# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royal de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# តួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌ ដំណាក់កាលសាលាដំបូង

ស្រាវជ្រាវថ្ងៃ២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **សែម សុផាន់ម៉ៃ**

កញ្ញា **យស់ សុគន្ធលីនដា**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ម ចាន់ណែត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# តួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌ ដំណាក់កាលសាលាដំបូង

ស្រាវជ្រាវថ្ងៃ២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **សែម សុផាន់ម៉ៃ**

កញ្ញា **យស់ សុគន្ធលីនដា**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ម ចាន់ណែត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **យស់ សុគន្ធលីនដា** និង **សែម សុផាន់ម៉ៃ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

មាតាបិតារបស់យើងខ្ញុំទាំងពីរនាក់ដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្តីជាមួយការអប់រំល្អៗប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន។ លោកទាំងទ្វេរបានជួយផ្គត់ផ្គង់គ្រប់បែបយ៉ាងមិនថា កម្លាំងកាយ កម្លាំងចិត្ត ផ្នែកស្មារតី ព្រមទាំងផ្នែកសម្ភារៈ ក្នុងគោលបំណងតែមួយគត់គឺចង់ឃើញកូនៗទទួលបានការអប់រំដែលល្អ។ លោកទាំងពីរជាព្រះព្រហ្ម ជាគ្រូបាអាចារ្យ ជាគ្រូពេទ្យ ជាអ្នកលើកទឹកចិត្តរបស់កូនគ្រប់ពេលវេលា។ លោកបានផ្តល់ឱកាសឲ្យយើងខ្ញុំទាំងពីរនាក់សិក្សារៀនសូត្រចាប់តាំងពីថ្នាក់កុមារដ្ឋាន រហូតដល់ថ្នាក់ឧត្តមសិក្សាដើម្បីឲ្យកូនបានក្លាយជាបុគ្គលមានតម្លៃទាំង ចំពោះខ្លួនឯង គ្រួសារ និង សង្គមជាតិ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យសិក្សា និងសាស្ត្រាចារ្យបណ្ឌិតគ្រប់មុខវិជ្ជាទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្ទេរនូវចំណេះដឹងដល់ពួកយើងខ្ញុំ និងសិស្សនិស្សិតដទៃទៀតតាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

លោកសាស្ត្រាចារ្យ **ម៉ម ចាន់ណែត** ដែលបានដឹកនាំក្នុងការសរសេរសារណាមួយនេះព្រមទាំងជួយណែនាំ ចង្អុលបង្ហាញ ផ្តល់មតិយោបល់ ដំបូន្មានល្អៗទាំងផ្នែកស្មារតី និងឯកសារ ព្រមទាំងជួយត្រួតពិនិត្យកែតម្រូវចំណុចខ្វះខាតជាពិសេស គឺពេលវេលាដ៏មានតម្លៃរបស់លោកនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះចាប់តាំងពីចំណុចចាប់ផ្តើមរហូតដល់សារណាមួយនេះបានបញ្ចប់ប្រកបដោយជោគជ័យ។

លោកមេធាវី **ខាន់ ច័ន្ទតូលិច** ប្រធានការិយាល័យមេធាវី មហិស្សរាដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំធ្វើការងារជាជំនួយការមេធាវីក្នុងការិយាល័យរបស់លោក ដើម្បីសិក្សារៀនសូត្រអំពីវិជ្ជាជីវៈមេធាវី និងចំណេះដឹងផ្សេងៗទៀត។ ហើយលោកបានផ្តល់មតិយោបល់ និងគោលគំនិតល្អៗដល់យើងខ្ញុំក្នុងការធ្វើសារណាមួយនេះបានយ៉ាងល្អព្រមទាំងជួយផ្តល់ឯកសារគម្រូមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទសារណានេះផងដែរ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរទៅដល់មាតាបិតាដែលជាអ្នកមានគុណទាំងពីរ រួមទាំងឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យណែនាំ សាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ មិត្តនិស្សិត សិស្សានុសិស្ស និងមិត្តរួមជំនាន់គ្រប់រូបទាំងអស់ សូមឲ្យប្រកបនូវសេចក្តីសុខ

ទាំងផ្លូវកាយ និង ផ្លូវចិត្ត ហើយថែមទទួលជោគជ័យគ្រប់ភារកិច្ចការងារ ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

# **អារម្ភកថា**

ក្រោយពីបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យរយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុមយើងខ្ញុំត្រូវបានខាងសាកលវិទ្យាល័យតម្រូវឲ្យជ្រើសរើសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាទៅតាមជំនាញឯកទេសដែលបានសិក្សាកន្លងមក។ ការសរសេរសារណាបញ្ចប់ការសិក្សានេះគឺជាការចូលរួមចំណែកមួយដ៏សំខាន់ដែលឆ្លុះបញ្ចាំងពីទ្រឹស្តីក្រោយពីបានសិក្សាកន្លងមកជាមួយនឹងបទពិសោធន៍ផ្ទាល់ក៏ដូចជាការអនុវត្តជាក់ស្តែងដើម្បីជាស្ពានឆ្ពោះទៅរកការអភិវឌ្ឍបន្ថែមទៀត។

ប្រទេសកម្ពុជា បានឆ្លងកាត់ពីសម័យកាលមួយទៅសម័យកាលមួយទៀត ដែលរួមមានទាំងសង្គ្រាមស៊ីវិលជាច្រើនទសវត្សន៍ផងដែរទើបធ្វើឲ្យវិជ្ជាជីវៈមេធាវីត្រូវបានបាត់បង់អស់មួយរយៈ ហើយអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ត្រូវបានគេសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលក្រោយថ្ងៃរំដោះ ឆ្នាំ១៩៧៩ វិជ្ជាជីវៈនេះបានកកើតឡើងវិញជាផ្លូវការដោយមានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នគ្រប់គ្រងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវីឆ្នាំ១៩៩៥។ ដោយមើលឃើញថាមេធាវីគឺជាបុគ្គលសំខាន់មួយរូបដែលរួមចំណែកយ៉ាងខ្លាំងក្នុងការស្វែងរកយុត្តិធម៌ក្នុងសង្គម ទើបយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី **តួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូង** មកធ្វើការស្រាវជ្រាវដោយសារតែយើងខ្ញុំយល់ឃើញថា មេធាវី គឺជាវិជ្ជាជីវៈមួយដែលឯករាជ្យ និងសេរីហើយបានចូលរួមលើកកម្ពស់នីតិរដ្ឋ និងយុត្តិធម៌សង្គម ហើយជាវិជ្ជាជីវៈមួយដែលមានមនុស្សជាច្រើនប្រាថ្នាចង់ធ្វើជាពិសេសនិស្សិតផ្នែកច្បាប់គ្រប់ៗរូប។ ការស្រាវជ្រាវលើប្រធានបទមួយនេះគឺពិតជាមានសារៈសំខាន់ណាស់ទាំងអ្នកសិក្សាស្រាវជ្រាវទាក់ទងនឹងមេធាវី នីតិវិធីតុលាការនៃការជម្រះលើកទី១ និងជាពិសេសទាក់ទងតួនាទីរបស់មេធាវីក្នុងនីតិវិធីបណ្តឹងព្រហ្មទណ្ឌនេះតែម្តង។ ម្យ៉ាងវិញទៀត ប្រធានបទសារណានេះក៏អាចជាស្ពានសម្រាប់ប្រជាពលរដ្ឋទូទៅដែលមានបំណងចង់យល់ដឹងឲ្យកាន់តែច្បាស់អំពីផ្នែកច្បាប់ ប្រព័ន្ធតុលាការ ជាពិសេសយល់ដឹងអំពីតួនាទីរបស់មេធាវីផ្ទាល់ ហើយដើម្បីឲ្យបានដឹង និងយល់អំពីតួនាទីរបស់មេធាវីថា មេធាវីពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងបណ្តឹងព្រហ្មទណ្ឌក្នុងការតំណាងឲ្យដើមចោទ និងចុងចម្លើយនៅក្នុងដំណើរការនីតិវិធីរបស់តុលាការដើម្បីជួយឲ្យដំណើរការនីតិវិធីបណ្តឹងប្រព្រឹត្តទៅបានយ៉ាងរលូនក៏ដូចជាការពារបាននូវផលប្រយោជន៍របស់កូនក្តីដែរ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថាសៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិតដែលមានបំណងចង់ពង្រីកចំណេះដឹង ក៏ដូចជាចង់យល់ដឹងឲ្យកាន់តែច្បាស់អំពីតួនាទីរបស់មេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌ។ យើងខ្ញុំទាំងពីរនាក់សូមអភ័យទោសជាមុនពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមិត្ត

អ្នកអានទាំងអស់នូវរាល់ចំណុចខ្វះខាតទាំងខ្លឹមសារ និង អក្ខរាវិរុទ្ធដែលមិនត្រឹមត្រូវដោយអចេតនាព្រមទាំងទទួលយករាល់មតិរិះគន់ក្នុងន័យស្ថាបនា ។

# មាតិកា


វាក្យសព្ទដែលប្រើក្នុងសារណា ........ v
បញ្ជីឧបសម្ព័ន្ធ ........ vii


## សេចក្ដីផ្ដើម


១. លំនាំនៃការសិក្សាស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣
៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ៤
៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៤
៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៥
ក. វិធីសាស្ត្រប្រមូលទិន្នន័យ ........ ៥
ខ. វិធីចងក្រង បញ្ចូលទិន្នន័យ និងព័ត៌មាន ........ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥


## ជំពូកទី១
## អំពីមេធាវី


**១.១ ប្រវត្តិនៃការកកើត និងការវិវត្តវិជ្ជាជីវៈមេធាវី** ........ ៨
**១.២ សារៈសំខាន់ និងតម្លៃរបស់មេធាវីនៅក្នុងសង្គម** ........ ១០
**១.៣ ក្របខណ្ឌបទដ្ឋានគតិយុត្តនៃវិជ្ជាជីវៈមេធាវី** ........ ១១
**១.៤ លក្ខខណ្ឌ និងនីតិវិធីចូលប្រកបវិជ្ជាជីវៈ** ........ ១២
១.៤.១ តាមរយៈការប្រឡងចូលប្រកបវិជ្ជាជីវៈមេធាវី ........ ១៣
១.៤.១.១ លក្ខខណ្ឌ ........ ១៣
១.៤.១.២ ការប្រឡង ........ ១៣
១.៤.១.៣ ការចុះកម្មសិក្សា ........ ១៤
១.៤.២ តាមរយៈសម្បថចូលប្រកបវិជ្ជាជីវៈមេធាវី ........ ១៤
១.៤.២.១ លក្ខខណ្ឌ ........ ១៤
១.៤.២.២ ការដាក់ពាក្យសុំ ........ ១៥
១.៤.២.៣ ការដាក់ពាក្យសុំធ្វើកម្មសិក្សា ........ ១៥
**១.៥ ក្រមសីលធម៌ក្នុងការប្រកបវិជ្ជាជីវៈមេធាវី** ........ ១៦

១.៥.១ ឯករាជ្យភាព និង សេរីភាពនៃវិជ្ជាជីវៈមេធាវី ..................... ១៦
១.៥.២. តម្លៃសីលធម៌នៃវិជ្ជាជីវៈមេធាវី ..................... ១៧
១.៥.២.១ សញ្ញាណទូទៅ ..................... ១៧
១.៥.២.២ ការទទួលរឿងក្តី ..................... ១៧
១.៥.២.៣ ការប្រុងប្រយ័ត្ន ..................... ១៧
១.៥.២.៤ សុចរិតភាព និង ភាពស្មោះត្រង់ ..................... ១៨
១.៥.២.៥ ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ..................... ១៨
១.៥.២.៦ ទំនាស់ផលប្រយោជន៍ និង ការហាមឃាត់ ..................... ១៩
១.៥.៣. ការបង់ភាគទាន ..................... ២០

## ជំពូកទី២

## សិទ្ធិ និង ករណីយកិច្ចរបស់មេធាវី

**២.១ ករណីយកិច្ចរបស់មេធាវី** ..................... ២២
២.១.១ ករណីយកិច្ចចំពោះវិជ្ជាជីវៈ ..................... ២២
២.១.១.១ ការចៀសវាងជាដាច់ខាតទំនាស់រវាងករណីយកិច្ចវិជ្ជាជីវៈ និង ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មេធាវី ..................... ២៣
២.១.១.២ សហប្រតិបត្តិការរបស់មេធាវីជាមួយគណៈមេធាវី ..................... ២៣
២.១.២ ករណីយកិច្ចចំពោះអតិថិជន ..................... ២៤
២.១.៣ ករណីយកិច្ចចំពោះតុលាការ ..................... ២៥
**២.២ សិទ្ធិរបស់មេធាវី** ..................... ២៥
២.២.១ អំពីសិទ្ធិ ..................... ២៥
២.២.១.១ សិទ្ធិក្នុងការបំពេញវិជ្ជាជីវៈដោយគ្មានការជ្រៀតជ្រែក ..................... ២៥
២.២.១.២ សិទ្ធិក្នុងការទទួលបានការការពារ ..................... ២៦
២.២.១.៣ សិទ្ធិទទួលបានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ..................... ២៦
២.២.១.៤ សិទ្ធិក្នុងការតំណាងកូនក្តី ..................... ២៦
២.២.១.៥ សិទ្ធិក្នុងការទទួលបានកូនក្តី និងព័ត៌មានចាំបាច់សម្រាប់ការពារកូនក្តី ..................... ២៧
២.២.១.៦ សិទ្ធិមិនត្រូវសម្តែងមានសមានចិត្តជាមួយកូនក្តី ..................... ២៧
២.២.១.៧ សិទ្ធិក្នុងការទទួលបានការសម្ងាត់ផ្នែកវិជ្ជាជីវៈមេធាវី ..................... ២៧
២.២.១.៨ សិទ្ធិទទួលបានការអប់រំ និងការបណ្តុះបណ្តាល ..................... ២៨

២.២.១.៩ សិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ និង ការបង្កើតសមាគម ..............២៨
**២.៣ តួនាទី និង សារៈសំខាន់របស់មេធាវី**............................................................២៨
២.៣.១ តួនាទីរបស់មេធាវី..........................................................................................២៩
២.៣.១.១ សញ្ញាណទូទៅរបស់មេធាវី.......................................................................២៩
២.៣.១.២ តួនាទីរបស់មេធាវីក្នុងការផ្តល់ប្រឹក្សាផ្នែកច្បាប់..........................................២៩
២.៣.១.៣ បេសកកម្មរបស់មេធាវី ............................................................................២៩

# ជំពូកទី៣

# តួនាទីមេធាវីក្នុងដំណាក់កាលសំខាន់ៗនៃនីតិវិធី

**៣.១ ដំណាក់កាលស៊ើបអង្កេត**............................................................................ ៣២
៣.១.១ តួនាទីមេធាវីក្នុងការស៊ើបអង្កេតករណីជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌ .................. ៣៣
៣.១.១.១ លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតជាក់ស្តែង .......................................... ៣៣
៣.១.២ តួនាទីមេធាវីក្នុងការស៊ើបអង្កេតបឋមរបស់មន្ត្រីនគរបាលយុត្តិធម៌ ...............................៣៤
៣.១.២.១ លក្ខខណ្ឌនៃការស៊ើបអង្កេតបឋម ..........................................................៣៤
៣.១.៣ សិទ្ធិមានមេធាវីរបស់ជនសង្ស័យក្នុងដំណាក់កាលឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌....៣៥
៣.១.៤ ជំនួយមេធាវីពេលជាប់ឃុំ ........................................................................... ៣៧
**៣.២ ដំណាក់កាលចោទប្រកាន់** ..............................................................................៣៨
៣.២.១ វត្តមានមេធាវីក្នុងពេលស្តាប់ចម្លើយ .................................................................៣៨
**៣.៣ ដំណាក់កាលស៊ើបសួរ**.....................................................................................៣៨
៣.៣.១ កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ......................................................................៣៩
៣.៣.១.១ វត្តមានមេធាវីក្នុងពេលសួរចម្លើយជនត្រូវចោទ ............................................៣៩
៣.៣.១.២ វត្តមានមេធាវីពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី .............................. ៤០
៣.៣.២ វិធានការនិរន្តរាយ ...................................................................................... ៤០
៣.៣.២.១ ការឃុំខ្លួនបណ្តោះអាសន្ន..................................................................... ៤១
៣.៣.២.២ ជំនួយមេធាវីក្នុងការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ.............................៤២
៣.៣.២.៣ ការកោះហៅ និងជូនដំណឹងដល់មេធាវី ..................................................៤៣
៣.៣.២.៤ បណ្តឹងសុំកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ............................ ៤៤
៣.៣.៣ ការស្នើសុំឲ្យបំពេញកិច្ចដោយមេធាវីជនត្រូវចោទ.............................................. ៤៤
៣.៣.៤ ការស្នើសុំឲ្យបំពេញកិច្ចដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ....................................... ៤៥

៣.៣.៥ ការបិទការស៊ើបសួរ ........ ៤៥
៣.៣.៦ ការប្ដឹងអំពីសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ ........ ៤៥
៣.៣.៦.១ ការប្ដឹងមោឃភាពកិច្ចនៃនីតិវិធី ........ ៤៥
៣.៣.៦.២ បណ្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ ........ ៤៦
**៣.៤ ដំណាក់កាលជំនុំជម្រះ** ........ ៤៧
៣.៤.១ នីតិវិធីមុនពេលសវនាការ ........ ៤៧
៣.៤.១.១ នីតិវិធីនៃការសម្រេចមុនអង្គសេចក្ដី ........ ៤៧
៣.៤.២ នីតិវិធីក្នុងពេលសវនាការ ........ ៤៨
៣.៤.២.១ ការពិភាក្សាដេញដោល ........ ៤៩
៣.៤.២.២ សិទ្ធិនិយាយជាបន្ដបន្ទាប់ ........ ៥០
៣.៤.២.៣ សេចក្ដីសន្និដ្ឋានរបស់មេធាវី ........ ៥០
**៣.៥ ដំណាក់កាលក្រោយពេលសវនាការ** ........ ៥១
៣.៥.១ កិច្ចនីតិវិធីការពារឲ្យជនជាប់ចោទ ........ ៥១
៣.៥.១.១ បណ្ដឹងទាស់ ........ ៥២
៣.៥.១.២ បណ្ដឹងឧទ្ធរណ៍ ........ ៥៣
៣.៥.២ កិច្ចនីតិវិធីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី និង ជនរងគ្រោះ ........ ៥៣
៣.៥.២.១ ការជូនដំណឹងដល់ជនត្រូវចោទសងសំណង ........ ៥៤
៣.៥.២.២ ការដាក់ពាក្យសុំអនុវត្តបង្ខំលើរូបកាយ ........ ៥៤
៣.៥.២.៣ ការដាក់ពាក្យសុំអនុវត្តលើទ្រព្យសម្បត្តិ ........ ៥៥
**សេចក្ដីសន្និដ្ឋាន** ........ ៥៧
**អនុសាសន៍** ........ ៥៩
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# វាក្យសព្ទដែលប្រើក្នុងសារណា

- មេធាវី — ជនដែលជាសមាជិកនៃគណៈមេធាវី ផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗ ក្នុងវិស័យគតិយុត្ត តំណាងឱ្យកូនក្តី ឬការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី។
- ព្រះរាជអាជ្ញា — គឺជាអ្នកដែលផ្តួចផ្តើមធ្វើបណ្តឹងអាជ្ញាក្នុងការចោទប្រកាន់បទល្មើសណាមួយទៅលើជនណាម្នាក់អោយតុលាការផ្តន្ទាទោស។
- ចៅក្រម — សំដៅដល់ចៅក្រមអាសនៈរួមមានជាអាទិ៍ ចៅក្រមស៊ើបសួរ និងចៅក្រមជម្រះក្តី។
- ជនល្មើស — រួមមាន ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត។
- ជនជាប់ចោទ — ជនដែលស្ថិតក្នុងដំណាក់កាលជំនុំជម្រះ។
- ជនត្រូវចោទ — ជនដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ហើយស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរ។
- ពិរុទ្ធជន — ជនដែលតុលាការបានធ្វើការជំនុំជម្រះក្តី ប៉ុន្តែពុំទាន់ចេញសាលក្រមជាស្ថាពរ។
- បទល្មើស — គឺជាអំពើល្មើសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលច្បាប់បានហាមឃាត់។
- ព្យសនកម្ម — ជាការបង្កឲ្យមានការខូចខាតផ្លូវចិត្ត រូបរាងកាយ សំភារៈ។
- ការឃាត់ខ្លួន — ជាការឃាត់ខ្លួនបុគ្គលណាម្នាក់ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសដោយមន្ត្រីនគរបាលយុត្តិធម៌។
- សាក្សី — បុគ្គល ដែលត្រូវតុលាការកោះហៅមកសាកសួរនូវហេតុការណ៍ ដែលមានប្រយោជន៍ដល់ការវិនិច្ឆ័យរឿងក្តី។
- អនីតិជន — ជនដែលមានអាយុតិចជាង១៨(ដប់ប្រាំបី)ឆ្នាំ។
- នគរបាល — ជាអ្នកថែរក្សាការពារ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងបង្ក្រាបបទល្មើស ព្រមទាំងចាប់ជនល្មើស ក៏ជាជំនួយដល់តុលាការផងដែរ។
- នគរបាលយុត្តិធម៌ — ត្រូវបានចែកជាមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យ។
- ទោសព្រហ្មទណ្ឌ — គឺជាការបែងចែកដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ គឺមូលទោស រួមមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

- ○ បណ្ដឹងឧទ្ធរណ៍ ជាបណ្ដឹងឧបាស្រ័យមួយប្រភេទដែលនាំឲ្យសំណុំរឿងត្រូវផ្ទេរទៅសាលាឧទ្ធរណ៍ក្នុងព្រំដែនដែលកំណត់ដោយលិខិតប្ដឹងឧទ្ធរណ៍ និងតាមឋានៈអ្នកប្ដឹងឧទ្ធរណ៍។
- ○ ដីកាដំណោះស្រាយ ជាដីកាចេញដោយចៅក្រមស៊ើបសួរបន្ទាប់ពីបិទការស៊ើបសួរ ហើយដីកាដំណោះស្រាយអាចជាដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនទៅជំនុំជម្រះ។
- ○ សាលក្រម ជាសេចក្ដីសម្រេចផ្ដន្ទាទោសរបស់សាលាដំបូង ដែលមានដូចជាសាលក្រមចំពោះមុខ សាលក្រមចាត់ទុកថាចំពោះមុខ និងសាលក្រមកំបាំងមុខ។
- ○ អញ្ញត្រកម្ម អំពើមិនដូចប្រក្រតី, ហេតុដែលកើតមានឡើងថ្មី ឬករណីលើកលែង។
- ○ ប្ដឹងមោឃភាព ជាការប្ដឹងមោឃភាពចំពោះការមិនគោរពវិធានបញ្ញត្តិនៃនីតិវិធីស៊ើបសួរមានដូចជាការបើកការស៊ើបសួរ សមត្ថកិច្ចដែនដី ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ វិសាលភាពនៃការប្ដឹង និងជំនួយរបស់ក្រឡាបញ្ជី។
- ○ វិធានការនិរន្តរាយ គឺជាដំណាក់កាលមួយ ដែលជាការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់ត្រូវបានអនុវត្តដោយអំណាចចាប់បង្ខំរបស់រដ្ឋតាមរយៈស្ថាប័នអំណាចតុលាការ។
- ○ សភាស៊ើបសួរ ជាសភាមួយនៃសាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ចជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍ និង ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ លើបណ្ដឹងមោឃភាពនៃកិច្ចនីតិវិធី និងលើបណ្ដឹងផ្ទាល់ពីចំណាត់ការរបស់ចៅក្រមស៊ើបសួរ។
- ○ បណ្ដឹងក្នុងរឿងក្ដីព្រហ្មទណ្ឌ គឺជាបណ្ដឹងមួយ ដែលបានធ្វើឡើងដោយជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬតតិយជន ហើយបណ្ដឹងនេះមានពីរ បណ្ដឹងទាមទារ និងបណ្ដឹងបរិហារ។

# បញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ឧបសម្ព័ន្ធ១ | ពាក្យសុំធ្វើកម្មសិក្សា |
| ឧបសម្ព័ន្ធ២ | កិច្ចព្រមព្រៀងរវាងមេធាវី និង អតិថិជន |
| ឧបសម្ព័ន្ធ៣ | ពាក្យតំណាង និង ការពារក្តី<br>(ក) ពាក្យសុំពិនិត្យ និងថតចម្លងសុំណុំរឿង<br>(ខ) ពាក្យពឹងពាក់មេធាវី |
| ឧបសម្ព័ន្ធ៤ | លិខិតតំណាងដោយអាណត្តិ<br>(ក) ពាក្យសុំពិនិត្យ និងថតចម្លងសុំណុំរឿង<br>(ខ) លិខិតប្រគល់អាណត្តិ |
| ឧបសម្ព័ន្ធ៥ | ពាក្យសុំឈប់តំណាងដោយអាណត្តិ |
| ឧបសម្ព័ន្ធ៦ | ពាក្យសុំអនុញ្ញាតជួបកូនក្តី |
| ឧបសម្ព័ន្ធ៧ | ពាក្យសុំបញ្ចូលភស្តុតាង |
| ឧបសម្ព័ន្ធ៨ | ពាក្យសុំឲ្យកូនក្តីនៅក្រៅឃុំ |
| ឧបសម្ព័ន្ធ៩ | ពាក្យសុំពន្យាពេលចូលបំភ្លឺ |
| ឧបសម្ព័ន្ធ១០ | ពាក្យស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ |
| ឧបសម្ព័ន្ធ១១ | ពាក្យសុំមោឃៈភាពនីតិវិធី |
| ឧបសម្ព័ន្ធ១២ | សេចក្តីសន្និដ្ឋានរបស់មេធាវី |
| ឧបសម្ព័ន្ធ១៣ | លិខិតប្រគល់សិទ្ធិប្តឹងទាស់<br>(ក) ពាក្យបណ្តឹងទាស់ |
| ឧបសម្ព័ន្ធ១៤ | ពាក្យបណ្តឹងឧទ្ធរណ៍ |
| ឧបសម្ព័ន្ធ១៥ | លិខិតប្រគល់សិទ្ធិប្តឹងទាមទារសំណងរដ្ឋប្បវេណី |
| ឧបសម្ព័ន្ធ១៦ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័ត<br>ដោយរដ្ឋសភាចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ |

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំនៃការសិក្សាស្រាវជ្រាវ

បន្ទាប់ពីវិជ្ជាជីវៈមេធាវី បានកើតឡើងនៅក្នុងសង្គមកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំណាស់មកហើយ វិជ្ជាជីវៈមួយនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងវិស័យយុត្តិធម៌លើកកម្ពស់នីតិរដ្ឋ សង្គមជាតិ និងលទ្ធិ-ប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាផងដែរ។ ប្រទេសកម្ពុជាបានឆ្លងកាត់ពីសម័យកាលមួយទៅសម័យកាលមួយទៀតដែលរួមមានទាំងសង្គ្រាមស៊ីវិលជាច្រើនទសវត្សន៍ផង ទើបធ្វើឲ្យវិជ្ជាជីវៈមេធាវីត្រូវបានបាត់បង់មួយរយៈហើយអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ត្រូវបានគេសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩វិជ្ជាជីវៈនេះបានកកើតឡើងវិញជាផ្លូវការដោយមានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលជាស្ថាប័នគ្រប់គ្រងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវីឆ្នាំ១៩៩៥។ ក្រោយមកវិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវីចំនួន២ផ្សេងទៀតត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវីឆ្នាំ១៩៩៥ គឺបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី និងក្រមសីលធម៌មេធាវី។

ដោយសារព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនលូតលាស់គ្រប់វិស័យដែលក្នុងនោះមានជាអាទិ៍ការរីកចម្រើនក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និងវិស័យយុត្តិធម៌ ទើបធ្វើឲ្យវិជ្ជាជីវៈមេធាវីមានការរីកចម្រើនជាបន្តបន្ទាប់។ ដើម្បីធានានូវរបៀបរៀបរយនៃការប្រកបវិជ្ជាជីវៈមេធាវី និងជាពិសេសអាចធានាបាននូវសេចក្តីថ្លៃថ្នូរ ឯករាជ្យ សេរីភាព នៃវិជ្ជាជីវៈមេធាវី និងទទួលបានទំនុកចិត្តខ្ពស់ពីអតិថិជន គណៈមេធាវីបានធ្វើការអនុម័ត និង ប្រកាសឲ្យប្រើប្រាស់ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រនៅ ឆ្នាំ២០១២។ លើសពីនេះ ក្រុមប្រឹក្សានៃគណៈមេធាវីក៏បានធ្វើការអនុម័តទៅលើសេចក្តីសម្រេចដាក់ឲ្យអនុវត្តនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃលក្ខន្តិកៈមេធាវីនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ដើម្បីធ្វើការកំណត់ឲ្យបានច្បាស់លាស់ពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំចូលប្រកបវិជ្ជា-ជីវៈមេធាវីដោយមិនឆ្លងកាត់ការប្រឡងផងដែរ។

មេធាវី ដើរតួនាទីយ៉ាងសំខាន់ចំពោះបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌដើម្បីការពារដើមចោទនិងចុងចម្លើយ។ មេធាវី គឺជាអ្នកតំណាងដ៏សំខាន់ក្នុងបណ្តឹងទាំងពីរនេះ។ ចំពោះតួនាទីមេធាវីក្នុងនីតិវិធីព្រហ្ម-ទណ្ឌនេះយើងខ្ញុំលើកយកតែតួនាទីមេធាវីក្នុងបណ្តឹងព្រហ្មទណ្ឌមកសិក្សាប៉ុណ្ណោះ។ ជាក់ស្តែងក្នុងសង្គមនាពេលបច្ចុប្បន្ននេះ តែងតែមានរឿងក្តីព្រហ្មទណ្ឌកើតឡើង ដែលបានបង្កឲ្យមានព្យសនកម្មធ្វើឲ្យខូចខាត

ផ្លូវកាយ ផ្លូវចិត្ត សម្ភារៈ ក៏ដូចជាផលប្រយោជន៍សាធារណៈបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ ដែលត្រូវការមានមេធាវីការពារសិទ្ធិជាចាំបាច់នៅមានការឃាត់ខ្លួន និងពិភាក្សាយោបល់ផ្នែកច្បាប់ពីមេធាវី។ មេធាវីដើរតួនាទីយ៉ាងសំខាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌដោយសារតែជាប្រយោជន៍សាធារណៈដែលមានស្ថាប័នអយ្យការជាម្ចាស់បណ្តឹងអាជ្ញាហើយអាចសម្រេចធ្វើការចោទប្រកាន់ពីបទល្មើសណាមួយបាន។

មេធាវី មានតួនាទីការពារកូនក្តីខ្លួនឲ្យរួចផុតពីបទល្មើស ឬការចោទប្រកាន់ការរំលោភបំពានលើរាងកាយជាពិសេសអនីតិជន ដើម្បីជាប្រយោជន៍ដល់កូនក្តីរួមទាំងជួយសម្រួលដល់ដំណើរការប្រព្រឹត្តទៅនៃនីតិវិធីរបស់តុលាការ ព្រោះមេធាវីអាចចូលរួមបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌដើម្បីស្វែងរកនូវភស្តុតាងដែលជាប្រយោជន៍ដល់កូនក្តី។ លើសពីនេះតម្រូវឲ្យមេធាវីការពារក្តីត្រូវមានសមត្ថភាពខ្ពស់ដើម្បីការពារកូនក្តីរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព។ ការស្រាវជ្រាវនេះយើងខ្ញុំនឹងធ្វើការសិក្សាអំពី តួនាទីមេធាវីក្នុងនីតិវិធីបណ្តឹងព្រហ្មទណ្ឌ ដែលជាអ្នកការពារស្របច្បាប់ដល់កូនក្តីក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ។

យ៉ាងណាមិញសៀវភៅសារណាស្តីពី តួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូងស្ថិតនៅក្នុងទីនេះ ដែលយើងខ្ញុំជានិស្សិតច្បាប់បានខិតខំស្រាវជ្រាវយកមកសរសេរយ៉ាងក្បោះក្បាយ ពាក់ព័ន្ធនៅតួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូងជាពិសេស មុខងារ តួនាទី និង ក្រមសីលធម៌ក្នុងការប្រកបវិជាជីវៈមេធាវីអោយស្របតាមច្បាប់ ដើម្បីយុត្តិធម៌សង្គមមកធ្វើការបង្ហាញដល់សាធារណជនដើម្បីឲ្យកាន់តែលម្អិតអំពីវិស័យច្បាប់ដែលពាក់ព័ន្ធទៅនឹងរឿងក្តីព្រហ្មទណ្ឌ ដែលជាពិសេសតួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌតែម្តង ថាតើមេធាវីនឹងត្រូវធ្វើអ្វីខ្លះដើម្បីវិស័យយុត្តិធម៌ ជៀសវាងការយល់ច្រលំថាមេធាវីជាអ្នកសម្រេចក្តី ឬជាអ្នកចោទប្រកាន់ជាដើម។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅសារណាមួយក្បាលនេះនឹងចូលរួមជាចំណែកមួយដល់សិស្ស និស្សិត និងប្រជាពលរដ្ឋគ្រប់រូបក្នុងការបង្កើនចំណេះដឹងរបស់ខ្លួនឲ្យបានកាន់តែទូលាយជាងនេះផងដែរ។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ជាទូទៅមេធាវីត្រូវបានគេចាត់ទុកថាជាបុគ្គល ដែលមានចំណេះដឹងផ្នែកច្បាប់យ៉ាងស្ទាត់ជំនាញដែលជាជំនួយដល់ភាគីមានជម្លោះសម្រាប់ដាក់ពាក្យបណ្តឹង និងដំណើរការរឿងក្តីតាមនីតិវិធីច្បាប់ប៉ុន្តែនៅមានប្រជា-ជនមួយចំនួនពុំទាន់យល់ច្បាស់ពីតួនាទី និងភារកិច្ចរបស់មេធាវីឲ្យបានច្បាស់លាស់នូវឡើយស្របពេលដែលវាពិតជាមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋក្នុងការសិក្សាស្វែងយល់។ ការសិក្សាស្វែងយល់ពីតួនាទីរបស់មេធាវីនៅក្នុងនីតិវិធីព្រហ្មទណ្ឌគឺជាការចាំបាច់សម្រាប់អ្នកសិក្សាស្រាវជ្រាវទាំងឡាយ និងប្រជាជននៅក្នុងសង្គមជាតិព្រោះថាមេធាវី ជាអ្នកការពារក្តីស្របច្បាប់មួយរូបសម្រាប់ស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់រូបក្នុងការប្តឹង

ទាមទារ ឬស្វែងរកនូវយុត្តិធម៌ដែលពួកគេត្រូវការ។ ហេតុនេះនៅពេលមានបញ្ហាណាមួយបានកើតឡើងមេធាវីអាចចូលរួមចំណែកក្នុងការស្វែងរកដំណោះស្រាយដែលមានលក្ខណៈត្រឹមត្រូវផ្អែកលើចំណេះ និងវិជ្ជាជីវៈស្របច្បាប់របស់ខ្លួន។ ដូចនេះទើបធ្វើឲ្យការសិក្សាស្រាវជ្រាត្រូវវធ្វើឡើងដោយមានចំណោទបញ្ហាដូចតទៅ៖

- តើមេធាវីជានរណា?
- តើវិជ្ជាជីវៈមេធាវីកើតឡើងយ៉ាងដូចម្ដេច? ហើយវិជ្ជាជីវៈនេះមានការវិវត្តដូចម្ដេចខ្លះ?
- តើត្រូវមានលក្ខណៈសម្បត្តិ និង គុណវិបត្តិអ្វីខ្លះទើបអាចក្លាយជាមេធាវី?
- តើត្រូវធ្វើយ៉ាងដូចម្ដេចទើបអាចចូលប្រកបវិជ្ជាជីវៈមេធាវីបាន?
- តើលំហូរនីតិវិធីព្រហ្មទណ្ឌមានលក្ខណៈដូចម្ដេចខ្លះ?
- តើនៅគ្រប់ដំណាក់កាលទាំងអស់នៃរឿងក្ដីព្រហ្មទណ្ឌត្រូវតែមានមេធាវី ឬយ៉ាងណា?
- តើមេធាវីមានតួនាទីអ្វីខ្លះនៅក្នុងលំហូរនៃនីតិវិធីព្រហ្មទណ្ឌ?

ដើម្បីឲ្យជ្រាបកាន់តែច្បាស់ទៅលើប្រធានបទ និងឈានដល់ការបកស្រាយនូវខ្លឹមសារទាំងមូលឲ្យបានក្បោះក្បាយ និងស៊ីជម្រៅក្រុមយើងខ្ញុំនឹងធ្វើការឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធទាំងនោះដោយធ្វើការបកស្រាយនៅក្នុងប្រធានបទសារណានេះទាំងមូល ។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវខាងលើនេះយើងខ្ញុំបានស្រាវជ្រាវយកមកសរសេរចងក្រងឡើងដោយមានគោលបំណងផ្ដោតសំខាន់ដូចជា៖

- ដើម្បីយល់ដឹងពីបែបបទដែលអាចក្លាយជាមេធាវី និង ការចូលប្រកបវិជ្ជាជីវៈមេធាវីប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។
- ដើម្បីធ្វើការសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅបន្ថែមពីតួនាទីមេធាវីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌនៅពេលជំនុំជម្រះលើកទីមួយ។
- ស្វែងយល់ពីភារកិច្ចរបស់មេធាវីដែលត្រូវបំពេញនៅពេលដែលការពារកូនក្ដីក្នុងរឿងក្ដីព្រហ្មទណ្ឌ។
- ស្វែងយល់ពីនីតិវិធីនៃរឿងក្ដីព្រហ្មទណ្ឌចាប់តាំងពីការដាក់ពាក្យបណ្ដឹង រហូតដល់ការប្រកាសសាលក្រម។
- ស្វែងយល់ពីការទទួលខុសត្រូវរបស់មេធាវី ចំពោះកូនក្ដីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។
- ដើម្បីទុកជាឯកសារជំនួយដល់អ្នកសិក្សាស្រាវជ្រាវ ទុកជាការសិក្សាស្វែងយល់បន្ថែមពីតួនាទីរបស់មេធាវីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូង។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

របាយការណ៍សិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតសំខាន់លើមេធាវី និងតួនាទីរបស់មេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូង។ យើងខ្ញុំនឹងធ្វើការបកស្រាយទាក់ទងនឹងលក្ខន្តិកៈមេធាវី និងការប្រកបវិជ្ជាជីវៈមេធាវីដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រ ឆ្នាំ១៩៩៥ ក្រមសីលធម៌មេធាវីឆ្នាំ២០១២ និងតួនាទីរបស់មេធាវីនៅក្នុងនីតិវិធីនៃការជំនុំជម្រះលើកទី១ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៦ ដែលយើងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះប៉ុណ្ណោះ។

ក. ទំហំនៃការស្រាវជ្រាវៈគឺនៅក្នុងដំណាក់កាលសាលាដំបូងរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ខ. ដែនកំណត់នៃការស្រាវជ្រាវៈ គឺការសរសេររៀបរាប់ចាប់ពីដំណាក់កាលនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ និង ដំណាក់កាលក្រោយពេលសវនាការ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនីមួយៗគឺ ពិតណាស់តែងតែជួបការលំបាកព្រោះយើងត្រូវការចំណាយពេលវេលាច្រើន ព្រមទាំងកម្លាំងកាយចិត្ត ក៏ដូចជាថវិកាជាដើម ជាពិសេសគឺត្រូវមានចំណង់ចំណូលចិត្ត និង ការព្យាយាមបន្ថែមទៀតផង ទើបការសិក្សាស្រាវជ្រាវរបស់យើងទទួលបានជោគជ័យ។

ទោះបីមានការលំបាកយ៉ាងណាក៏ដោយក៏យើងខ្ញុំនៅតែខិតខំជម្នះឲ្យទាល់តែបានពីព្រោះថាការសិក្សាស្រាវជ្រាវប្រធានបទនេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យើងខ្ញុំដែលក្នុងនោះរួមមានដូចជាៈ

- ទទួលបានចំណេះដឹងថ្មីៗពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ
- យល់ដឹងកាន់តែលម្អិតទៅលើប្រធានបទដែលសិក្សាស្រាវជ្រាវ
- ទទួលបានប្រភពឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ
- ចេះធ្វើការប្រៀបធៀបរវាងចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និង ដំណោះស្រាយ
- ទទួលបានបទពិសោធន៍ល្អៗពីអ្នកមានចំណេះដឹង និងព្រមទាំងអ្នកមានបទពិសោធន៍
- យល់កាន់តែច្បាស់បន្ថែមទៀត អំពីការរៀបប្រយោគ ឃ្លោងឃ្លា និង អក្ខរាវិរុទ្ធ
- ជាពិសេសគឺបានបន្សល់ស្នាដៃទុកសម្រាប់សិស្ស និស្សិត បានសិក្សាស្រាវជ្រាវបន្តទៀតផង។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ យើងខ្ញុំបានខិតខំប្រើប្រាស់នូវវិធីសាស្ត្រជាច្រើនដើម្បីយកមកសរសេរសារណានេះឡើងដែលក្នុងនោះរួមមានដូចជា៖

### ក. វិធីសាស្ត្រប្រមូលទិន្នន័យ

ចំពោះវិធីសាស្ត្រប្រមូលទិន្នន័យគឺ យើងខ្ញុំបានសម្រេចចិត្តរៀបរៀងសរសេរសារណានេះឡើង ដោយបានធ្វើការប្រមូលទិន្នន័យគឺតាមបែបគុណវិស័យ ដែលជាទិន្នន័យបានមកពីការប្រមូលឯកសារ ទ្រឹស្តី ព័ត៌មាន របាយការណ៍ ការជួបសម្ភាសន៍ ការសាកសួរដោយផ្ទាល់មាត់ ការស្នើសុំឯកសារ និងរបាយការណ៍ដើម្បីឲ្យដំណើរការនៃការស្រាវជ្រាវនេះទទួលបានភាពជោគជ័យ ។

ចំពោះប្រភព និងប្រភេទនៃវិធីប្រមូលទិន្នន័យឯកសារ និងព័ត៌មានដែលបានសរសេរតាមគុណវិស័យរួមមាន៖

- ក្រមនីតិវិធីព្រហ្មទណ្ឌក្នុងឆ្នាំ២០០៧
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមសីលធម៌មេធាវី ឆ្នាំ២០១២
- បទបញ្ជាផ្ទៃក្នុងគណៈមេធាវី ឆ្នាំ២០១៦
- ឯកសារច្បាប់ផ្សេងទៀតដែលចងក្រងដោយសាស្ត្រាចារ្យ
- ការជួបសម្ភាសន៍ជាមួយសាស្ត្រចារ្យណែនាំសារណាក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធផងដែរ និង
- ការប្រមូលឯកសារទិន្នន័យជាច្រើនទៀតតាមប្រព័ន្ធផ្សព្វផ្សាយនានា។

### ខ. វិធីចងក្រង បញ្ចូលទិន្នន័យ និងព័ត៌មាន

បន្ទាប់ពីប្រមូលឯកសារ និងរបាយការណ៍បានគ្រប់គ្រាន់ហើយ យើងខ្ញុំបានប្រើប្រាស់វិធីចងក្រងឯកសារទៅតាមផ្នែកនីមួយៗដើម្បីកុំឲ្យមានការភ័ន្តច្រឡំគ្នា ហើយក៏បានវាយឯកសារទាំងនោះបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ទៅតាមប្រភេទ និងផ្នែកដែលបានព្រៀងទុក។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវប្រធានបទ "តួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌក្នុងដំណាក់កាលសាលាដំបូង" គឺត្រូវបានបែងចែករចនាសម្ព័ន្ធចេញជា៣ជំពូកសំខាន់ៗដូចខាងក្រោម៖

- **ជំពូកទី១ អំពីមេធាវី ៖** គឺជាការបង្ហាញអំពីប្រវត្តិនៃការវិវត្តវិជ្ជាជីវៈមេធាវី សារៈសំខាន់ និងតម្លៃរបស់មេធាវីនៅក្នុងសង្គម ក៏ដូចក្របខណ្ឌគតិយុត្តនៃវិជ្ជាជីវៈមេធាវីថែមទាំងលក្ខខណ្ឌ និងនីតិវិធីចូលប្រកបវិជ្ជាជីវៈ ហើយជាពិសេសបង្ហាញពីក្រមសីលធម៌វិជ្ជាជីវៈមេធាវីក្នុងការប្រកបវិជ្ជាជីវៈផ្ទាល់តែម្តង។
- **ជំពូកទី២ សិទ្ធិ និងករណីយកិច្ចរបស់មេធាវី ៖** ក្នុងជំពូកនេះគឺបង្ហាញអំពីករណីយកិច្ចរបស់មេធាវីនឹងសិទ្ធិរបស់មេធាវីថែមទាំងបង្ហាញអំពីសារៈសំខាន់ និងតួនាទីរបស់មេធាវីក្នុងសង្គមទៀតផង។
- **ជំពូកទី៣ តួនាទីមេធាវីក្នុងដំណាក់កាលសំខាន់ៗនៃនីតិវិធី ៖** នៅក្នុងជំពូកនេះផ្ទាល់គឺជាជំពូកសំខាន់ជាងគេក្នុងប្រធានបទមួយនេះដោយបង្ហាញយ៉ាងពិស្តារអំពីតួនាទីរបស់មេធាវីនៅក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌនៃដំណាក់កាលនីមួយៗរបស់មេធាវីក្នុងការតំណាងឲ្យកូនក្តី និងការការពាររកយុត្តិធម៌ជូនកូនក្តីក៏ដូចជាស្វែងរកយុត្តិធម៌សាធារណៈសម្រាប់សង្គមជាតិ។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៖** ការស្វែងរកចំណុចវិជ្ជមាន និងអវិជ្ជមានដែលកើតមានឡើង និងការខិតខំព្យាយាមស្វែងរកដំណោះស្រាយដ៏សមរម្យដើម្បីចូលរួមកាត់បន្ថយនូវកង្វះខាតទាំងឡាយនោះដែលបានកើតឡើង។

# គំនូសបំព្រួញនៃជំពូកនីមួយៗរបស់សារណា

**ប្រធានបទ**

**តួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូង**

**សេចក្តីផ្តើម**

**ជំពូកទី១៖ អំពីមេធាវី**

១.១ ប្រវត្តិនៃការកកើត និងការវិវត្តវិជ្ជាជីវៈមេធាវី

១.២ សារៈសំខាន់ និងតម្លៃរបស់មេធាវីនៅក្នុងសង្គម

១.៣ ក្របខណ្ឌបទដ្ឋានគតិយុត្តនៃវិជ្ជាជីវៈមេធាវី

១.៤ លក្ខខណ្ឌ និង នីតិវិធីចូលប្រកបវិជ្ជាជីវៈ

១.៥ ក្រមសីលធម៌ក្នុងការប្រកបវិជ្ជាជីវៈមេធាវី

**ជំពូកទី២**

**សិទ្ធិ និង ករណីយកិច្ចរបស់មេធាវី**

២.១ ករណីយកិច្ចរបស់មេធាវី

២.២ សិទ្ធិរបស់មេធាវី

២.៣ តួនាទី និង សារៈសំខាន់របស់មេធាវី

**ជំពូកទី៣**

**តួនាទីមេធាវីក្នុងដំណាក់កាលសំខាន់ៗនៃនីតិវិធី**

៣.១ ដំណាក់កាលស៊ើបអង្កេត

៣.២ ដំណាក់កាលចោទប្រកាន់

៣.៣ ដំណាក់កាលស៊ើបសួរ

៣.៤ ដំណាក់កាលជំនុំជម្រះ

៣.៥ ដំណាក់កាលក្រោយពេលសវនាការ

**សេចក្តីសន្និដ្ឋាន និង អនុសាសន៍**

# ជំពូកទី១
# អំពីមេធាវី

# ជំពូកទី១
# អំពីមេធាវី

## ១.១ ប្រវត្តិនៃការកកើត និងការវិវត្តវិជ្ជាជីវៈមេធាវី

នៅក្នុងឆ្នាំ១៩៣២ មានការណែនាំឲ្យស្គាល់ជាផ្លូវការនូវវិជ្ជាជីវៈមេធាវីនៅក្នុងប្រទេសកម្ពុជាដោយព្រះរាជក្រមប្រកាសលេខ៣២ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៣២ ហើយក្រោយមកត្រូវបានធ្វើវិសោធនកម្មដោយព្រះរាជក្រមលេខ ៦៤៨ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៥១។ ព្រះរាជប្រកាសលេខ៣២ បានណែនាំឲ្យស្គាល់អ្នកអនុវត្តវិជ្ជាជីវៈនេះដែលត្រូវបានហៅថា អ្នកថណាយក្តី។

វិជ្ជាជីវៈមេធាវីនៅកម្ពុជាបានទទួលរងនូវបញ្ហាដោយសារតែមានការផ្លាស់ប្តូររបបនយោបាយ និងសង្គមជាច្រើនដំណាក់កាលទើបធ្វើឲ្យវិជ្ជាជីវៈមួយនេះជួបប្រទះទៅនឹងផលប៉ះពាល់។ ចំពោះ សេវារបស់មេធាវី គឺមានការរីកចម្រើនដោយសារតែមានការរីកចម្រើនលើផ្នែកវិនិយោគសេដ្ឋកិច្ច សកម្មភាពពាណិជ្ជកម្ម ផលវិបាកនៃប្រព័ន្ធច្បាប់ និងនីតិវិធីរបស់តុលាការ រួមទាំងការកើតឡើងនៃសកម្មជាបទល្មើសនៅក្នុងសង្គមជាដើម។ សិទ្ធិក្នុងការទទួលបានការការពារផ្នែកច្បាប់បានដោយឯករាជ្យ ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ ក្នុងឆ្នាំ១៩៤៧ ប្រទេសកម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញទី១ របស់ខ្លួនដែលបានទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូបហើយការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនអាចធ្វើទៅបានលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការចាប់ខ្លួនត្រូវផ្អែកតាមនីតិវិធីដែលកំណត់នៅក្នុងច្បាប់ហើយមានមូលដ្ឋានជាក់លាក់ និងត្រូវបានសម្រេចដោយស្ថាប័នតុលាការ។ រដ្ឋធម្មនុញបានទទួលស្គាល់នូវសិទ្ធិជាមូលដ្ឋានផ្សេងទៀតរបស់មនុស្ស។ លើសពីនេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ បានចែងពីសិទ្ធិរបស់ជនគ្រប់រូបក្នុងការការពារខ្លួនតាមផ្លូវតុលាការ។[1] ក្រោយមក សិទ្ធិជាមូលដ្ឋានក៏ត្រូវបានលុបចោលអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាបានបាត់បង់នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ របបខ្មែរក្រហម បានធ្វើឲ្យមានការដាក់ទណ្ឌកម្ម និងប្រហារជីវិត យកមកអនុវត្តដោយស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការដែលពុំមានការជំនុំជម្រះតាមផ្លូវតុលាការនោះឡើយ។ ការចាត់តាំង មេធាវីបានចាប់ផ្តើមបន្ទាប់ពីមានការបង្កើតតុលាការ ខេត្តក្រុង បដិវត្តន៍ប្រជាជនក្នុង

[1] មាត្រា ៦ នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២

ឆ្នាំ១៩៧៩។[2] តុលាការកំពូលក្នុងឆ្នាំ១៩៨៥ និងសាលាឧទ្ធរណ៍ក្នុងឆ្នាំ១៩៩២។ លុះដល់ឆ្នាំ១៩៩២ មានការជួយពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា ក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត បទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌ និងច្បាប់យុត្តាធិការព្រមទាំងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តក្នុងអំឡុងពេលអន្តរកាលដែលមានឈ្មោះថា បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាលដែលគេហៅកាត់ថា (ច្បាប់ព្រហ្មទណ្ឌអន្តរកាល)។ ច្បាប់ព្រហ្មទណ្ឌអន្តរកាល បានផ្តល់នូវលទ្ធភាពក្នុងការបង្កើតគណៈមេធាវី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការមានមេធាវីជាតំណាង រួមទាំងការពារសិទ្ធិនៅក្នុងដំណើរការជំនុំជម្រះក្តី។[3] អំឡុងពេលអន្តរកាល បុគ្គលដែលមានសញ្ញាបត្រស្មើនឹងសញ្ញាបត្រនីតិសាស្ត្រ ឬមានបទពិសោធន៍ ៥ឆ្នាំក្នុងវិស័យច្បាប់ ឬវិស័យតុលាការអាចឲ្យអនុវត្តវិជ្ជាជីវៈមេធាវី។ សិទ្ធិក្នុងការទទួលបានការតំណាង និងការពារសិទ្ធិជនជាប់ចោទនៅក្នុងដំណើរការជំនុំជម្រះក្តី មិនមែនមានតែក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ នោះទេ ប៉ុន្តែរដ្ឋធម្មនុញ្ញទី៥នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក៏បានបញ្ជាក់ ទទួលស្គាល់សិទ្ធិនេះផងដែរ។[4] រដ្ឋធម្មនុញ្ញ បានទទួលស្គាល់សិទ្ធិមូលដ្ឋានរបស់មនុស្សដូចដែលបានប្រកាសនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ និងអនុសញ្ញា កតិកាសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដ៏ទៃទៀត។[5] ម្យ៉ាងវិញទៀត សិទ្ធិមានមេធាវីក៏មានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ផងដែរ។[6]

ទោះបីសិទ្ធិទទួលបានការការពារ និងមានការបង្កើតនូវវិជ្ជាជីវៈមេធាវីត្រូវបានទទួលស្គាល់ក៏ដោយ មេធាវីមិនអនុញ្ញាតឲ្យអនុវត្តវិជ្ជាជីវៈ ដែលមានលក្ខណៈឯកជននៅក្រៅតុលាការឡើយនៅពេលដែលគ្មានច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មានន័យថាមេធាវីអាចធ្វើត្រឹមតែជាអ្នកការពារក្តីប៉ុណ្ណោះ។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានអនុម័តចប់សព្វគ្រប់ដោយរដ្ឋសភានៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ ហើយត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៨៩៥/០៦ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។ គណៈមេធាវីនៃព្រះរាជាណាចក្រ-

[2] ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៥ តុលាការមានតែ១ថ្នាក់ប៉ុណ្ណោះ គឺតុលាការខេត្តក្រុង ហើយសេចក្តីសម្រេចតុលាការត្រូវមានការពិនិត្យពីក្រសួងយុត្តិធម៌ និងបើរកឃើញថាមានកំហុសនោះសេចក្តីសម្រេចនឹងត្រូវបញ្ជូនទៅក្រុមប្រឹក្សារដ្ឋដើម្បីសម្រេចជាលើកចុងក្រោយយោងតាមច្បាប់ស្តីពីការរៀបចំតុលាការ។

[3] មាត្រា ៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

[4] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

[5] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

[6] មាត្រា ៧៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣

កម្ពុជា ត្រូវបានបង្កើតឡើង និងដំណើរការជាផ្លូវការនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ តាមរយមហាសន្និបាតលើកទី១ របស់ខ្លួនដែលនៅក្នុងនោះរួមមានវត្តមានមេធាវីចំនួន៣០ រូប ដែលត្រូវប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសជាប្រធានគណៈមេធាវី សម្រាប់ដឹកនាំគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ ក្រោយមក ចំនួនមេធាវីត្រូវបានកើនឡើងដែលស្របតាមតម្រូវការក្នុងសង្គមដើម្បីធានាការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្សដែលធានាឲ្យបាននូវយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប ថែមទាំងពង្រឹងវិស័យយុត្តិធម៌ក្នុងសង្គមកម្ពុជា។ យើងសង្កេតឃើញថាពីមួយឆ្នាំទៅមួយឆ្នាំ ចំនួនមេធាវីមានការ កើនឡើងគួរឲ្យកត់សម្គាល់ជាខ្លាំង នៅអំឡុងឆ្នាំ២០១៦ មេធាវីពេញសិទ្ធិដែលប្រកបវិជ្ជាជីវៈមានចំនួន៨៧៨ រូបចំណែកមេធាវីដែលមិនប្រកបវិជ្ជាជីវៈមានចំនួន៥៩ រូប មេធាវីដែលត្រូវបានហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈមានចំនួន២ រូប ហើយមេធាវីដែលត្រូវផ្អាកពីមុខងារជាបណ្តោះអាសន្នមានចំនួន៣ រូប និងមេធាវីកម្មសិក្សាមានចំនួន១៧៤រូប។[7] គិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ នេះចំនួនមេធាវីសរុបបានកើនឡើងរហូតទៅដល់ ២៣៣៤ រូប។[8]

## ១.២ សារៈសំខាន់ និងតម្លៃរបស់មេធាវីនៅក្នុងសង្គម

យោងតាមមាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានចែងថា វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌។ វិជ្ជាជីវៈមេធាវី ប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវីតែប៉ុណ្ណោះ។

ជាក់ស្តែងនៅក្នុងសង្គម តួនាទីជាមេធាវីមិនត្រឹមតែជាអ្នកតំណាង និងជួយការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានតួនាទីសំខាន់ក្នុងការបង្កើតវិធានច្បាប់ក្នុងសង្គមផងដែរ។ លើសពីនេះ មេធាវីជាបុគ្គលមួយរូបដែលអាចផ្តល់ការប្រឹក្សាយោបល់ក៏ដូចជាគំនិតល្អៗដោយស្របតាមមូលដ្ឋានច្បាប់លើគ្រប់វិស័យ។ មេធាវីក៏ចូលរួមក្នុងក្របខណ្ឌគតិយុត្តនៃការវិនិយោគ និងការពារផលប្រយោជន៍របស់វិនិយោគិនដែលជាផ្នែកមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ជាតិ។

ដោយសារតែមេធាវីដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមជាតិ ទើបការអនុវត្តវិជ្ជាជីវៈមួយនេះត្រូវបានគ្រប់គ្រងដោយវិធានគតិយុត្ត និងសីលធម៌វិជ្ជាជីវៈ។ វិធានទាំងនេះ មានអត្ថប្រយោជន៍ដោយធានាបាននូវប្រកួតប្រជែងដោយភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរទៅដល់មេធាវីទាំងអស់។ ចំពោះទំនាក់ទំនងសហភាតាមេធាវី ត្រូវប្រព្រឹត្តដោយសេចក្តីថ្លៃថ្នូរ សម្បជញ្ញៈ ភាពទៀងត្រង់ មនុស្សធម៌ ស្មារតីឯករាជ្យជាមួយ

[7] សៀវភៅវិជ្ជាជីវៈមេធាវីក្នុងសង្គមកម្ពុជា ដោយ មេធាវី ប៊ុន ហុន ឆ្នាំ២០១៦

[8] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីស្ថិតិមេធាវីៈ https://www.bakc.org.kh/index.php/km/2020-02-02-04-06-24

ទេពកោសល្យ និងគោរពវិធានវិជ្ជាជីវៈរបស់ខ្លួន។ វិជ្ជាជីវៈមេធាវី មានលក្ខណៈសេរីខុសពីវិជ្ជាជីវៈសេរីដ៏ទៃដូចជា វិជ្ជាជីវៈវេជ្ជសាស្ត្រ គណនេយ្យ និងវិស្វករជាដើម។ វិជ្ជាជីវៈមេធាវីមានគោលការណ៍ និងតម្លៃរបស់ខ្លួនដាច់ដោយឡែកដែលបានបង្ហាញនៅលើនិមិត្តសញ្ញានៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះនិមិត្តសញ្ញាព្រះវិស្ណុតំណាងឲ្យអាទិទេពការពារពិភពលោកប្រឆាំងនឹងបិសាច និមិត្តសញ្ញាព្រះវិស្ណុកាន់វត្ថុផ្សេងៗដោយដៃទាំងប្រាំបី វត្ថុនីមួយៗតំណាងឲ្យតម្លៃផ្សេងៗគ្នា។ តម្លៃនៃដៃនីមួយៗមានសារៈសំខាន់ក្នុងការអនុវត្តវិជ្ជាជីវៈដោយសេរី និងឯករាជ្យ។ មេធាវីទទួលបាននូវបុព្វសិទ្ធិ និងសេរីភាពពេញលេញក្នុងការបញ្ចេញមតិនៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួនដើម្បីការពារផលប្រយោជន៍ផ្នែកច្បាប់របស់អតិថិជន។ មេធាវីមានកាតព្វកិច្ចអនុវត្តវិជ្ជាជីវៈរបស់ខ្លួនដែលប្រកបដោយ សេចក្តីថ្លៃថ្នូរ សម្បជញ្ញៈ សុចរិត មនុស្សធម៌ និងឯករាជ្យ ដែលមានចែងក្នុងក្រមសីលធម៌មេធាវី ។

## ១.៣ ក្របខណ្ឌបទដ្ឋានគតិយុត្តនៃវិជ្ជាជីវៈមេធាវី

វិជ្ជាជីវៈមេធាវីត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពី លក្ខន្តិកៈមេធាវី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ បទបញ្ជាផ្ទៃក្នុងគណៈមេធាវីដែលត្រូវបានសម្រេចអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវីនាសម័យប្រជុំថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ និងក្រមសីលធម៌មេធាវីដែលបានសម្រេចអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវីហើយត្រូវបានតែងតាំង និងសម្រេចអនុម័តជាថ្មីនាសម័យប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ព្រមទាំងបទប្បញ្ញត្តិ និង សេចក្តីសម្រេចដ៏ទៃទៀតដែលចេញដោយក្រុមប្រឹក្សាគណៈមេធាវី។

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បង្កើតឲ្យមាននូវរចនាសម្ព័ន្ធ និងកិច្ចដំណើរការនៃវិជ្ជាជីវៈមេធាវី បានផ្តល់អំណាចផ្តាច់មុខដល់គណៈមេធាវីក្នុងការគ្រប់គ្រងវិជ្ជាជីវៈ។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានបញ្ញត្តិពី តួនាទីរបស់មេធាវី តួនាទីរបស់ប្រធាន និងក្រុមប្រឹក្សាគណៈមេធាវី ការជ្រើសតាំងប្រធាន និងក្រុមប្រឹក្សាគណៈមេធាវី អាណត្តិរបស់ប្រធាន និងក្រុមប្រឹក្សាគណៈមេធាវីរចនាសម្ព័ន្ធនៃមហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ វិធាន និងលក្ខខណ្ឌក្នុងការអនុវត្តវិជ្ជាជីវៈមេធាវីក្នុងព្រះរាជាណាចក្រកម្ពុជាមានងារជាមេធាវីកិត្តិយស ទណ្ឌកម្មជាបទវិន័យ ការកំណត់កម្រៃ វិជ្ជាជីវៈរបស់មេធាវី ការបង់ភាគទានចូលទៅក្នុងមូលនិធិនៃគណៈមេធាវីគណនេយ្យ និងធានារ៉ាប់រងការទទួលខុសត្រូវរបស់មេធាវីក្នុងការប្រកបវិជ្ជាជីវៈ។

បទបញ្ជាផ្ទៃក្នុងគណៈមេធាវីបានកំណត់នូវវិធានដែលរួមមាន វិធានវិជ្ជាជីវៈមេធាវី មហាសន្និបាតគណៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវី ជំនួយសង្គ្រោះតាមផ្លូវតុលាការ មជ្ឈមណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈ

មេធាវី ការរៀបចំកម្មសិក្សា ការគ្រប់គ្រងមូលនិធិ និង ប្រាក់តម្កល់ទុក កាតព្វកិច្ច គណនេយ្យ និង ការត្រួតពិនិត្យ។ ក្រមសីលធម៌មេធាវីបានកំណត់នូវវិធានទូទៅទីលំនៅវិជ្ជាជីវៈ និងកន្លែងពិគ្រោះយោបល់ ការផ្សព្វផ្សាយមេធាវី និងអតិថិជន ទំនាក់ទំនងជាមួយភាគីម្ខាងទៀត និងសាក្សី ទំនាក់ទំនងជាមួយសហភាតា និងសមាជិកនៃវិជ្ជាជីវៈប្រហាក់ប្រហែកគ្នា និងទំនាក់ទំនងជាមួយគណៈមេធាវី។

## ១.៤ លក្ខខណ្ឌ និងនីតិវិធីចូលប្រកបវិជ្ជាជីវៈ

ដើម្បីអាចក្លាយជាមេធាវី និងចូលប្រកបវិជ្ជាជីវៈមេធាវីបានបេក្ខជនត្រូវគោរពតាមលក្ខខណ្ឌមាត្រា៣១នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ យោងតាមមាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានចែងថាជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបានត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិជាខ្មែរ
- ត្រូវមានបរិញ្ញាបត្រច្បាប់ ឬសញ្ញាបត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល។
- ត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។ វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីត្រូវចេញដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះត្រូវបានកំណត់ដោយអនុក្រឹត្យ។
- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជាបទល្មើសរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការដកហូតងារពីអំពើផ្ទុយកិត្តិយសឬអំពើមិនស្អាតស្អំ។
- មិនត្រូវធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។
- មិនចាំបាច់មានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាបត្រច្បាប់៖
  - ✓ ចៅក្រម ដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី៥ឆ្នាំ និងអតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ ហើយបានបម្រើការក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី២ឆ្នាំ។
- មិនចាំបាច់មានវិញ្ញាបនបត្រខាងវិជ្ជាជីវៈមេធាវី ៖
  - ✓ អ្នកមានបរិញ្ញាបត្រច្បាប់ហើយបានបម្រើការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ឆ្នាំ
  - ✓ មេធាវីដែលមានសញ្ជាតិដើមខ្មែរដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
  - ✓ អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់។[៩]

[៩] មាត្រា ៣១ និងមាត្រា៣២ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

ដូចនេះយោងតាមមាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានបង្ហាញពីលក្ខខណ្ឌ និងមធ្យោបាយចំនួនពីរដែលអាចចូលប្រកបវិជ្ជាជីវៈមេធាវីបាន។ ចំពោះមធ្យោបាយទី១ គឺតាមរយៈការប្រឡងចូលមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីទទួលបានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនិងមធ្យោបាយទី២គឺតាមរយៈសម្បថដោយត្រូវគោរពទៅតាមលក្ខខណ្ឌមួយចំនួនដូចដែលបានបញ្ជាក់ខាងលើ។

### ១.៤.១ តាមរយៈការប្រឡងចូលប្រកបវិជ្ជាជីវៈមេធាវី

បេក្ខជនដែលអាចចូលប្រកបវិជ្ជាជីវៈមេធាវីបានគឺត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីដែលវិញ្ញាបនបត្រនេះត្រូវចេញដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។[10] មួយវិញទៀត ដើម្បីទទួលបានវិញ្ញាបនបត្រនេះចាំបាច់ត្រូវធ្វើការប្រឡងចូលមជ្ឈមណ្ឌល និងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

#### ១.៤.១.១ លក្ខខណ្ឌ

ដើម្បីអាចប្រឡងចូល និង ទទួលបានការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីបានបេក្ខជនត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានបរិញ្ញាបត្រច្បាប់ ឬសញ្ញាបត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមាមូល។
- ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។ វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះត្រូវចេញឲ្យប្រើដោយមជ្ឈមណ្ឌលនេះត្រូវកំណត់ដោយអនុក្រឹត។
- មិនដែលត្រូវផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជារដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ។ មិនត្រូវមានក្ស័យធនផ្ទាល់ខ្លួនប្រកាសដោយតុលាការ។[11]

#### ១.៤.១.២ ការប្រឡង

ការប្រឡងជ្រើសរើសសិស្សមេធាវីត្រូវប្រព្រឹត្តទៅតាមនីតិវិធីដែលមានការកំណត់ចំនួនសិស្ស មេធាវីកម្មវិធីបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងការប្រឡងយកវិញ្ញាបនបត្រសម្បទាវិជ្ជាជីវៈមេធាវីត្រូវតែពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។[12] ការប្រឡងត្រូវបានបែងចែកជា២ដំណាក់កាលផ្សេងគ្នាដំណាក់កាល

---

[10] មាត្រា ៣១ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

[11] មាត្រា ៣១ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

[12] មាត្រា ៦ នៃអនុក្រឹត្យស្តីពី ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ទី១គឺវិញ្ញាសារសរសេរ និងដំណាក់កាលទី២គឺវិញ្ញាសារផ្ទាល់មាត់មានន័យថានៅពេលដែលបេក្ខជនជាប់វិញ្ញាសារសរសេរហើយត្រូវឆ្លងកាត់វិញ្ញាសារផ្ទាល់មាត់។ ក្នុងករណីដែលបេក្ខជនជាប់លើវិញ្ញាសារផ្ទាល់ បេក្ខជនបានប្រឡងជាប់ជាស្ថាពរហើយត្រៀមខ្លួនដើម្បីចូលរៀន ឬទទួលការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលវិជ្ជាជីវៈ។

#### ១.៤.១.៣ ការចុះកម្មសិក្សា

បន្ទាប់ពីបានបញ្ចប់ការសិក្សានៅមជ្ឈមណ្ឌលហើយនោះ ក្រុមប្រឹក្សាគណៈមេធាវីនឹងធ្វើការពិនិត្យ មើលលក្ខខណ្ឌដែលបេក្ខជនបានបំពេញ និងធ្វើការសម្រេចចំពោះការអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈក្រោយពេលដែលមានយោបល់ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ លើសពីនេះមេធាវីដែលត្រូវទទួលឲ្យប្រកបវិជ្ជាជីវៈត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ដោយមានវត្តមានប្រធានគណៈមេធាវី។

ចំពោះមេធាវីដែលទើបទទួលបានការចុះឈ្មោះត្រូវធ្វើកម្មសិក្សារយៈពេល១ឆ្នាំ ក្នុងរយៈពេលនោះត្រូវទទួលបានការបំប៉នបន្ថែមទៀត ស្ថិតក្រោមការរៀបចំដោយគណៈមេធាវី និងត្រូវបម្រើការងារក្នុងការិយាល័យមេធាវីណាមួយ ស្ថិតក្រោមការគ្រប់គ្រងរបស់មេធាវីណាម្នាក់ដែលត្រូវបានចាត់តាំងឲ្យទទួលបន្ទុកកម្មសិក្សាដោយគណៈមេធាវី។

### ១.៤.២ តាមរយៈសម្បថចូលប្រកបវិជ្ជាជីវៈមេធាវី

#### ១.៤.២.១ លក្ខខណ្ឌ

តាមរយៈការស្នើសុំប្រកបវិជ្ជាជីវៈមេធាវីមិនចាំបាច់មានវិញ្ញាបនបត្រវិជ្ជាជីវៈមេធាវី និងបរិញ្ញាបត្រច្បាប់ឡើយ ប៉ុន្តែការស្នើសុំនេះត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចតទៅ៖

- ករណីគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈមេធាវី និង បរិញ្ញាបត្រច្បាប់
  - ចៅក្រម ដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ឆ្នាំ
  - អតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ និងបានបម្រើការក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី២ឆ្នាំ។
- ករណីគ្មានវិញ្ញាបនបត្រខាងវិជ្ជាជីវៈមេធាវី
  - អ្នកដែលមានបរិញ្ញាបត្រច្បាប់ និងបម្រើការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ឆ្នាំ
  - មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែរបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
  - អ្នកដែលមានសញ្ញាបត្របណ្ឌិតច្បាប់។[13]

[13] មាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

### ១.៤.២.២ ការដាក់ពាក្យសុំ

បុគ្គលដែលមានបំណងចង់ស្នើសុំប្រកបវិជ្ជាជីវៈមេធាវី ហើយបានបំពេញតាមលក្ខខណ្ឌនៃមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវធ្វើការទាក់ទងទៅការិយាល័យរដ្ឋបាលនៃគណៈមេធាវីរាល់ម៉ោងធ្វើការ។

ម្យ៉ាងវិញទៀតការដាក់ពាក្យសុំតម្រូវឲ្យបង់ថ្លៃលើពាក្យសុំ ដោយសារតែការកំណត់ទម្រង់ពាក្យសុំ និង តម្លៃនៃពាក្យសុំនេះគឺជាការកំណត់ដែលធ្វើឡើងដោយគណៈមេធាវីផ្ទាល់។[14] បន្ទាប់ពីបំពេញពាក្យសុំរួចរាល់ ហើយនោះ ត្រូវយកពាក្យសុំទៅដាក់នៅការិយាល័យរដ្ឋបាលនៃគណៈមេធាវីដោយត្រូវភ្ជាប់ជាមួយឯកសារមួយចំនួនដូចជា៖

- ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី យោងតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- ប្រវត្តិរូបសង្ខេបសាមីខ្លួន
- លិខិតបញ្ជាក់ថ្កោលទោសដែលមានសុពលភាព
- ឯកសារចាំបាច់ផ្សេងទៀតដែលកំណត់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

### ១.៤.២.៣ ការដាក់ពាក្យសុំធ្វើកម្មសិក្សា

បន្ទាប់ពីគណៈមេធាវីបានពិនិត្យ និងបញ្ជូនឯកសារពាក្យសុំទៅក្រុមអធិការកិច្ចហើយក្រុមអធិការកិច្ច ត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងរយៈពេលយូរបំផុតត្រឹម ៣០ថ្ងៃហើយត្រូវធ្វើរបាយការណ៍អធិការកិច្ច និងបញ្ជូន របាយការណ៍នោះទៅកាន់ប្រធាននាយកដ្ឋានអធិការកិច្ចដើម្បីត្រួតពិនិត្យវាយតម្លៃ មុននឹងបញ្ជូនទៅប្រធាន គណៈមេធាវី។ បើរបាយការណ៍មានលក្ខណៈត្រឹមត្រូវគ្រប់គ្រាន់ហើយនោះប្រធានគណៈមេធាវីត្រូវកំណត់ពេល ដើម្បីធ្វើការសម្ភាសន៍បេក្ខជនផ្ទាល់ក្នុងរយៈពេល ៣០ ថ្ងៃ។[15] នៅពេលដែលការសម្រេចរបស់ក្រុមប្រឹក្សា គណៈមេធាវីបានបោះឆ្នោតសម្រេចយល់ព្រមចំពោះសំណើនោះដោយមានសម្លេងគាំទ្រភាគច្រើននោះបញ្ជាក់ថា បេក្ខជនទទួលបានការអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈជាស្ថាពរ។ បន្ទាប់ពីបេក្ខជនចូលប្រកបវិជ្ជាជីវៈហើយត្រូវធ្វើ សច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍ និងត្រូវដាក់ពាក្យសុំធ្វើកម្មសិក្សាដើម្បីចុះកម្មសិក្សារយៈពេល ១២ ខែ។ របាយការណ៍បញ្ចប់ការសិក្សាដាក់ឲ្យគណៈមេធាវីធ្វើការត្រួតពិនិត្យ និងសម្រេចពីការអនុញ្ញាត ឬ មិន អនុញ្ញាតឲ្យក្លាយជាមេធាវីពេញសិទ្ធិ ។

[14] ប្រការ ៦ នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី យោងតាមមាត្រា៣២

[15] ប្រការ១៤ នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី យោងតាមមាត្រា៣២

## ១.៥ ក្រមសីលធម៌ក្នុងការប្រកបវិជ្ជាជីវៈមេធាវី

ការប្រកបវិជ្ជាជីវៈមេធាវីត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌មេធាវី និងគោរពតាមគោលការណ៍ដែលត្រូវអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

### ១.៥.១ ឯករាជ្យភាព និងសេរីភាពនៃវិជ្ជាជីវៈមេធាវី

វិជ្ជាជីវៈមេធាវីគឺជា វិជ្ជាជីវៈមួយដែលឯករាជ្យ និងសេរីហើយជាវិជ្ជាជីវៈមួយដែលបង្កើតឡើងដើម្បីចូលរួមបម្រើវិស័យយុត្តិធម៌ និងពង្រឹងនីតិរដ្ឋ ហើយវិជ្ជាជីវៈមេធាវី អាចប្រព្រឹត្តទៅបានតែក្នុងក្របខណ្ឌនៃគណៈមេធាវីប៉ុណ្ណោះ។[16] វិជ្ជាជីវៈមេធាវី ស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គណៈមេធាវីដែលជាស្ថាប័នឯករាជ្យមិនស្ថិតក្រោមគណៈបក្សនយោបាយណាមួយ អង្គការសាសនាណាមួយ និងអង្គការផ្សេងទៀតទេ។[17] វិជ្ជាជីវៈមេធាវី មានលក្ខណៈឯករាជ្យព្រោះការអនុវត្តវិជ្ជាជីវៈនេះមិនស្ថិតក្រោមបញ្ជា ឬការណែនាំពីបុគ្គលណាម្នាក់ ឬស្ថាប័នណាមួយឡើយ។ ចំពោះការផ្តល់សេវាកម្មច្បាប់មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិជាធរមាន និងវិធានវិជ្ជាជីវៈដែលបានបំពេញការងារតាមបច្ចេកទេស ជំនាញរបស់ខ្លួនដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជនដោយមិនស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលណា ឬស្ថាប័នណាមួយឡើយ។ តួនាទីមេធាវីគឺអនុវត្តវិជ្ជាជីវៈរបស់ខ្លួនដោយផ្អែកលើជំនាញដែលមានរៀងៗខ្លួន យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវីដោយមិនត្រូវអនុវត្តវិជ្ជាជីវៈតាមរយៈការបង្ខិតបង្ខំទទួលឥទ្ធិពលពីសំណាក់ជនណាមួយឡើយ។ មេធាវីមានសេរីភាពក្នុងការប្រកបវិជ្ជាជីវៈដោយឯករាជ្យ និងសេរីភាពពេញលេញក្នុងការផ្តល់សេវាកម្ម ឬមិនផ្តល់ជូនដល់អតិថិជនសេរីភាពលើការកំណត់កម្រៃសេវា និងសេរីភាពក្នុងការជ្រើសរើសមធ្យោបាយសម្រាប់បំពេញការងារ។ កម្រៃដែលអតិថិជនផ្តល់ជូនដល់មេធាវីគឺស្ថិតនៅលើការព្រមព្រៀងរវាងអតិថិជន និងមេធាវីផ្ទាល់តែម្តងមិនមានការកំណត់ដោយលិខិតបទដ្ឋានណាមួយ ដែលបានកំណត់អត្រាកម្រៃសេវារបស់មេធាវីនោះទេ។ លើសពីនេះមេធាវីមានសិទ្ធិសេរីភាពការពារបុគ្គល និងជួយពង្រឹងវិស័យយុត្តិធម៌ក្នុងសង្គមជាតិ។ ក្នុងករណីមេធាវីប្រព្រឹត្តអំពើបំពាននឹងវិជ្ជាជីវៈមេធាវីនាំឲ្យមេធាវីត្រូវទទួលទណ្ឌកម្មពីក្រុមប្រឹក្សាគណៈមេធាវី។

[16] មាត្រា ១ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

[17] មាត្រា ១៣ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

### ១.៥.២. តម្លៃសីលធម៌នៃវិជ្ជាជីវៈមេធាវី

#### ១.៥.២.១ សញ្ញាណទូទៅ

ជាគោលការណ៍តួនាទីជាមេធាវី ត្រូវប្រតិបត្តិឲ្យបានខ្ជាប់ខ្ជួននូវពាក្យសម្បថ និងគោរពសម្បជញ្ញៈ មនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ។ មេធាវី ត្រូវអនុវត្តវិជ្ជាជីវៈប្រកបដោយ សេចក្តីថ្លៃថ្នូរ មនុស្សធម៌ សេចក្តីទៀងត្រង់ ឯករាជ្យដោយគោរពតាមរដ្ឋធម្មនុញ្ញ និងបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា។ មេធាវីមិនត្រូវចូលរួមសកម្មភាពណាដែលមានលក្ខណៈផ្ទុយច្បាប់ វិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនឡើយ។

មេធាវីក៏ត្រូវតែគោរពប្រតិបត្តិតាមគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់។[18] ម្យ៉ាងវិញទៀត មេធាវីក៏មានបេសកកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋ ជួយពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។[19]

#### ១.៥.២.២ ការទទួលរឿងក្តី

មេធាវីមានសិទ្ធិទទួល ឬមិនទទួលជួយអតិថិជនលើកលែងតែត្រូវចាត់តាំងដោយប្រធានគណៈមេធាវី។ មេធាវីអាចទទួលរឿងក្តីតាមរយៈកូនក្តីផ្ទាល់ ឬតតិយជនដោយប្រធានគណៈមេធាវី។ ករណីមេធាវីព្រមទទួលយកបេសកកម្មមេធាវី ត្រូវបំពេញបេសកកម្មដោយយកចិត្តទុកដាក់រហូតដល់ពេលចប់បេសកកម្ម លើកលែងតែអតិថិជនឈប់ពឹងពាក់មេធាវី។ បន្ទាប់មកមេធាវីត្រូវធ្វើការប្រឹក្សាយោបល់ និងពន្យល់ពីលក្ខខណ្ឌនីតិវិធីនៃរឿងក្តីដំណោះស្រាយការចំណាយលើសេវា និងកម្រៃផ្សេងទៀតផ្អែកលើព័ត៌មានដែលទទួលបានពីអតិថិជន។ ដើម្បីទទួលបានការគោរពពីអតិថិជនក្នុងការបំពេញបេសកកម្មរបស់ខ្លួនមេធាវីត្រូវស្ថិតជាម្ចាស់ដោយមានមធ្យោបាយការពារ និងមិនត្រូវផ្តល់ការធានាណាមួយចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ។[20] ចំពោះការងារការពារក្តីជូនជនក្រីក្រ មេធាវីទទួលការពារក្តីទៅតាមការចាត់តាំងរបស់គណៈមេធាវី។ មេធាវីទាំងអស់មានកាតព្វកិច្ចជួយការពារក្តីជូនជនក្រីក្រតាមរយៈការចាត់តាំងរបស់ប្រធានគណៈមេធាវី និងត្រូវយកចិត្តទុកដាក់ការពារក្តីដូចនឹងការការពារក្តីជូនអតិថិជនរបស់ខ្លួនដែរ។[21]

#### ១.៥.២.៣ ការប្រុងប្រយ័ត្ន

ករណីមេធាវីព្រមទទួលរឿងក្តីរបស់អតិថិជន មេធាវីត្រូវគិតពីផលប្រយោជន៍របស់អតិថិជនឲ្យដូចជាផលប្រយោជន៍របស់ខ្លួនដែរ។ ហេតុនេះ មេធាវីត្រូវប្រើប្រាស់នូវសមត្ថកិច្ច និងជំនាញវិជ្ជាជីវៈដែលខ្លួនមានទាំង

---

[18] មាត្រា ៣៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងមាត្រា៣ និង ៦នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២

[19] មាត្រា ៤ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[20] មាត្រា ២២ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[21] មាត្រា ២៩ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

អស់ដើម្បីបំពេញកិច្ចការដែលអតិថិជនបានពឹងពាក់ប្រកបដោយការប្រុងប្រយ័ត្ន។ ផ្ទុយទៅវិញ ករណីដែលមានការធ្វេសប្រហែស អតិថិជនអាចប្ដឹងមេធាវីចំពោះការខូចខាតបាន។ ឧទាហរណ៍៖ អតិថិជនបានពឹងពាក់មេធាវីឲ្យរៀបចំធ្វើបណ្ដឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលាដំបូងដែលខ្លួនមិនសុខចិត្ត ប៉ុន្តែដោយសារមេធាវីធ្វើឲ្យមានកំហុសមិនបានរៀបចំប្ដឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលាដំបូង ក្នុងអំឡុងពេលដែលច្បាប់កំណត់ បណ្ដាលឲ្យអតិថិជនទទួលរងនូវការខូចខាតផលប្រយោជន៍ស្របច្បាប់របស់ខ្លួនមេធាវី ត្រូវទទួលខុសត្រូវលើការខូចខាត។ ហេតុនេះ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីតម្រូវឲ្យមេធាវីបង់ប្រាក់ធានារ៉ាប់រងសម្រាប់ធានាការទទួលខុសត្រូវទៅលើវិជ្ជាជីវៈរបស់ខ្លួនដើម្បីការពារផលប្រយោជន៍របស់អតិថិជន។[22]

### ១.៥.២.៤ សុចរិតភាព និងភាពស្មោះត្រង់

មេធាវីត្រូវផ្ដល់ទំនុកចិត្ត និងភាពជឿជាក់ក្នុងការធ្វើរឿងក្ដីជូនដល់អតិថិជនខ្លួនជាសំខាន់។ ទោះបីជាយ៉ាងណា មេធាវីមិនអាចធ្វើការធានាជាមួយអតិថិជនចំពោះលទ្ធផលនៃរឿងក្ដីបានឡើយ ប៉ុន្តែត្រូវខិតខំក្នុងការបំពេញបេសកកម្មរបស់ខ្លួនធ្វើយ៉ាងណាឲ្យអស់ពីសមត្ថភាព។ ករណីមេធាវីចង់បញ្ចប់ការងារមុនពេលកំណត់នោះមេធាវីត្រូវជូនដំណឹងទៅអតិថិជនខ្លួនអំពីការបញ្ឈប់ ឬដកខ្លួនពីការបំពេញការងារនៅក្នុងពេលមួយដែលសមស្របដើម្បីផ្ដល់លទ្ធភាពជូនដល់អតិថិជនក្នុងការការពារផលប្រយោជន៍ខ្លួន និងមានពេលគ្រប់គ្រាន់ស្វែងរកមេធាវីផ្សេងទៀតឲ្យជួយការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។[23] មេធាវីមិនត្រូវប្រើឧបាយកលណាមួយដើម្បីទាញផលប្រយោជន៍ក្នុងស្ថានភាព ដែលអតិថិជនមិនមានចំណេះដឹងផ្នែកច្បាប់ឡើយ។ មួយវិញទៀត មេធាវីត្រូវគោរពប្រតិបត្តិនូវគោលការណ៍សុចរិត និងភាពស្មោះត្រង់។[24]

### ១.៥.២.៥ ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ

មេធាវីត្រូវដឹងពីកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ ករណីមានការបំពានវិធានដែលពាក់ព័ន្ធនឹងការសម្ងាត់វិជ្ជាជីវៈអាចនាំឲ្យមេធាវីទទួលនូវទណ្ឌកម្មជាបទពិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើស និងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវីទោះបីប្រព្រឹត្តក្រៅពី

[22] មាត្រា ៧៣ នៃច្បាប់ស្ដីពី លក្ខន្តិកៈមេធាវី

[23] មាត្រា ២៩ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[24] មាត្រា ២៦ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

ការប្រកបវិជ្ជាជីវៈខ្លួនក៏ដោយ។[25] មួយវិញទៀតការបំពានវិធានពាក់ព័ន្ធនឹងការសម្ងាត់វិជ្ជាជីវៈក៏អាចប្រឈមនឹងការផ្តន្ទាទោសព្រហ្មទណ្ឌផងដែរ។[26]

មេធាវីមិនអាចបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាចបង្ខំឲ្យបំពានលើការសម្ងាត់វិជ្ជាជីវៈរបស់ខ្លួន បើទោះបីជានៅចំពោះមុខតុលាការ។ ជាពិសេសការសម្ងាត់មិនអាចឲ្យជនណាម្នាក់ស្រង់យកបានឡើយទោះបីជាអតិថិជនក៏ដោយ។ ឧទាហរណ៍៖ មេធាវីមិនអាចនិយាយអង្គហេតុនៃរឿងក្តីរបស់អតិថិជនប្រាប់ទៅមិត្តភក្តិ គ្រួសារ ប្រព័ន្ធផ្សព្វផ្សាយ ឬជនណាម្នាក់ឡើយ។ ត្រូវចាត់ទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ ការផ្តល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយដែលមេធាវីតាក់តែងឡើងសម្រាប់អតិថិជនរបស់ខ្លួនលិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួនផ្ញើទាក់ទងគ្នា។[27] ការរក្សាការសម្ងាត់វិជ្ជាជីវៈជួយការពារដល់ផលប្រយោជន៍កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អតិថិជនខ្លួន។ កាតព្វកិច្ចរបស់មេធាវីក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ គឺជាកាតព្វកិច្ចក្នុងចំណោមកាតព្វកិច្ចដទៃទៀតដែលបានចងភ្ជាប់ទៅនឹងកាតព្វកិច្ចមានភាពស្មោះត្រង់ជាមួយអតិថិជន។ ក្រៅពីនេះការបំពេញកាតព្វកិច្ចទាំងនេះបានផ្តល់ទំនុកចិត្តដល់អតិថិជនក្នុងការជឿជាក់លើមេធាវី និងជួយសម្របសម្រួលដល់ការធ្វើទំនាក់ទំនងគ្នារវាងអតិថិជន និងមេធាវី។ ករណីមេធាវីត្រូវធ្វើការឆ្លើយតបនឹងបណ្តឹងអតិថិជនខ្លួននោះ មេធាវីមិនមានកាតព្វកិច្ចរក្សាការសម្ងាត់ទេប៉ុន្តែស្ថិតក្នុងកម្រិតនៃការចាំបាច់ការពារខ្លួនប៉ុណ្ណោះ។

### ១.៥.២.៦ ទំនាស់ផលប្រយោជន៍ និង ការហាមឃាត់

គោលបំណងការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជន មេធាវីត្រូវបានហាមឃាត់ក្នុងការធ្វើជាមេធាវីការពារ ឬតំណាងឲ្យអតិថិជនក្នុងករណីដូចតទៅ៖

– រឿងក្តីមួយដែលមេធាវីខ្លួនឯង ឬក្រុមមេធាវីរបស់ខ្លួន បានជួយបដិភាគីនៅក្នុងការផ្តល់យោបល់ ឬទទួលយល់ព្រមតំណាងឲ្យបដិភាគីរួចហើយ

– ពេលដែលផលប្រយោជន៍អតិថិជនម្នាក់មានទំនាស់ជាមួយផលប្រយោជន៍របស់អតិថិជនម្នាក់ទៀតនៅក្នុងរឿងក្តីដែលមេធាវី ឬក្រុមមេធាវីរបស់ខ្លួនកំពុងតែកាន់

– ករណីអតិថិជនទាំងពីរជាភាគីវិវាទក្នុងរឿងក្តីតែមួយ

[25] មាត្រា ៥៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[26] មាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[27] មាត្រា ៧ នៃក្រមសីលធម៌គណៈមេធាវី ឆ្នាំ២០១២

– នៅពេលអតិថិជនម្នាក់ចង់ពឹងពាក់មេធាវី ឬក្រុមមេធាវីរបស់ខ្លួនតែមេធាវី ឬក្រុមមេធាវីនេះធ្លាប់ទទួលជួយបដិភាគីក្នុងរឿងដទៃ ឬមេធាវីបានយល់ព្រមផ្តល់យោបល់ផ្នែកច្បាប់បន្តទៀតលើកលែងតែរឿងក្តីចុងក្រោយដែលមេធាវី ឬក្រុមមេធាវីធ្លាប់ពាក់ព័ន្ធបានកន្លងផុតក្នុងរយៈពេល ២ឆ្នាំ។

– រឿងក្តីដែលមេធាវី ឬក្រុមមេធាវីរបស់ខ្លួនបានដើរតួជាអាជ្ញាកណ្តាលអ្នកផ្សះផ្សា ឬសម្របសម្រួលក្នុងទម្រង់នីតិវិធីនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។ ករណីមេធាវី ឬក្រុមមេធាវីជាទីប្រឹក្សា ឬធ្លាប់ជាទីប្រឹក្សារបស់អតិថិជនច្រើនគ្នានៅមេធាវីអាចទទួលការពារផលប្រយោជន៍ភាគីណាមួយបាន លុះត្រាតែបានជម្រាបជូនដំណឹងទៅភាគីផ្សេងទៀត និងបន្ទាប់ពីទទួលបានការយល់ព្រមជាមុន ហើយត្រូវតែប្រុងប្រយ័ត្នមិនឲ្យបាត់បង់ភាពថ្លៃថ្នូរ កិត្តិយស និងការសម្ងាត់វិជ្ជាជីវៈ។

ដើម្បីធានាបានការការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជន ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានហាមឃាត់មិនឲ្យមេធាវី ដែលធ្លាប់ជាអតីតមន្ត្រីរាជការធ្វើបទអន្តរាគមន៍ការពារកូនក្តីប្រឆាំងនឹងក្រសួងមន្ទីររដ្ឋបាលដែលខ្លួនស្ថិតក្រោមឱវាទពីមុន។ មេធាវីអាចធ្វើជាតំណាង ឬការពារកូនក្តីប្រឆាំងនឹង ក្រសួងមន្ទីររដ្ឋបាល ដែលខ្លួនធ្លាប់ស្ថិតនៅក្រោមឱវាទបានលុះត្រាតែផុតរយៈពេល ៥ ឆ្នាំគិតចាប់ពីថ្ងៃដែលឈប់ពីមុខងាររបស់ខ្លួន។[28] មេធាវីមិនត្រូវផ្តល់ព័ត៌មានក្លែងក្លាយ ឬបន្លំបោកប្រាស់ ឬអួតអាងពីសេវាកម្មរបស់ខ្លួន ដើម្បីធ្វើការផ្សព្វផ្សាយទាក់ទាញអតិថិជនឡើយ។[29] មេធាវី អាចធ្វើការផ្សព្វផ្សាយអំពីសេវាកម្មនៃការិយាល័យមេធាវីរបស់ខ្លួនតាមរយៈទំនាក់ទំនងជាលាយលក្ខណ៍អក្សរ សារអេឡិចត្រូនិក រួមទាំងប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈដោយមានការអនុញ្ញាតពីក្រុមប្រឹក្សា។

### ១.៥.៣ ការបង់ភាគទាន

មូលនិធិគណៈមេធាវីត្រូវបានបង្កើតឡើងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលមានឈ្មោះថាភាគទានគណៈមេធាវី។[30] ការអនុវត្តជាក់ស្តែងជំនួយផ្នែកច្បាប់នៅកម្ពុជាត្រូវបានបែងចែកជា៣ផ្នែកគឺ៖

(១) រាល់សមាជិកគណៈមេធាវីត្រូវបង់ភាគទានជារៀងរាល់ឆ្នាំទៅឲ្យមូលនិធិគណៈមេធាវី។

(២) រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ថវិកាជំនួយផ្នែកច្បាប់ជារៀងរាល់ឆ្នាំ

---

[28] មាត្រា ៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ២០១២

[29] មាត្រា ១៥ នៃក្រមសីលធម៌គណៈមេធាវី ឆ្នាំ២០១២

[30] មាត្រា ២៩ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

(៣) ជំនួយផ្នែកច្បាប់ផ្សេងទៀតក៏ត្រូវបានផ្តល់ដោយវិស័យឯកជន អង្គការ ឬរដ្ឋាភិបាលបរទេស។ មូលនិធិរបស់គណៈមេធាវី ត្រូវបានប្រើប្រាស់សម្រាប់សកម្មភាព និងតម្រូវការរបស់គណៈមេធាវីសម្រាប់ឧបត្ថម្ភទៅឲ្យមេធាវីដែលបានការពារក្តីជូនប្រជាពលរដ្ឋក្រីក្រ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានផ្តល់មេធាវីដើម្បីការពារ និង លើកកម្ពស់សិទ្ធិមនុស្ស ឬផ្តល់ជំនួយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។ មិនត្រឹមតែប៉ុណ្ណោះ ជំនួយផ្នែកច្បាប់នេះអាចការពារពីការធ្វើទណ្ឌកម្មក្នុងអំឡុងពេលឃុំខ្លួន និងកាត់បន្ថយការផ្តន្ទាទោសដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់។[31]

គណៈមេធាវីមានឯករាជ្យផ្នែករដ្ឋបាល និងស្វ័យភាពហិរញ្ញវត្ថុដាច់ដោយឡែកពីស្ថាប័នរដ្ឋាភិបាលទាំងឡាយ។ គណៈមេធាវី មិនស្ថិតនៅចំណុះឲ្យអំណាចសាធារណៈ និងមិនប្រើប្រាស់ថវិកាជាតិដូចស្ថាប័នសាធារណៈដទៃទៀតឡើយ។ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវី មេធាវីទាំងអស់ដែលបច្ចុប្បន្នកំពុងមានឈ្មោះក្នុងបញ្ជីរាល់ត្រីមាសដោយត្រូវបង់នៅបំណាច់ត្រីមាសនីមួយៗ។ មេធាវីម្នាក់ៗត្រូវបង់ភាគទានឲ្យបានទាន់ពេលវេលាដែលបានកំណត់។ មេធាវីណាដែលមិនបានបង់ភាគទានត្រូវទទួលទណ្ឌកម្មជាបទវិន័យតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។[32]

[31] តួនាទីមេធាវី និងភារកិច្ចរបស់មេធាវីនៅកម្ពុជាបោះពុម្ពដោយវិទ្យាស្ថានសភាកម្ពុជា

[32] មាត្រា ៥៥ នៃក្រមសីលធម៌គណៈមេធាវីឆ្នាំ២០១២

# ជំពូកទី២
# សិទ្ធិ និងករណីយកិច្ចរបស់មេធាវី

# ជំពូកទី២
# សិទ្ធិ និង ករណីយកិច្ចរបស់មេធាវី

## ២.១ ករណីយកិច្ចរបស់មេធាវី

គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពី តួនាទីរបស់មេធាវីនៅកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការធានានីតិរដ្ឋ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ មេធាវីមិនត្រូវស្ថិតនៅក្រោមការរឹតត្បិត ឬជ្រៀតជ្រែកណាមួយឡើយ។ ក្នុងការបំពេញមុខងាររបស់ខ្លួន មេធាវីនៅកម្ពុជាដើរតួជាអ្នកបកស្រាយច្បាប់ក៏ដូចជាពន្យល់ពីអត្ថន័យ និងសារៈសំខាន់នៃច្បាប់ទាំងនោះទៅកាន់ប្រជាពលរដ្ឋ។ លើសពីនេះទៀតក្នុងករណីដែលច្បាប់ណាមួយមិនបានឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋ មេធាវីក៏អាចផ្តល់ជាជំនួយក្នុងការប្រឹក្សាដើម្បីធ្វើការកែសម្រួលច្បាប់នោះដែរ។ នៅក្នុងដំណើរការច្បាប់ មេធាវីអាចផ្តល់ជាជំនួយដល់ សមាជិកសភានូវបទពិសោធន៍ និងការប្រឹក្សាយោបល់ទាក់ទងទៅនឹងការអនុវត្តច្បាប់ខណៈពេលដែលមេធាវីមានតួនាទីការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងការដាក់ពាក្យបណ្តឹង ប្រសិនបើអាជ្ញាធរណាមួយរំលោភច្បាប់។

ជាទូទៅនៅក្នុងការអនុវត្តន៍ការងាររបស់មេធាវី មេធាវីគឺត្រូវពិចារណាអំពីភារកិច្ច ៣ សំខាន់ៗដែលភារកិច្ចទាំងនោះរួមមាន៖ ភារកិច្ចចំពោះវិជ្ជាជីវៈមេធាវីផ្ទាល់ ចំពោះអតិថិជន និង ចំពោះតុលាការ។

ករណីយកិច្ច និងសិទ្ធិទាំងនេះមានចែងនៅក្នុង គោលការណ៍ណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពី តួនាទីរបស់មេធាវីកម្ពុជាឆ្នាំ១៩៩០ លក្ខន្តិកៈមេធាវីកម្ពុជា ក្រមសីលធម៌សំរាប់មេធាវី និងនៅក្នុងច្បាប់នីតិវិធីផងដែរ។

### ២.១.១ ករណីយកិច្ចចំពោះវិជ្ជាជីវៈ

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌។ វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី។[33] នៅគ្រប់កាលៈទេសៈមេធាវីត្រូវរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួនថាជាទីភ្នាក់ងារដ៏សំខាន់នៃរដ្ឋបាលយុត្តិធម៌។[34]

មេធាវី ត្រូវចេះរក្សាកេរ្តិ៍ឈ្មោះ និងភាពបិតថេរនៃវិជ្ជាជីវៈ ហើយមិនត្រូវជ្រើសរើសវិជ្ជាជីវៈមេធាវីព្រោះតែវិជ្ជាជីវៈនេះអាចធ្វើឲ្យខ្លួនមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់ មានឥទ្ធិពល និង អាចមានប្រាក់ចំណូលច្រើននោះឡើយ។

[33] មាត្រា ១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ២០១២

[34] ប្រការ ១២ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីមេធាវី

មេធាវីត្រូវប្រកាន់ខ្ជាប់នូវបមាណីយ (កម្រិត)នៃការប្រព្រឹត្ត និងត្រូវចងចាំជានិច្ចថាខ្លួនត្រូវបម្រើសាធារណជនក្នុងការស្វែងរកយុត្តិធម៌។ មេធាវីម្នាក់អាចលើកកម្ពស់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួនបានដោយៈ

### ២.១.១.១ ការជ្រៀសវាងជាដាច់ខាតទំនាស់រវាងករណីយកិច្ចវិជ្ជាជីវៈ និង ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មេធាវី

មេធាវីត្រូវប្រកាន់ខ្ជាប់នៅផ្នត់គំនិតថា ផលប្រយោជន៍យុត្តិធម៌ត្រូវស្ថិតនៅពីលើផលប្រយោជន៍ដទៃទៀតទាំងអស់។ មេធាវីម្នាក់មិនអាចលាយឡំផលប្រយោជន៍ផ្ទាល់ខ្លួន តួនាទីនយោបាយ ឬតំណែងសាធារណៈរបស់ខ្លួនជាមួយការអនុវត្តន៍ច្បាប់បានឡើយ។ សកម្មភាពទាំងនេះនឹងមានទំនាស់ដោយស្វ័យប្រវត្តិជាមួយកាតព្វកិច្ចផ្លូវច្បាប់ព្រោះជាមេធាវីភារកិច្ចរបស់ខ្លួនគឺបម្រើវិស័យយុត្តិធម៌ និងផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។[35]

ដើម្បីឲ្យការងារបានល្អមេធាវីម្នាក់គួរតែតំណាងចុងចោទម្នាក់ នៅក្នុងរឿងក្តីមួយដែលមានចុងចោទច្រើនពីព្រោះចុងចោទម្នាក់ៗ មានវិធីសាស្ត្រការពារ និងប្រយោជន៍រៀងៗខ្លួន។[36] មេធាវីត្រូវតែចៀសវាងឲ្យបាននូវទំនាស់ផលប្រយោជន៍ដើម្បីឲ្យកូនក្តីរបស់ខ្លួនទទួលបានការកាត់ក្តីដោយយុត្តិធម៌។

### ២.១.១.២ សហប្រតិបត្តិការរបស់មេធាវីជាមួយគណៈមេធាវី

សហប្រតិបត្តិការជាមួយគណៈមេធាវី ដែលជាសមាគមវិជ្ជាជីវៈមេធាវីមួយ និងមេធាវីទាំងអស់ត្រូវតែជាសមាជិកនៃគណៈមេធាវី។[37]

មេធាវី មានកាតព្វកិច្ចគោរពឲ្យបានដាច់ខាតនូវបម្រាមនៃការផ្សាយពាណិជ្ជកម្ម ពីព្រោះការផ្សាយពាណិជ្ជកម្មជ្រុលហួសហេតុអាចបណ្តាលឲ្យមានអ្នកយល់ខុស ហើយអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈមេធាវីដែលមិនមែនជាពាណិជ្ជកម្ម ឬអាជីវកម្មណាមួយនោះឡើយ ប៉ុន្តែជាសេវាមួយដែលបម្រើដល់វិស័យយុត្តិធម៌។[38] មួយវិញទៀត មេធាវីគឺជាវិជ្ជាជីវៈមួយដែលមានលក្ខណៈឯករាជ្យ និងសេរីហើយត្រូវបានបង្កើតឡើងដើម្បីចូលរួមបម្រើវិស័យយុត្តិធម៌វិជ្ជាជីវៈនេះអាចប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវីតែប៉ុណ្ណោះ យោងតាមមាត្រា១ នៃច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ។

[35] មាត្រា ៥៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[36] មាត្រា ១៩ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[37] មាត្រា៤ និង មាត្រា៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[38] មាត្រា ៥៧ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

### ២.១.២ ករណីយកិច្ចចំពោះអតិថិជន

ក្នុងករណីយកិច្ចចំពោះអតិថិជន មេធាវីត្រូវតែបំពេញតួនាទីដើម្បីជាប្រយោជន៍របស់អតិថិជនដោយសេចក្តីក្លាហាន ស្មោះត្រង់ និងដោយបញ្ចេញឲ្យអស់នូវចំណេះដឹង និងសមត្ថភាពរបស់ខ្លួនស្របតាមច្បាប់ ព្រោះមេធាវីជាអ្នកតំណាងឲ្យកូនក្តី។ មេធាវីប្រើចំណេះដឹងនឹងជំនាញដើម្បីការពារកូនក្តីនៅចំពោះមុខតុលាការ។ តាមរយៈការផ្តល់សេវាច្បាប់ និងកសាងជំនឿទុកចិត្តដល់កូនក្តី មេធាវីត្រូវ៖

(ក) ពិភាក្សាជាមួយកូនក្តីពាក់ព័ន្ធទៅនឹងរឿងក្តី

(ខ) ស្វែងរកអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធ

(គ) ផ្តល់នូវដំបូន្មានដល់កូនក្តីអំពីសិទ្ធិរបស់ពួកគេ និង

(ឃ) រៀបចំឯកសារ និងការពារកូនក្តីក្នុងពេលជម្រះក្តី។ ការធ្វើបែបនេះវាជួយឲ្យមេធាវី និងអតិថិជនមានទំនុកចិត្ត និងការចុះហត្ថលេខាលើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ស្តីពីថ្លៃចំណាយលើការធ្វើជាតំណាងផ្លូវច្បាប់។[39]

ទំនាក់ទំនងរវាងមេធាវី និងអតិថិជន គឺជាទំនាក់ទំនងតាមកិច្ចសន្យា ហើយកិច្ចសន្យានោះមានប្រភពពីទំនៀមទម្លាប់ និងពីការព្រមព្រៀងគ្នាទៅវិញទៅមក។ មេធាវីគឺជាអ្នកតំណាងការពារ និងតំណាងឲ្យអតិថិជន។ ទំនាក់ទំនងរវាងមេធាវី និងអតិថិជន កើតមាននៅពេលជនណាម្នាក់ បង្ហាញពីបំណងចង់ឲ្យមេធាវីផ្តល់សេវាកម្មផ្នែកច្បាប់ហើយមេធាវីនោះយល់ព្រមយោងតាមមាត្រា១៨ នៃក្រមសីលធម៌មេធាវី។

ចំពោះការរក្សាការសម្ងាត់វិជ្ជាជីវៈ មេធាវីគ្រប់រូបមានកាតព្វកិច្ចរក្សាការសម្ងាត់ជូនអតិថិជនរបស់ខ្លួនជាដាច់ខាតស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ មេធាវីមិនត្រូវបង្ហាញការសម្ងាត់របស់អតិថិជនខ្លួនឡើយលើកលែងតែមានការជូនដំណឹង និងយល់ព្រមពីអតិថិជន ឬកាលណាមានការអនុញ្ញាតដោយច្បាប់ ឬដោយយោងតាមមាត្រា១៩ នៃច្បាប់ស្តីពីក្រមសីលធម៌មេធាវី។

ការទាក់ទងជាមួយអតិថិជនត្រូវធ្វើដោយចំពោះ និងផ្ទាល់ខ្លួន។ មេធាវីមិនអាចទទួលរឿងមួយតាមរយៈតតិយជនបានឡើយ បើខ្លួនគ្មានសេរីភាពនឹងចូលទាក់ទងផ្ទាល់ខ្លួនជាមួយអតិថិជនដែលមានរឿងនោះបាន។ វិធាននេះអាចមិនត្រូវប្រតិបត្តិតាមបាន កាលណាមេធាវីដើរតួជាអ្នកឆ្លើយឆ្លងរបស់មេធាវីម្នាក់ទៀតយោងតាមមាត្រា២៤ នៃច្បាប់ស្តីពីក្រមសីលធម៌មេធាវី។

[39] មាត្រា ៦៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

### ២.១.៣ ករណីយកិច្ចចំពោះតុលាការ

ចំពោះតុលាការតួនាទីចម្បងរបស់មេធាវី គឺការជួយឲ្យតុលាការសម្រេចបានយុត្តិធម៌ស្របតាមច្បាប់។ អាស្រ័យហេតុដូចនេះ មេធាវីមិនត្រូវដឹកនាំតុលាការឲ្យដើរផ្លូវខុស ឬបង្ហាញនូវភស្តុតាងដែលខ្លួនដឹងថាក្លែងក្លាយទោះបីជាការធ្វើបែបនេះអាចជាប្រយោជន៍ដល់អតិថិជនក៏ដោយ។ ផ្ទុយទៅវិញ មេធាវីក៏ពុំត្រូវបង្ហើបប្រាប់តុលាការនូវការពិតទាំងឡាយណាដែលមិនស្ថិតក្នុងផលប្រយោជន៍របស់អតិថិជនឡើយ។ ទោះបីជាការពិតទាំងនេះបានបង្ហាញពីពិរុទ្ធភាពរបស់អតិថិជនក៏ដោយ។

មេធាវីត្រូវណែនាំខ្លួនជូនចៅក្រម ចំពោះរឿងក្តីដែលខ្លួនការពារ ឬតំណាងដោយអាណត្តិ។ មេធាវីត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវឯករាជ្យភាព និងសេចក្តីថ្លៃថ្នូរក្នុងវិជ្ជាជីវៈនៅចំពោះមុខតុលាការ។ មេធាវីត្រូវគោរពតាមវិធាននីតិវិធី និងបទបញ្ជារបស់តុលាការ។ មេធាវីមិនត្រូវប្រើជាដាច់ខាតនូវវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់គ្នា។ មេធាវីមានសិទ្ធិសម្តែងឡើងនូវអ្វីៗដែលខ្លួនយល់ថាមានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន។

មេធាវីត្រូវរួចផុតពីការចោទប្រកាន់ក្នុងព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះសេចក្តីថ្លែងការណ៍ឬសារណា ទោះធ្វើជាលាយលក្ខណ៍អក្សរក្តី ជាផ្ទាល់មាត់ក្តី ក្នុងបំណងសុចរិតដើម្បីការពារនៅចំពោះមុខតុលាការ សាលាជម្រះក្តី ឬអាជ្ញាធរផ្សេងៗទៀត។ ក្នុងករណីមានទំនាស់ជាមួយចៅក្រមពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ឬសារណា មេធាវីត្រូវសុំអន្តរាគមន៍ពីប្រធានគណៈមេធាវីភ្លាមដោយយោងតាម មាត្រា ៣៧ នៃក្រមសីលធម៌មេធាវី។

## ២.២ សិទ្ធិរបស់មេធាវី

### ២.២.១ អំពីសិទ្ធិ

ក្នុងការបំពេញមុខវិជ្ជាជីវៈមេធាវីត្រូវតែទទួលបាននូវសិទ្ធិគ្រប់គ្រាន់ដើម្បីការពារខ្លួនពីបទចោទ ឬគំនាបណាមួយ។ សិទ្ធិដូចរៀបរាប់តទៅនេះមានចែងនៅក្នុង " គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី " ។

#### ២.២.១.១ សិទ្ធិក្នុងការបំពេញវិជ្ជាជីវៈដោយគ្មានការរើសអើង

ក្នុងការបំពេញមុខងារវិជ្ជាជីវៈរបស់ខ្លួន មេធាវីត្រូវតែទទួលបាននូវសិទ្ធិគ្រប់គ្រាន់ដើម្បីការពារខ្លួនពីបទចោទ ឬការដាក់គំនាបណាមួយ។ ការធានាឲ្យបានថាគ្រប់ការបំពេញវិជ្ជាជីវៈរបស់មេធាវីត្រូវតែគ្មានការជ្រៀតជ្រែកនឹងទទួលបានសិទ្ធិក្នុងការប្រកបវិជ្ជាជីវៈ។ ដើម្បីធានាឲ្យបាននូវសិទ្ធក្នុងការបំពេញមុខវិជ្ជាជីវៈដោយគ្មានការជ្រៀតជ្រែកនោះរាជរដ្ឋាភិបាលត្រូវធានាថាមេធាវីទាំងអស់៖

ក) មានសមត្ថភាពបំពេញមុខងារវិជ្ជាជីវៈគ្រប់ប្រភេទរបស់ខ្លួនដោយគ្មានការបំភ័យ ការយាយី ឬការជ្រៀតជ្រែកមិនសមស្រប។

ខ) មានសមត្ថភាពធ្វើដំណើរ និងពិគ្រោះយោបល់ជាមួយអតិថិជនរបស់ខ្លួនដោយសេរី ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។

គ) មិនត្រូវរងទុក្ខ ឬទទួលការគំរាមកំហែងដោយការកាត់ទោស ឬទណ្ឌកម្មរដ្ឋបាល សេដ្ឋកិច្ច ឬទណ្ឌកម្មដទៃទៀត ចំពោះសកម្មភាពណាមួយដែលត្រូវបានធ្វើឡើងស្របទៅតាមករណីយកិច្ច បទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ឡើយ។

ប្រសិនបើមេធាវីណាម្នាក់បានទទួលរងនូវអំពើអយុត្តិធម៌ពីសំណាក់ចៅក្រមណាម្នាក់ មេធាវីអាចដាក់ពាក្យបណ្តឹងទៅប្រធានតុលាការ ទៅប្រធានគណៈមេធាវី ឬ ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដោយផ្ទាល់ដែលអាចធ្វើអន្តរាគមន៍បាន។[40] មេធាវីថែមទាំងអាចជំទាស់ដល់ចៅក្រម ក្នុងការធ្វើសេចក្តីសម្រេចបានទៀតផងប្រសិនបើសញ្ញានៃការវិនិច្ឆ័យជាមុន ឬការបោកបញ្ឆោត ឬការរារាំង។

### ២.២.១.២ សិទ្ធិក្នុងការទទួលបានការការពារ

មេធាវីមានសិទ្ធិធ្វើការនៅក្នុងបរិយាកាសសុវត្ថិភាពមួយ ដោយគ្មានការភ័យខ្លាចដោយសារការគំរាមកំហែង និង ការបង្ខិតបង្ខំ។ ប្រសិនបើសន្តិសុខរបស់មេធាវីត្រូវបានគំរាមកំហែងដោយសារការបំពេញមុខងាររបស់ខ្លួនមេធាវីត្រូវទទួលបានការការពារគ្រប់គ្រាន់ពីអាជ្ញាធរ។[41]

### ២.២.១.៣ សិទ្ធិទទួលបានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌ

មេធាវី ត្រូវតែមានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌសម្រាប់សេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយសេចក្តីស្មោះត្រង់នៅក្នុងចម្លើយថាព្រមទទួល ឬមិនព្រមទទួលជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់នៅក្នុងការបង្ហាញខ្លួនចំពោះមុខតុលាការ សាលាក្តី ឬច្បាប់ ឬអាជ្ញាធររដ្ឋបាលដទៃទៀត។[42] មេធាវីមិនត្រូវបានអនុញ្ញាតឲ្យធ្វើការភូតកុហកដោយចេតនាក្នុងនាមជាកូនក្តីរបស់ខ្លួនដើម្បីឈ្នះក្តីនោះទេ ។

### ២.២.១.៤ សិទ្ធិក្នុងការតំណាងកូនក្តី

មេធាវី ស្វយ័ត និងជ្រើសរើសកូនក្តីរបស់ខ្លួនបានដោយសេរី។ មេធាវី អាចបដិសេធក្នុងការធ្វើជាអ្នកតំណាងកូនក្តីនៅក្នុងករណីណាមួយក៏បាន ក៏ប៉ុន្តែមេធាវីអាចទទួលធ្វើជាតំណាងកូនក្តីបានដោយសេរី។ មេធាវីអាចតំណាងកូនក្តីណាម្នាក់ដោយមានការយល់ព្រមពីកូនក្តីនោះ។ ការបដិសេធក្នុងការធ្វើជាតំណាងកូនក្តីមាន

[40] មាត្រា២៤ ប្រយោគទី៤ នៃក្រមសីលធម៌សំរាប់មេធាវី

[41] ប្រការ ១៧ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី

[42] ប្រការ ២០ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី

តម្លៃស្មើគ្នានឹងការបដិសេធន៍នូវសិទ្ធិក្នុងការបញ្ចេញមតិនៅចំពោះមុខតុលាការ។[43] ម្យ៉ាងវិញទៀត តុលាការមិនអាចបដិសេធមេធាវីមិនឲ្យតំណាងកូនក្តីបានទេ ប្រសិនបើមេធាវីសម្រេចចិត្តតំណាងដោយមានការយល់ព្រមពីកូនក្តីនោះ។ តុលាការត្រូវគោរពសេចក្តីសម្រេចចិត្តរបស់កូនក្តី។ បើមិនដូច្នោះទេតុលាការអាចជ្រៀតជ្រែកដោយខុសច្បាប់ដែលចូលក្នុងសិទ្ធិមនុស្សរបស់មេធាវីក្នុងការអនុវត្តន៍វិជ្ជាជីវៈរបស់មេធាវី។[44]

### ២.២.១.៥ សិទ្ធិក្នុងការទទួលបានកូនក្តី និងព័ត៌មានចាំបាច់សម្រាប់ការពារកូនក្តី

ប្រការ៥ និង ៧ នៃ "គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី" បានចែងពីសិទ្ធិរបស់ជនជាប់ចោទដែលត្រូវស្វែងរកជំនួយពីអ្នកការពារក្តី រដ្ឋាភិបាលត្រូវធានាថាអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងជាបន្ទាន់ដល់ជនគ្រប់រូបអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានជំនួយពីមេធាវី តាមការជ្រើសរើសរបស់ពួកគេនៅពេលឃាត់ខ្លួន ឬឃុំឃាំង ឬនៅពេលដែលត្រូវបានចោទពីបទល្មើសណាមួយ។[45] រដ្ឋាភិបាលត្រូវធានាបន្ថែមថាជនគ្រប់រូបដែលត្រូវឃាត់ខ្លួន ឬឃុំឃាំង ដោយមាន ឬគ្មានការចោទពីបទល្មើសណាមួយ គឺត្រូវមានលទ្ធភាពជាបន្ទាន់ក្នុងការស្វែងរកមេធាវី ហើយនៅក្នុងករណីណាក៏ដោយមិនត្រូវឲ្យលើសពីរយៈពេល៤៨ម៉ោង ក្រោយការឃាត់ខ្លួន ឬការឃុំឃាំងឡើយ។[46]

### ២.២.១.៦ សិទ្ធិមិនត្រូវសម្តែងមានសមានចិត្តជាមួយកូនក្តី

មេធាវីមិនត្រូវសម្តែងថាមានសមានចិត្តជាមួយកូនក្តី ឬបុព្វហេតុរបស់កូនក្តីក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។[47] ការងាររបស់មេធាវីសម្រាប់កូនក្តីមិនគួរត្រូវបានមើលឃើញថា ជាការបង្ហាញថាមេធាវីមានចិត្តជាមួយ ឬយល់ព្រមជាមួយទង្វើរបស់កូនក្តីឡើយ ។

### ២.២.១.៧ សិទ្ធិក្នុងការទទួលបានការសម្ងាត់ផ្នែកវិជ្ជាជីវៈមេធាវី

មេធាវី ក៏ដូចជាវេជ្ជបណ្ឌិតដែរ មេធាវីអាចទទួលបាននូវទំនាក់ទំនងជាសម្ងាត់ជាមួយនឹងអតិថិជនរបស់ខ្លួន។ មធ្យោបាយណាមួយដែលប្រែក្លាយការសន្ទនារវាងមេធាវីនឹងកូនក្តីរបស់គាត់ឲ្យបើកចំហរ គឺជាមធ្យោបាយដែលផ្ទុយនឹងច្បាប់។ ការចម្លងឯកសារ ឬការថតសម្លេងដោយសម្ងាត់ គឺអាចជាកម្មវត្ថុនៃការដាក់ទណ្ឌកម្ម។ មេធាវីក៏មិនត្រូវបានគេបង្ខំឲ្យធ្វើការបើកកកាយអំពីការប្រាស្រ័យទាក់ទងរបស់ខ្លួនជាមួយនិងកូនក្តីខ្លួននោះទេ។

---

[43] មាត្រា ៣៩ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

[44] មាត្រា ៦ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

[45] ប្រការ ៥ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី

[46] ប្រការ ៧ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់

[47] ប្រការ ១៨ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី

រដ្ឋាភិបាលត្រូវទទួលស្គាល់ និង គោរពថារាល់ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់រវាងមេធាវី និងកូនក្តីរបស់ពួកគេនៅក្នុងទំនាក់ទំនងវិជ្ជាជិវៈរបស់ពួកគេគឺជាការសម្ងាត់។[48]

### ២.២.១.៨ សិទ្ធិទទួលបានការអប់រំ និងការបណ្តុះបណ្តាល

រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវី និងគ្រឹះស្ថានសិក្សាត្រូវធានាថាមេធាវីមានការអប់រំ និងការបណ្តុះបណ្តាលសមស្រប និងមេធាវីត្រូវយល់ច្បាស់អំពីឧត្តមគតិ ករណីកិច្ចផ្នែកសីលធម៌របស់មេធាវី និងករណីយកិច្ចនៃសិទ្ធិមនុស្សព្រមទាំងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ។[49] ជាការពិតណាស់នៅក្នុងឆ្នាំ២០០២ គណៈមេធាវីកម្ពុជាបានបង្កើត "មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី" សម្រាប់អនុវត្តកម្មវិធីចូលជាមេធាវីក្នុងការចេញអាជ្ញាប័ណ្ណដល់មេធាវីថ្មីនៅក្នុងប្រទេសកម្ពុជា។ មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវីនេះត្រូវបានបើកឡើងជាផ្លូវការនៅចុងខែតុលា ឆ្នាំ២០០២ដោយមានសិស្សពូកែចំនួន ៦០នាក់ ដែលផ្តោតលើការសរសេរកិច្ចសន្យា ជំនាញក្នុងការទំនាក់ទំនង ការចរចា និងការសម្រុះសម្រួល និងច្បាប់ពាណិជ្ជកម្ម។

### ២.២.១.៩ សិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ និង ការបង្កើតសមាគម

មេធាវី ក៏ដូចជាពលរដ្ឋដទៃទៀតដែរ មេធាវីក៏មានសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ ជំនឿ ការបង្កើតសមាគម និងការប្រមូលផ្តុំគ្នា។ លើសពីនេះទៀត មេធាវីមានសិទ្ធិក្នុងការចូលរួមក្នុងការពិភាក្សាជាសាធារណៈអំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់រដ្ឋបាលនៃវិស័យយុត្តិធម៌ និងការលើកកម្ពស់ ការពារសិទ្ធិមនុស្ស និងក្នុងការចូលរួម ឬបង្កើតអង្គការក្នុងស្រុក ឬអង្គការអន្តរជាតិព្រមទាំងចូលរួមកិច្ចប្រជុំដោយគ្មានការទទួលរងនូវការដាក់កំហិតផ្នែកវិជ្ជាជីវៈដោយសារសកម្មភាពស្របច្បាប់ ឬ សមាជិកភាពរបស់ពួកគេនៅក្នុងអង្គការស្របច្បាប់ណាមួយឡើយ។ ក្នុងការប្រើសិទ្ធិទាំងនេះមេធាវីត្រូវរៀបចំខ្លួនឲ្យបានសមស្របតាមច្បាប់ និងបទដ្ឋានព្រមទាំងសីលធម៌ដែលមេធាវីទទួលស្គាល់នៅក្នុងវិជ្ជាជីវៈមេធាវីរបស់ខ្លួន ។[50]

មេធាវីអាចចូលរួមនៅក្នុងអង្គការជាតិ ដែលជាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការអន្តរជាតិដើម្បីបង្កើតជារូបរាងសម្រាប់អនាគតនៃវិជ្ជាជីវៈមេធាវី។

## ២.៣ តួនាទី និង សារៈសំខាន់របស់មេធាវី

ក្នុងការបំពេញមុខងាររបស់ខ្លួន មេធាវីនៅកម្ពុជាដើរតួជាអ្នកបកស្រាយច្បាប់ ក៏ដូចជាពន្យល់ពីអត្ថន័យ និងសារៈសំខាន់នៃច្បាប់ទាំងនោះទៅកាន់ប្រជាពលរដ្ឋ។ លើសពីនេះទៀត ក្នុងករណីដែលច្បាប់ណាមួយមិន

[48] ប្រការ ២២ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី

[49] ប្រការ ៩ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី

[50] ប្រការ ២៣ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី

បានឆ្លើយតបនៅនឹងតម្រូវការរបស់ពលរដ្ឋ មេធាវីក៏អាចផ្តល់ជាជំនួយក្នុងការប្រឹក្សាដើម្បីធ្វើការកែសម្រួលច្បាប់នោះផងដែរ។ ក្រៅពីនេះ មេធាវីដើរតួនាទីជាតំណាងកូនក្តីរបស់ខ្លួននៅក្នុងដំណើរការតុលាការ និងតវ៉ាក្តីដើម្បីការពារសិទ្ធិរបស់កូនក្តីចំពោះមុខតុលាការ ។

### ២.៣.១ តួនាទីរបស់មេធាវី

#### ២.៣.១.១ សញ្ញាណទូទៅរបស់មេធាវី

មេធាវី មានតួនាទីក្នុងការពិគ្រោះយោបល់ ផ្តល់ប្រឹក្សា តំណាង ឬការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី រាប់បញ្ចូលទាំងរឿងព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ និងសង្គមកិច្ច។[51] មេធាវីក៏អាចជួយការពារកូនក្តីនៅចំពោះមុខក្រុមប្រឹក្សាវិន័យបានផងដែរ។ មេធាវីផ្តល់យោបល់ និងរៀបចំតាក់តែងលិខិតស្នាមគតិយុត្តផ្សេងៗ ព្រមទាំងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់សាធារណជនទូទៅ។ មេធាវី អាចត្រូវបានចាត់តាំងដោយកូនក្តី ឬចៅក្រមឲ្យបំពេញមុខងារជាអ្នកផ្សះផ្សា ឬជាអ្នកដែលសម្រុះសម្រួល ឬអាជ្ញាកណ្តាលក្នុងករណីដែលច្បាប់អនុញ្ញាត។[52] ដោយមានការពឹងពាក់ពីអតិថិជនមេធាវីក៏មានសិទ្ធិធ្វើជាតំណាងដោយអាណត្តិ និងការពារផលប្រយោជន៍ស្របច្បាប់ឲ្យអតិថិជននៅចំពោះមុខស្ថាប័នមានសមត្ថកិច្ចនានាផ្សេងទៀតផងដែរ។

#### ២.៣.១.២ តួនាទីរបស់មេធាវីក្នុងការផ្តល់ប្រឹក្សាផ្នែកច្បាប់

សម្រាប់ការផ្តល់ប្រឹក្សាផ្នែកច្បាប់ មេធាវីត្រូវតែយល់ឲ្យច្បាស់ពីអង្គហេតុ និងច្បាប់នានាដែលពាក់ព័ន្ធនឹងរឿងក្តីមុននឹងធ្វើការផ្តល់ប្រឹក្សាច្បាប់។ ដើម្បីយល់ឲ្យបានច្បាស់នូវអង្គហេតុមេធាវីគប្បីជម្រុញឲ្យអតិថិជនរៀបរាប់ហេតុការណ៍ឲ្យបានលម្អិតដែលពាក់ព័ន្ធនឹងអង្គហេតុ។ មេធាវីត្រូវកត់ត្រារាល់ចំណុចសំខាន់ទាំងអស់ដែលពាក់ព័ន្ធនឹងអង្គហេតុ ជាពិសេសអង្គហេតុចម្បងរបស់រឿងក្តីនីមួយៗបន្ទាប់ពីធ្វើការវិភាគលើអង្គហេតុមេធាវីត្រូវកំណត់ថាច្បាប់ណាខ្លះដែលគួរលើកយកមកអនុវត្ត និងថាតើមានបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដែរឬទេ ដើម្បីអោយមេធាវីអាចផ្តល់ប្រឹក្សាច្បាប់ត្រឹមត្រូវទៅកាន់អតិថិជនរបស់ខ្លួន។

#### ២.៣.១.៣ បេសកកម្មរបស់មេធាវី

មេធាវីជាតួអង្គមួយដែលចូលរួមបម្រើវិស័យយុត្តិធម៌ពោលគឺមេធាវីមានបេសកកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។[53] មេធាវីជាជំនួយការយុត្តិធម៌របស់សង្គមដែលជម្រុញឲ្យ

---

[51] មាត្រា ២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[52] មាត្រា ៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[53] មាត្រា ១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

មានយុត្តិធម៌ក្នុងដំណើរការនីតិវិធីរបស់ស្ថាប័នយុត្តាធិការ និងស្ថាប័នមានសមត្ថកិច្ច។ នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌប្រភេទខ្លះដូចជា រឿងក្តីនៃបទល្មើសឧក្រិដ្ឋ និង រឿងក្តីដែលមានអតិថិជនជាជនជាប់ចោទច្បាប់តម្រូវឲ្យមានមេធាវីជាចាំបាច់។[54]

[54] មាត្រា ៤ នៃក្រមសីលធម៌មេធាវី២០១២

# ជំពូកទី៣
# តួនាទីមេធាវីក្នុង
# ដំណាក់កាលសំខាន់ៗនៃនីតិវិធី

# ជំពូកទី៣
# តួនាទីមេធាវីក្នុងដំណាក់កាលសំខាន់ៗនៃនីតិវិធី

បណ្តឹង ជាអំណាចមួយដែលច្បាប់ទទួលស្គាល់សម្រាប់បុគ្គល ឬនីតិបុគ្គល ដែលប្តឹងទៅតុលាការដើម្បីទាមទារឲ្យមានការគោរពសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់បុគ្គល។[55] នៅក្នុងរឿងក្តីព្រហ្មទណ្ឌជនរងគ្រោះ អ្នកតំណាងស្របច្បាប់ ឬសិទ្ធិវ័ន្តរបស់ជនរងគ្រោះ អាចប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌[56] និងអយ្យការដែលទទួលចំណាត់ការលើពាក្យបណ្តឹងដែលខ្លួនបានទទួលដោយផ្ទាល់ ឬមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។

យោងតាមមាត្រា២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បណ្តឹងអាជ្ញា គឺជាបណ្តឹងដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់បានកំណត់។ បណ្តឹងអាជ្ញា មានគោលបំណងជួសជុលសណ្តាប់ធ្នាប់សាធារណៈ និងផ្តន្ទាទោសរាល់ការរំលោភច្បាប់ ចំណែកបណ្តឹងរដ្ឋប្បវេណី មានបំណងត្រឹមជួសជុលព្យសនកម្មដែលខ្លួនបានទទួលប៉ុណ្ណោះ។[57] បណ្តឹងអាជ្ញា តែងតែមានមូលដ្ឋានច្បាប់ដែលកំណត់ជាក់លាក់តាមច្បាប់ស្របតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ ក្នុងរឿងក្តីព្រហ្មទណ្ឌពេលជនណាម្នាក់បានប្រព្រឹត្តអំពើល្មើសណាមួយហើយមិនអាចសម្រុះសម្រួលបានឡើយ ជនល្មើសចាំបាច់ត្រូវទទួលទណ្ឌកម្មតាមបទបញ្ញត្តិច្បាប់ដែលបានកំណត់ទុកជាស្រេច បើមានការខូចខាតស្តួចស្តើងទណ្ឌកម្មក៏ត្រូវទទួលតាមនោះដែរ។ អង្គការអយ្យការ ជាស្ថាប័នមួយគត់ដែលរដ្ឋធម្មនុញ្ញទុកជាម្ចាស់នៃបណ្តឹងអាជ្ញាហើយបណ្តឹងអាជ្ញាមិនអាចធ្វើការសម្រួលបានឡើយទោះបីមានការដកពាក្យបណ្តឹងពីជនរងគ្រោះក៏ដោយ។ ម្យ៉ាងវិញទៀត បណ្តឹងអាជ្ញាអាចឈានដល់ការដាក់ទណ្ឌកម្មចំពោះជនបង្កឲ្យមានការអន្តរាយ និងស្តារឡើងវិញនូវសណ្តាប់ធ្នាប់សាធារណ ដែលអាចពិន័យជាប្រាក់ និងការដាក់ពន្ធនាគារ ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃកំហុសដែលអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពបុគ្គលជាខ្លាំង។ ជាគោលការណ៍ ជនដែលបំពានលើសិទ្ធិ និងផលប្រយោជន៍របស់ជនដទៃ បង្កឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ បើទោះបីមានលក្ខណៈជាសំភារៈ ឬស្មារតី គឺត្រូវទទួលខុសត្រូវនៅពេលដែលជននោះមានកំហុសពេលប្រព្រឹត្តអំពើអនីត្យានុកូល។[58]

---

[55] ដកស្រង់ពី ព្រឹត្តបត្រមេធាវីលេខ ២៥ ខែមេសា មិថុនា ឆ្នាំ២០២០

[56] មាត្រា ៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[57] មេរៀន នីតិវិធីព្រហ្មទណ្ឌ បង្រៀនដោយសាស្ត្រាចារ្យ មីន សំអុល ឆ្នាំ២០២០

[58] មេរៀន ស្តីពី អំពើអនីត្យានុកូល បង្រៀនដោយ លោកគ្រូ ហ៊ី សោភា ទំព័រ ៦៩

មួយវិញទៀត ពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើងបុគ្គលដែលបានប្រព្រឹត្តបទល្មើស ឬជនរងគ្រោះប្រាកដជាស្វែងរកអ្នកច្បាប់ដែលមានបទពិសោធន៍ច្បាស់លាស់នោះ គឺជាមេធាវីដើម្បីជួយពិគ្រោះយោបល់ផ្តល់ជាដំណោះស្រាយដែលល្អទាក់ទងនឹងរឿងក្តីដើម្បីស្វែងរកយុត្តិធម៌មកឲ្យខ្លួន ព្រោះរឿងក្តីព្រហ្មទណ្ឌអាចឈានដល់ការពិន័យជាប្រាក់ និងការឃុំខ្លួនដែលមានលក្ខណៈអាចប៉ះពាល់ដល់សេរីភាពបុគ្គល។ នៅគ្រប់រឿងក្តីទាំងអស់មេធាវីមានកាតព្វកិច្ចជួបពិភាក្សាផ្តល់យោបល់ជាមួយកូនក្តីនៅពេលដែលមានការពឹងពាក់ពីកូនក្តី ហើយអាចធានាដល់សិទ្ធិសេរីភាពកូនក្តីខ្លួន ស្វែងរកភស្តុតាងដោះបន្ទុក ដើម្បីឲ្យរួចផុតពីការរំលោភបំពានណាមួយដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់។

ជាក់ស្តែងនៅពេលដែលមានបទល្មើសណាមួយកើតមានឡើង គូភាគីតែងតែចង់ទទួលបាននូវភាពយុត្តិធម៌ផ្តល់មកឲ្យខ្លួន និងការរួចផុតពីបទចោទប្រកាន់នានាដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ព្រោះអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និងកិត្តិយសក្នុងសង្គមជាខ្លាំង។ ហេតុនេះជាចាំបាច់នៅក្នុងរឿងក្តីព្រហ្មទណ្ឌគឺត្រូវការជំនួយពីមេធាវីក្នុងការជួយការពារសិទ្ធិដល់បុគ្គលណាម្នាក់ និងផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់ដែលមានប្រសិទ្ធិភាពជូនកូនក្តី។ លើសពីនេះ មេធាវីត្រូវតែរក្សាការសម្ងាត់វិជ្ជាជីវៈខ្លួនដោយមិនឲ្យបុគ្គលណាបានដឹងឡើយអំពីរឿងក្តី ឬសំណុំរឿងដែលខ្លួនកំពុងធ្វើការ ព្រោះវាអាចធ្វើឲ្យប៉ះពាល់ដល់ដំណើរការរឿងក្តី និងផលប្រយោជន៍អតិថិជនខ្លួនផងដែរ។ ច្បាប់នៃនីតិវិធីព្រហ្មទណ្ឌជាច្បាប់ដែលមានសារៈសំខាន់សម្រាប់ដំណើរការរឿងក្តីព្រហ្មទណ្ឌ និងការពារសង្គមក៏ដូចជាសេរីភាពបុគ្គលដោយអនុញ្ញាតឲ្យជនដែលគ្មានកំហុសអាចចៀសផុតពីការភ័ន្តច្រឡំផ្នែកតុលាការ គឺជនជាប់ចោទអាចការពារខ្លួនតាមរយៈមេធាវីខ្លួនដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវរបស់ខ្លួន។

ចំពោះ តួនាទីរបស់មេធាវីក្នុងដំណាក់កាលសំខាន់ៗនៃនីតិវិធីព្រហ្មទណ្ឌទាំងនោះរួមមានដូចជា៖

- (៣.១) ដំណាក់កាលស៊ើបអង្កេត
- (៣.២) ដំណាក់កាលចោទប្រកាន់
- (៣.៣) ដំណាក់កាលស៊ើបសួរ
- (៣.៤) ដំណាក់កាលជំនុំជម្រះ
- (៣.៥) ដំណាក់កាលក្រោយពេលសវនាការ

## ៣.១ ដំណាក់កាលស៊ើបអង្កេត

ដំណាក់កាលស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវប្រសិទ្ធិភាពនៃបណ្តឹងអាជ្ញា និងការស្វែងរកភស្តុតាងដើម្បីចាប់ជនល្មើស។ នៅក្នុងដំណាក់កាលទី១ នៃរឿងក្តីព្រហ្មទណ្ឌ

បន្ទាប់ពីមានបទល្មើសកើតឡើងរួចហើយ ឬកំពុងតែកើតឡើង ឬនឹងកើតឡើងក្នុងពេលខាងមុខ ស្ថាប័នដែលពាក់ព័ន្ធក្នុងការជួយដោះស្រាយរឿងក្តីនេះមុនគេ គឺនគរបាលយុត្តិធម៌។ នគរបាលយុត្តិធម៌ គឺជាជំនួយនៃអំណាចតុលាការ និងធ្វើការទទួលបន្ទុកក្នុងការត្រួតពិនិត្យបទល្មើស ឧក្រិដ្ឋ មជ្ឈិម និងបទលហុ ដោយកំណត់ពីអត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាងជាដើម។

ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានកំណត់ពីសិទ្ធិមានមេធាវីទៅតាមក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង និងការស៊ើបអង្កេតបឋមរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

### ៣.១.១ តួនាទីមេធាវីក្នុងការស៊ើបអង្កេតករណីជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌

#### ៣.១.១.១ លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតជាក់ស្តែង

ការបើកការស៊ើបអង្កេតជាក់ស្តែង ត្រូវបើកក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដោយយោងតាមមាត្រា៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បទល្មើសជាក់ស្តែង ជាបទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។ ចាត់ទុកជាបទល្មើសជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមកជនដែលគេសង្ស័យត្រូវបានសាធារណជន ស្រែកដេញប្រផាត់ចាប់ប្រកីង ឬបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្តបទល្មើសយោងមាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាត់ទុកដូចជាបទល្មើសជាក់ស្តែងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងនៅមាត្រា៨៦ ក៏ដោយគ្រប់បទឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ គឺសុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។

ការឃុំខ្លួន ឬចាប់ខ្លួនតែងកើតមានឡើងនៅពេលមានពាក្យបណ្តឹង ដោយសារមានការប្រព្រឹត្តបទល្មើសជាក់ស្តែង។ អាជ្ញាធរអាចឃុំខ្លួន ឬចាប់ខ្លួន ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលដាក់ពន្ធនាគារពីមួយឆ្នាំឡើងប៉ុណ្ណោះ។ ពេលឃាត់ខ្លួន ជនជាប់ឃុំអាចបាត់បង់សិទ្ធិមួយចំនួនខុសពីបុគ្គលទូទៅ ប៉ុន្តែយោងតាមច្បាប់ស្តីពីពន្ធនាគារមាត្រា២០ បញ្ញត្តិថាជនជាប់ឃុំមានសិទ្ធិស្វែងរកអ្នកតំណាងផ្នែកច្បាប់ សិទ្ធិផ្តល់ដំណឹងទៅគ្រួសារ ឬសាច់ញាតិ ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងការជាប់ពន្ធនាគារ និងទីតាំងនៃពន្ធនាគារព្រមទាំងសិទ្ធិករណីកិច្ចផ្សេងទៀត។

### ៣.១.២ តួនាទីមេធាវីក្នុងការស៊ើបអង្កេតបឋមរបស់មន្ត្រីនគរបាលយុត្តិធម៌

#### ៣.១.២.១ លក្ខខណ្ឌនៃការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម អាចដំណើរការបានដោយការផ្តួចផ្តើមរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬតាមការសុំរបស់ព្រះរាជអាជ្ញា ក្នុងករណីដែលមានបទល្មើសជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ ការស៊ើបអង្កេតបឋមដំណើរការនៅក្នុងករណីដែលមានបទឧក្រិដ្ឋមិនជាក់ស្តែង ឬក៏ក្នុងករណី ដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុត។ មាត្រា១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ពីថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងតែ ៧ ថ្ងៃប៉ុណ្ណោះ គិតចាប់ពីថ្ងៃដែលប្រព្រឹត្តបទល្មើស ។

អំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋមមានលក្ខណៈប្រហាក់ប្រហែល និងអំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ដោយគ្រាន់តែបទបញ្ញត្តិយោងមានភាពខុសគ្នា។ វិធានទាក់ទងនឹងការស៊ើបអង្កេតបឋម មានចែងចាប់ពីមាត្រា១១១ រហូតដល់មាត្រា១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំណុចដែលមានភាពខុសប្លែកគ្នាខ្លះទាក់ទិននឹងអំណាចនៃការឆែកឆេរ ដែលមានចែងនៅក្នុងមាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ គឺអាចធ្វើការឆែកឆេរបាន ប៉ុន្តែត្រូវមានៈ

១. ការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ជាលាយលក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ប៉ុន្តែប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរត្រូវសរសេរពីការយល់ព្រមរបស់អ្នកកាន់កាប់ទីកន្លែង និងការដែលជននេះពុំចេះសរសេរអក្សរ។

២. ដីកាអនុញ្ញាតឲ្យឆែកឆេរពីប្រធានសាលាដំបូង តាមការស៊ើបសួររបស់ព្រះរាជអាជ្ញា ប្រសិនបើអ្នកដែលកាន់កាប់ទីកន្លែង ហើយមិនអាចផ្តើមមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចឡើយ។

ក្នុងករណីនេះជនសង្ស័យអាចសុំណាត់ជួបមេធាវីតំណាងរបស់ខ្លួនដើម្បីពិភាក្សា មុននឹងយល់ព្រមក៏ដូចជាសួរនាំពីរបៀបឆ្លើយតបទៅនឹងមន្ត្រីនគរបាលយុត្តិធម៌ ជៀសវាងមន្ត្រីនគរបាលយុត្តិធម៌ការបំពានទៅលើសិទ្ធិរបស់ខ្លួន។ ម្យ៉ាងទៀតប្រសិនបើមន្ត្រីនគរបាលយុត្តិធ៌មពុំបានអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីហើយមានការបំពានទៅលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌អាចត្រូវផ្តន្ទាទោសតាមមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា ។

មេធាវីក្នុងករណីនេះពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការអមជាមួយជនជាប់សង្ស័យ នៅក្នុងដំណាក់កាលស៊ើបអង្កេតបឋមនេះដែរ ជននេះផ្តល់ចម្លើយតាមការសាកសួរពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា ប៉ុន្តែក្នុងករណីដែលជនជាប់សង្ស័យគ្មានមេធាវីហើយត្រូវបានឃាត់ខ្លួន ឬជនល្មើសត្រូវបានឃាត់

ខ្លួនក្នុងបទល្មើសជាក់ស្តែង ជននេះអាចមានសិទ្ធិមានមេធាវីបាន បន្ទាប់ពីមានការឃាត់ខ្លួនក្នុងរយៈពេល ២៤ ម៉ោង កន្លងផុត។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាបានធ្វើទារុណកម្ម ប្រព្រឹត្តអំពើហិង្សា ដើម្បីឲ្យជនល្មើស ឬជនជាប់សង្ស័យផ្តល់ចម្លើយតាមការបង្ខំ ឬឲ្យឆ្លើយសារភាព មេធាវីអាចប្តឹងលើកំណត់ហេតុនោះទុកជាមោឃៈដើម្បីដកចេញពីសំណុំរឿង។ កំណត់ហេតុនៅដំណាក់កាលស៊ើបអង្កេតជាឯកសារដើម ដែលត្រូវបានរក្សាទុកក្នុងសំណុំរឿង ហេតុនេះកាលណាគ្មានភស្តុតាងផ្ទុយទេតុលាការនឹងសម្រេចដោយយោងទៅលើកំណត់ហេតុដែលជាភស្តុតាងដាក់បន្ទុក។

### ៣.១.៣ សិទ្ធិមានមេធាវីរបស់ជនសង្ស័យក្នុងដំណាក់កាលឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌

ជនដែលត្រូវបានឃាត់ខ្លួនមានសិទ្ធិរក្សាភាពស្ងៀមស្ងាត់ មិនឆ្លើយនូវសំណួររបស់មន្ត្រីនគរបាលយុត្តិធម៌បានរហូតចាំដល់មានជំនួយពីមេធាវី ហើយគ្មាននរណាម្នាក់អាចបង្ខំឲ្យឆ្លើយសារភាពបានឡើយ។ សិទ្ធិមិនឆ្លើយសារភាព ជនដែលត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួនមិនត្រូវឆ្លើយអ្វីដែលខ្លួនមិនបានប្រព្រឹត្តនោះទេ ឬអាចឆ្លើយ ឬមិនឆ្លើយសារភាពរហូតដល់ខ្លួនមាន មេធាវីការពារសិទ្ធិ ដោយគ្មាននរណាម្នាក់អាចបង្ខំឲ្យសារភាពថាបានប្រព្រឹត្តបទល្មើសណាមួយដោយការគំរាមកំហែង ការវាយដំធ្វើទារុណកម្មណាមួយនោះឡើយ។ រាល់ការសារភាពដែលកើតចេញពីការបង្ខំតាមផ្លូវកាយក្តី ការគំរាមកំហែង ការវាយដំ ធ្វើទារុណកម្ម មិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពបាននោះទេ ។

ក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិថា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួន ចំពោះបុគ្គលដែលសង្ស័យប្រព្រឹត្តបទល្មើស។ ករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើសហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុតយោងតាមមាត្រា៨៧ នៃក្រមនីតិ-វិធីព្រហ្មទណ្ឌ។ មន្ត្រីនគរបាលមានសិទ្ធិឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសក្រៅពីបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីបទល្មើស ឬដំណើររឿងហេតុបានផងដែរ។ លើសពីនេះ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនបុគ្គលទៅបាន លុះត្រាបុគ្គលប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញាដោយយោងតាមមាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

រយៈពេលនៃការឃាត់ខ្លួនមានថិរវេលា ៤៨ម៉ោង ដោយគិតចាប់ពីម៉ោងដែលសាមីខ្លួនបានមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចពន្យាពេលថែម២៤ ម៉ោងក្នុងករណីដែលរកឃើញថាមានភស្តុតាងថ្មីដែលមានប្រយោជន៍ដល់រឿងក្តី ប៉ុន្តែមិនត្រូវលើសពី២៤ម៉ោង នេះឡើយ។ ការពន្យា

ពេលនៃការឃាត់ខ្លួនមិនអាចធ្វើបានឡើយ ប្រសិនបុគ្គលដែលត្រូវបានឃាត់ខ្លួនអនីតិជន ហើយរយៈពេលនៃការឃាត់ខ្លួនអនីតិជនអាចធ្វើបានក្នុងករណីដូចមានចែងក្នុងមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌដូចតទៅៈ

- មានតម្រុយបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គល ដែលឃាត់ខ្លួនគឺជានីតិជនក្នុងបទឧក្រិដ្ឋ។
- ការពន្យាពេលជាវិធានការណ៍ចាំបាច់ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។
- ការអនុញ្ញាតដោយព្រះរាជអាជ្ញា ជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។
- ចំពោះការឃាត់ខ្លួនអនីតិជនអាចធ្វើបានចំពោះតែអនីតិជន អាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ដោយយោងតាមមាត្រា៩៦ កថាខណ្ឌចុងក្រោយ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រយៈពេលនៃការឃាត់ខ្លួនប្រែប្រួលទៅតាមប្រភេទនៃបទល្មើសដូចខាងក្រោមៈ

▪ **ចំពោះបទឧក្រិដ្ឋ ៖**

–អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ឬស្មើ ១៦ ឆ្នាំ មិនហួសពី ៣៦ ម៉ោង។

–អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ឬស្មើ ១៨ ឆ្នាំ មិនហួសពី ៤៨ ម៉ោង ។

❖ **ចំពោះបទមជ្ឈិម ៖**

–អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ឬស្មើ ១៦ ឆ្នាំ មិនហួសពី ២៤ ម៉ោង ។

–អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ឬស្មើ ១៨ ឆ្នាំ មិនហួសពី ៣៦ ម៉ោង ។

គ្រប់បុគ្គលដែលត្រូវបានឃាត់ខ្លួនមានសិទ្ធិក្នុងការទទួលបានជំនួយពីមេធាវី ឬអ្នកដែលត្រូវបានជ្រើសរើសដោយបុគ្គលដែលត្រូវបានគេឃាត់ខ្លួន (បុគ្គលដែលពុំជាប់ពាក់ព័ន្ធនឹងរឿងក្តី) អាចធ្វើការសន្ទនាជាមួយបុគ្គលដែលត្រូវបានឃាត់ខ្លួនរយៈពេល ៣០នាទី ក្នុងលក្ខខណ្ឌសម្ងាត់ក្រោយពេលដែលបុគ្គលនេះត្រូវបានគេឃាត់ខ្លួនរយៈពេល ២៤ម៉ោង រួចមកយោងតាមមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សម្រាប់ការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានគ្រប់មធ្យោបាយដល់ឪពុកម្តាយដល់អ្នកតំណាងស្របច្បាប់ ឬអ្នកដែលទទួលភារកិច្ចលើអនីតិជននោះយោងមាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មន្ត្រីយុត្តិធម៌ត្រូវជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជន ប្រសិនបើមាន។ ក្នុងករណីដែលគ្មានការជ្រើសរើស មន្ត្រីនគរបាលត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបានបន្ទាប់ពីអនីតិជនមកដល់អង្គភាពនគរបាលយុត្តិធម៌។

ក្នុងអំឡុងពេលឃាត់ខ្លួននេះ មេធាវីក៏ទទួលបានឱកាសសន្ទនា ឬទំនាក់ទំនងជាមួយកូនក្តីដែលជាអនីតិជនបានដោយមានលក្ខណៈឯកជន និងសម្ងាត់ ប្រសិនបើមានការស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) នាទី ដែលត្រូវធ្វើមុនពេលស្តាប់ចម្លើយ។ ករណីគ្មានវត្តមានមេធាវីអនីតិជនអាចមានសិទ្ធិមិនផ្តល់ចម្លើយបាន។

ការស្តាប់ចម្លើយត្រូវប្រព្រឹត្តដោយមានវត្តមានមេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជន និងជាសម្ងាត់។

ករណីអវត្តមានមេធាវីរបស់អនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាន ហើយបញ្ចូនក្នុងសំណុំរឿងអនីតិជន។ នៅពេលបញ្ចប់ការស្តាប់ចម្លើយហើយមេធាវីអាចអានកំណត់ហេតុស្តាប់ចម្លើយបាន។ លើសពីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដែលធ្វើឡើងដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ មេធាវីរបស់អនីតិជន ទោះបីការជូនដំណឹងនោះមិនបានទទួលលទ្ធផលក្តី។[59] មេធាវីក៏អាចធ្វើការស្នើសុំច្បាប់ចម្លងនៃកំណត់ហេតុស្តីពីការចាប់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនបានផងដែរ។

### ៣.១.៤ ជំនួយមេធាវីពេលជាប់ឃុំ

ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់នូវភារកិច្ចជូនមេធាវីជាអ្នកការពារសិទ្ធិឲ្យជនល្មើស និងការពារសិទ្ធិឲ្យជនរងគ្រោះទៅតាមដំណាក់កាលនីមួយៗនៃនីតិវិធី។ មុនពេលដែលជនជាប់ឃុំត្រូវបានគេបញ្ចូនមកដល់ពន្ធនាគារ ជនជាប់ឃុំដែលបានឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀតស្ថិតនៅក្នុងដំណាក់កាលឃាត់ខ្លួននេះអាចមានសិទ្ធិស្នើសុំមេធាវីដើម្បីការពារខ្លួន។

ក្នុងករណីដែលមេធាវីជាអ្នកការពារសិទ្ធិឲ្យជនល្មើស មេធាវីមានតួនាទីចូលរួមពិនិត្យមើលអំពីការទទួលស្គាល់ និងប្រើប្រាស់សិទ្ធិសម្រាប់ជនល្មើសពីសំណាក់អាជ្ញាធរសមត្ថកិច្ចតាមដំណាក់កាលនីតិវិធី។ ដំណាក់កាលស៊ើបអង្កេតបឋម មេធាវីអមជាមួយជនជាប់សង្ស័យ ដែលជននេះផ្តល់ចម្លើយតាមការសាកសួរពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា ប៉ុន្តែក្នុងករណីដែលជនជាប់សង្ស័យគ្មានមេធាវីហើយត្រូវបានឃាត់ខ្លួន ឬជនល្មើសត្រូវបានឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែងជននេះអាចមានសិទ្ធិមានមេធាវីបាន បន្ទាប់ពីមានការឃាត់ខ្លួនក្នុងរយៈពេល ២៤ម៉ោង កន្លងផុត។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាបានធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើហិង្សា ដើម្បីឲ្យជនល្មើស ឬជនជាប់សង្ស័យផ្តល់ចម្លើយតាមការបង្ខំ ឬឲ្យឆ្លើយសារភាព មេធាវីអាចប្តឹងលើកំណត់ហេតុនោះទុកជាមោឃៈ ដើម្បីដកចេញពីសំណុំរឿង។

កំណត់ហេតុនៅដំណាក់កាលស៊ើបអង្កេតជាឯកសារដើមដែលត្រូវបានរក្សាទុកក្នុងសំណុំរឿងហេតុនេះកាលណាគ្មានភស្តុតាងផ្ទុយទេ តុលាការនឹងសម្រេចដោយយោងទៅលើកំណត់ហេតុដែលជា ភស្តុតាងដាក់

[59] មាត្រា ១៨ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បន្ទុក។ នៅក្នុងដំណាក់កាលស៊ើបអង្កេត មេធាវីមានភារកិច្ចអមជាមួយជនរងគ្រោះ ដើម្បីចូលបំភ្លឺអង្គហេតុតាមការកោះហៅរបស់មន្រ្តីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា។

## ៣.២ ដំណាក់កាលចោទប្រកាន់

ពេលបញ្ចប់ការឃាត់ខ្លួនបុគ្គលដែលឃាត់ខ្លួន ត្រូវបញ្ជូនមកដើម្បីចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា។ បន្ទាប់មកព្រះរាជអាជ្ញា ត្រូវប្រាប់ឲ្យដឹងអំពីសិទ្ធិទទួលបានជំនួយមេធាវីតាមការជ្រើសរើស ឬតាមរយៈការចាត់មេធាវី។ នៅក្នុងដំណាក់កាលចោទប្រកាន់នេះ មេធាវីក៏ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងអំឡុងពេលស្តាប់ចម្លើយជនជាប់សង្ស័យដែរ។

### ៣.២.១ វត្តមានមេធាវីក្នុងពេលស្តាប់ចម្លើយ

ប្រសិនព្រះរាជអាជ្ញាបានធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើហិង្សាដើម្បីឲ្យជនល្មើស ឬជនជាប់សង្ស័យផ្តល់ចម្លើយតាមការបង្ខំ ឬឲ្យឆ្លើយសារភាព មេធាវីអាចប្តឹងលើកំណត់ហេតុនោះទុកជាមោឃៈ ដើម្បីដកចេញពីសំណុំរឿង។ ព្រះរាជអាជ្ញាត្រូវធ្វើការចាត់តាំងមេធាវីដោយមិនយកកម្រៃឲ្យអនីតិជន។ ករណីជាអនីតិជនការស្តាប់ចម្លើយត្រូវធ្វើឡើងជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី។ ការស្តាប់ចម្លើយត្រូវមានវត្តមានមេធាវី បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយ ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវីអានកំណត់ហេតុស្តាប់ចម្លើយ និងត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ។

ករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ។[60] ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅអនីតិជន និងត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬមេធាវីរបស់អនីតិជនដើម្បីរៀបចំមធ្យោបាយការពារអនីតិជន។[61]

## ៣.៣ ដំណាក់កាលស៊ើបសួរ

យោងតាមការជ្រើសរើសប្រព័ន្ធវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរមាននាទីសំខាន់ណាស់ក្នុងការចូលរួមចំណែកស្វែងរកយុត្តិធម៌ដល់គូភាគី។ តួនាទីយ៉ាងសំខាន់របស់ចៅក្រមស៊ើបសួរគឺការសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ដែលជាសេចក្តីសម្រេចប៉ះពាល់យ៉ាងខ្លាំងទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គល មានន័យថាចៅក្រមស៊ើបសួរមិនត្រឹមតែធ្វើការស៊ើបសួរប៉ុណ្ណោះទេ ប៉ុន្តែត្រូវស្វែងរកភស្តុតាង

[60] មាត្រា ២៦ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[61] មាត្រា ២៩ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ទាំងដាក់បន្ទុក និងដោះបន្ទុកដើម្បីបង្ហាញឲ្យឃើញពីភាពត្រឹមត្រូវនៃអំពើមួយដែលកើតឡើង។[62] ទោះបីជាយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលចៅក្រមស៊ើបសួរនេះមេធាវីក៏នៅតែបន្តតួនាទីរបស់ខ្លួនដើម្បីការពារដល់ជនត្រូវចោទគ្រប់ដំណាក់កាលនៃកិច្ចនីតិវិធីជាពិសេសដំណាក់កាលចៅក្រមស៊ើបសួរនេះផ្ទាល់។

មេធាវីក៏មានតួនាទីត្រួតពិនិត្យអំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការការពារសិទ្ធិរបស់ជនត្រូវចោទដែលជាកូនក្តីរបស់ខ្លួន ជៀសវាងមានការបំពានសិទ្ធិរបស់ជនត្រូវចោទ។ មេធាវី មានសិទ្ធិដឹងរាល់ការសម្រេចរបស់ចៅក្រមស៊ើបសួរលើជនត្រូវចោទតាមរយៈការជូនដំណឹង។ លើសពីនេះ មេធាវីមានតួនាទីត្រួតពិនិត្យអំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការការពារសិទ្ធិ របស់ជនត្រូវចោទដែលជាកូនក្តីរបស់ខ្លួន ជៀសវាងមានការបំពានសិទ្ធិរបស់ជនត្រូវចោទ។ មេធាវី មានសិទ្ធិដឹងរាល់ការសម្រេចរបស់ចៅក្រមស៊ើបសួរលើជនត្រូវចោទតាមរយៈការជូនដំណឹង។ នៅក្នុងដំណាក់ស៊ើបសួរ មេធាវីអាចធ្វើការស្នើសុំបំពេញកិច្ចនានាដែលខ្លួនយល់ឃើញថាចំណាច់ដើម្បីបំភ្លឺការពិតតាមរយៈការប្រគល់សិទ្ធិពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។

### ៣.៣.១ កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ

#### ៣.៣.១.១ វត្តមានមេធាវីក្នុងពេលសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ គឺដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធទៅនឹងបទល្មើសហើយ ជាដំណាក់កាលមួយក្នុងការបំភ្លឺឲ្យឃើញកាន់តែច្បាស់នូវអង្គហេតុណាមួយ។ មុននឹងសួរចម្លើយជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ជនត្រូវចោទ មកសួរចម្លើយមុនរយៈពេលយ៉ាងតិច ៥ថ្ងៃ មុនពេលសួរចម្លើយ។ ចៅក្រមស៊ើបសួរមិនអាចសួរចម្លើយដោយគ្មានមេធាវីការពារខ្លួនរបស់ជនត្រូវចោទបានឡើយ។ ក្នុងករណីដែលចៅក្រមស៊ើបសួរបានកោះហៅមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទ ប៉ុន្តែមេធាវីមិនបានបង្ហាញខ្លួនតាមការកំណត់ចៅក្រមស៊ើបសួរអាចសួរចម្លើយដោយពុំមានវត្តមានមេធាវីការពារសិទ្ធិបាន ហើយចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសទៅលើកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទ ដោយមូលហេតុអវត្តមានមេធាវីការពារសិទ្ធិជនត្រូវចោទ។ នៅពេលដែលសួរចម្លើយជនត្រូវចោទ មានសំណួរមួយចំនួនមិនអាចធ្វើការសួរទៅលើជនត្រូវចោទបាននោះឡើយ ហើយចំនួនសំណួរដែលមិនត្រូវបានអនុញ្ញាតឲ្យសួរនោះត្រូវចុះកំណត់ហេតុសួរចម្លើយ។មេធាវីអាចលើកសំណួរមកសួរជនត្រូវចោទបាននៅពេលដែលចៅក្រមស៊ើបសួរបានសួរចម្លើយចប់។

ករណីជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខចៅ-ក្រមស៊ើបសួរ។ ករណីគ្មានការជ្រើសរើស ចៅក្រមស៊ើបសួរត្រូវបានចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែង

[62] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវីយោងតាមមាត្រា ៣២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យមេធាវីអានកំណត់ហេតុស្តាប់ចម្លើយបានប្រសិនមានការស្នើសុំ។ ករណីអនីតិជនមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងការកំណត់ហេតុស្តាប់ចម្លើយ។ បើមេធាវីអវត្តមានចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ លើកលែងតែករណីដែលអាចបាត់បង់តម្រុយនៃភស្តុតាង។[63]

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ ក៏អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំ។ ការសន្ទនារបស់មេធាវី និងជនត្រូវចោទមិនអាចត្រូវបានគេស្តាប់ ឬថតបាននោះទេ។ មេធាវីអាចអានលិខិតសំណុំរឿងឲ្យកូនក្តីស្តាប់បាន ប៉ុន្តែមិនអាចឲ្យលិខិតថតចម្លងពីលិខិតសំណុំរឿងដល់កូនក្តីឡើយយោងតាមមាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ៣.៣.១.២ វត្តមានមេធាវីពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីក៏មានវត្តមានក្នុងពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដោយចៅក្រមស៊ើបសួរស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខមេធាវីមានការចូលរួមពីព្រះរាជអាជ្ញា។លើសពីនេះមេធាវីក៏អាចលើកសំណួរបានដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរយោងតាមមាត្រា១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តាមរយៈនេះនៅពេលចៅក្រមស៊ើបសួរចេញដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី មេធាវីក៏ត្រូវទទួលបានលិខិតអញ្ជើញពីចៅក្រមស៊ើបសួរផងដែរ។

### ៣.៣.២ វិធានការនិរន្តរាយ

នៅក្នុងវិធានការនិរន្តរាយ គឺជាដំណាក់កាលមួយដែលដកហូតសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់ត្រូវបានអនុវត្តដោយអំណាចចាប់បង្ខំរបស់រដ្ឋ គឺតាមរយៈស្ថាប័ននៃអំណាចតុលាការ។ ទោះបីវិធានការនេះបានរំលោភលើសិទ្ធិ និងសេរីភាពនៃជនជាប់ចោទដែលមានការឃុំខ្លួនបណ្តោះអាសន្នក្នុងគោលបំណងដើម្បីរក្សានូវគុណភាព និងសណ្តាប់ធ្នាប់ក្នុងសង្គមក្នុងនោះមានសិទ្ធិសេរីភាពរបស់ជនជាប់ចោទក៏ត្រូវបានធានាតាមច្បាប់ផងដែរតាមរយៈការទទួលបានសិទ្ធិការពារក្តីពីមេធាវីដែលខ្លួនបានជ្រើសរើស។

ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់សិទ្ធិជូនដល់មេធាវីក្នុងវិធានការនិរន្តរាយនេះតាមរយៈ ការធានានូវសិទ្ធិពេលឃុំខ្លួនបណ្តោះអាសន្ន ការធានាឲ្យជនត្រូវចោទនៅក្រៅឃុំ ការកោះហៅ ឬជូនដំណឹង បណ្តឹងសុំកែប្រែ និងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។

[63] មាត្រា ៣៦ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៣.៣.២.១ ការឃុំខ្លួនបណ្តោះអាសន្ន

យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាជាគោលការណ៍ជនត្រូវចោទ ត្រូវតែមានសេរីភាព។ ការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការមួយដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលទើបធ្វើឲ្យការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នអាចធ្វើបានតែក្នុងករណីពិសេសតែប៉ុណ្ណោះ ហើយការឃុំខ្លួនបណ្តោះអាសន្ននេះមានតែចំពោះបទឧក្រិដ្ឋ និង បទមជ្ឈិមដែលច្បាប់បានកំណត់ទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ឆ្នាំ។ មុននឹងសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវបើកនីតិវិធីឃុំខ្លួនដោយត្រូវមានវត្តមានជនត្រូវចោទ មេធាវីរបស់ជនត្រូវចោទ និងតំណាងអយ្យការចូលរួម។

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចថាឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នការឃុំខ្លួនបណ្តោះអាសន្ននេះត្រូវស្ថិតក្នុងថិរវេលាដែលកំណត់ដោយច្បាប់។ ចំពោះថិរវេលាមានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើសដែលដែលបានចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទដែលឃុំខ្លួន។

ថិរវេលានេះប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទឃុំខ្លួនដូចតទៅ៖

❖ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម

- ការឃុំខ្លួនមិនលើសពី ១ឆ្នាំបានទេចំពោះបទល្មើសនីមួយៗប៉ុន្តែនៅពេលផុតថិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារពេលឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ឆ្នាំ ដោយដីកាមានសំអាងហេតុច្បាស់លាស់ ហើយការពន្យារនេះធ្វើបានតែពីរដងប៉ុណ្ណោះយោងតាមមាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

❖ បទឧក្រិដ្ឋផ្សេងទៀត

- ជនត្រូវចោទជានីតិជន៖ រយៈពេលឃុំខ្លួនបណ្តោះអាសន្នគឺ ៦ខែ អាចពន្យារបាន ៦ខែ ចំនួនពីរដង យោងតាមមាត្រា២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ជនត្រូវចោទជាអនីតិជន អាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ៖ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ខែ បានទេ (មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- ជនត្រូវចោទជាអនីតិជន អាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ៖ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ខែ បានទេ ។

❖ បទមជ្ឈិម

- ជនត្រូវចោទជានីតិជន៖ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នគឺ៤ខែពន្យារពេលបាន ២ខែទៀតហើយការឃុំខ្លួនបណ្តោះអាសន្ននេះមិនលើសពីពាក់កណ្តាលនៃអប្បរមានៃទោស ដែលច្បាប់បានកំណត់ឡើយ យោងតាមមាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ឧទាហរណ៍៖ ជនត្រូវចោទជាប់ចោទពីបទ

អំពើលួច តាមច្បាប់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ដល់ ៣ឆ្នាំ យោងតាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។ អប្បរមានៃទោសគឺ ៦ខែ នាំឲ្យពាក់កណ្តាលអប្បរមាគឺ ៣ខែ។ ហេតុនេះ ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវឲ្យលើសពី ៣ខែនោះទេ។

- ជនត្រូវចោទជាអនីតិជនចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ៖ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ខែ បានទេ យោងតាមមាត្រា២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្តាលនៃអប្បរមានៃទោសដែលច្បាប់បានកំណត់ឡើយ។
- ជនត្រូវចោទជាអនីតិជនចាប់ពី ១៦ឆ្នាំ ដល់ ១៨ឆ្នាំ ៖ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ខែ បានទេ យោងតាមមាត្រា២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះពុំអាចលើសពីពាក់កណ្តាលនៃអប្បរមានៃទោសដែលច្បាប់បានកំណត់ឡើយ។

មេធាវីត្រូវបានជូនដំណឹងភ្លាមបន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតាមរយៈដីកាដោយមានសំអាងហេតុ។[64] កាលណាជនត្រូវចោទមានមេធាវីអម មេធាវីត្រូវបង្ហាញពីមធ្យោបាយការពារខ្លួនដល់កូនក្តីរបស់ខ្លួន។ បើចៅក្រមស៊ើបសួរ សម្រេចថាពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្នចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ ហើយមេធាវីជនត្រូវចោទមានតួនាទីត្រូវបង្ហាញពីមធ្យោបាយការពារខ្លួនដល់កូនក្តី។ អ្នកដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬអ្នកជាប់ពន្ធនាគារទាំងអស់ត្រូវបានផ្តល់ឱកាស ពេលវេលា និងមធ្យោបាយដើម្បីជួបប្រាស្រ័យទាក់ទង និងប្រឹក្សាយោបល់ជាមួយមេធាវីរបស់ខ្លួន ដោយគ្មានការពន្យាពេល ការរាំងស្ទាក់ ឬការត្រួតពិនិត្យ ត្រូវរក្សាការសម្ងាត់ទាំងស្រុង។[65]

### ៣.៣.២.២ ជំនួយមេធាវីក្នុងការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ

ក្នុងករណី ជនត្រូវចោទជាប់ឃុំខ្លួនបណ្តោះអាសន្នក្រោយពីមានដីកាសម្រេចរបស់ចៅក្រមស៊ើបសួររួចហើយដោយមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងដោយអនុញ្ញាតឲ្យជនត្រូវចោទអាចស្ថិតនៅក្រៅឃុំបានតាមរយៈពាក្យសុំឲ្យដោះលែងនៅក្រៅឃុំរបស់ជនត្រូវចោទ ឬមេធាវីជនត្រូវចោទ។

[64] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[65] ការការពារពិសេសក្នុងរឿងក្តីយុត្តិធម៌ព្រហ្មទណ្ឌ ចំណុចទី៨ នៃលិខិតតុបករណ៍អង្គការសហប្រជាជាតិ

មេធាវីអាចដាក់ពាក្យសុំឲ្យកូនក្តីខ្លួននៅក្រៅឃុំតាមរយៈពាក្យសុំនេះទៅកាន់ចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរនឹងបញ្ជូនពាក្យសុំនេះទៅកាន់ព្រះរាជអាជ្ញាភ្លាមដើម្បីសុំយោបល់ និងបញ្ជូនសំណុំរឿងទៅឲ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញា ត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរត្រូវសម្រេចថាដោះលែង ឬមិនដោះលែង ក្នុងរយៈពេល៥ថ្ងៃបន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាភ្លាម។ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ថ្ងៃនេះ ជនត្រូវចោទអាចប្តឹងសភាស៊ើបសួរឲ្យសម្រេចជំនួសបាន។ ចៅក្រមស៊ើបសួរអាចចេញ ដីកាសម្រេចឲ្យដោះលែងឲ្យនៅក្រៅឃុំ ឬដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ។ ចំពោះដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ ត្រូវតែមានសំអាងហេតុ។ ករណី ចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំម្តងហើយនោះ ជនត្រូវចោទអាចដាក់ពាក្យសុំម្តងទៀតបានក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីសម្រេចលើកមុន។[66]

ករណីអនីតិជន ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលាដោយគំនិតផ្តួចផ្តើមរបស់ខ្លួន។ ដោយយោងទៅតាមមាត្រា ៤១ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ប៉ុន្តែចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ។

### ៣.៣.២.៣ ការកោះហៅ និងជូនដំណឹងដល់មេធាវី

ដីកាកោះ គឺជាលិខិតបង្គាប់របស់តុលាការដែលតម្រូវឲ្យបុគ្គលណាមួយត្រូវបង្ហាញខ្លួននៅតុលាការតាមកាលបរិច្ឆេទដែលបានកំណត់។ មេធាវីអាចត្រូវបានកោះហៅតាមគ្រប់មធ្យោបាយដូចជា ប្រៃសណីយ៍ ឬតាមផ្លូវរដ្ឋបាល ប៉ុន្តែក្នុងករណីចាំបាច់ការកោះហៅអាចធ្វើបានគ្រប់មធ្យោបាយ។ មាត្រា ២៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ពីការជូនដំណឹងអំពីដីកាសម្រេចដែលត្រូវធ្វើការជូនដំណឹងដល់មេធាវីជនជាប់ចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានដឹងអំពីការកោះហៅ ឬការជូនដំណឹង។

ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានផ្តល់សិទ្ធិអនុញ្ញាតដល់មេធាវីជនត្រូវចោទក្នុងការជូនពាក្យសុំដល់ចៅក្រមស៊ើបសួរដើម្បីធ្វើបណ្តឹង។ រាល់ពាក្យសុំដោយបុគ្គលស្ថិតនៅក្រៅនីតិវិធីស៊ើបសួរឲ្យប្រគល់វត្ថុដែលចាប់យកអាចធ្វើតាមរយៈមេធាវី។ មួយវិញទៀត ទាក់ទងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរអំពីការសម្រេចឲ្យជនត្រូវចោទនៅក្រៅឃុំ ត្រូវធ្វើការជូនដំណឹងដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់មាត់ ផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ យោងតាមមាត្រា ២៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

---

[66] មាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.៣.២.៤ បណ្តឹងសុំកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតម្រូវឲ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើន ដែលមានចែងក្នុងមាត្រា ២២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ករណីនេះចៅក្រមស៊ើបសួរចេញដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬដីកាសម្រេចបដិសេធការសុំឲ្យដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

ក្រោយពីចៅក្រមស៊ើបសួរ ចេញដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរួចហើយអាចនឹងមានការកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ តាមរយៈនេះមេធាវី ឬជនត្រូវចោទអាចធ្វើបណ្តឹងសុំកែប្រែ ឬការត្រួតពិនិត្យតាមផ្លូវតុលាការបានផងដែរ។

មេធាវីការពារជនជាប់ចោទអាចធ្វើពាក្យសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរ នឹងធ្វើការបញ្ជូនពាក្យសុំលើកលែងនេះទៅកាន់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ករណីនេះចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទ ឬមេធាវីអាចប្តឹងទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ម្យ៉ាងវិញទៀត ករណីដីកាសម្រេច មិនបានធ្វើការសម្រេចព្រមតាមពាក្យសុំត្រូវមានសំអាងហេតុ។

### ៣.៣.៣ ការស្នើសុំឲ្យបំពេញកិច្ចដោយមេធាវីជនត្រូវចោទ

ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិឲ្យព្រះរាជអាជ្ញា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងជាពិសេសមេធាវីធ្វើការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបាន។ នៅគ្រប់ពេលនៃការស៊ើបសួរ ជនជាប់ចោទ អាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីសួរតទល់គ្នា ឬចុះទៅដល់ទីកន្លែងកើតហេតុ។ ករណីចៅក្រមស៊ើបសួរមិនបានធ្វើតាមពាក្យសុំនេះទេ ចៅក្រមត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១ខែបន្ទាប់ពីទទួលបានពាក្យសុំ។ មេធាវីការពារក្តីជនជាប់ចោទ ត្រូវទទួលបានការជូនដំណឹងជាបន្ទាប់អំពីដីកាដោយមានសំអាងហេតុ។ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[67]

[67] មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.៣.៤ ការស្នើសុំឲ្យបំពេញកិច្ចដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

នៅគ្រប់ពេលស៊ើបសួរ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឲ្យស្ដាប់ចម្លើយខ្លួន ស្ដាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទដោយតទល់គ្នា ឬចុះទៅកន្លែងកើតហេតុ។ ចំពោះពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ករណីចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំទេ ចៅក្រមត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកាបដិសេធ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់មេធាវីការពារក្ដីឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ១ខែ ទេ ដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់ពាក្យប្ដឹងសុំដល់សភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន (មាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៣.៣.៥ ការបិទការស៊ើបសួរ

បន្ទាប់ពីចៅក្រមស៊ើបសួរបានបញ្ចប់ការស៊ើបសួរហើយ ចៅក្រមស៊ើបសួរនឹងចេញដីកាដំណោះស្រាយ ដែលអាចជាដីកាលើកលែងការចោទប្រកាន់ ឬបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។

ចៅក្រមស៊ើបសួរនឹងចេញលិខិតជូនព័ត៌មាន ឬដំណឹងទៅជនជាប់ចោទ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីពិនិត្យ និងឆ្លើយតប។

### ៣.៣.៦ ការប្ដឹងអំពីសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ

ក្រោយពីបញ្ចប់ការស៊ើបសួរ ឬបិទការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាន ឬជូនដំណឹងស្ដីពីការបិទការស៊ើបសួរដល់គ្រប់ភាគីពាក់ព័ន្ធក្នុងសំណុំរឿងព្រហ្មទណ្ឌ ។ ចំពោះការប្ដឹងនេះអាចជាការប្ដឹងសុំមោឃភាពកិច្ចនៃនីតិវិធី ការប្ដឹងឧទ្ធរណ៍ ឬការប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដើម្បីឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរ។ យោងតាមមាត្រា២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានតែសភាស៊ើបសួរប៉ុណ្ណោះដែលមានសមត្ថកិច្ចដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី។

#### ៣.៣.៦.១ ការប្ដឹងមោឃភាពកិច្ចនៃនីតិវិធី

ចំពោះការកំណត់ករណីដែលនាំឲ្យមានមោឃភាពចំពោះនីតិវិធីស៊ើបសួរវិញ បានបញ្ញត្តិនៅមាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ វិធាន និងទម្រង់ការដែលចេញចែងដោយមាត្រាខាងក្រោមនេះ ស្ដីពីបញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរដែលមានលក្ខខណ្ឌដាច់ខាតត្រូវគោរពតាម ពុំនោះទេនាំឲ្យមានមោឃភាពនៃនីតិវិធីដែលមានដូចតទៅ៖

- ការបើកការស៊ើបសួរ
- សមត្ថកិច្ចដែនដី

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- វិសាលភាពនៃបណ្តឹង ករណីនេះចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអង្គហេតុមិនមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ។

ម្យ៉ាងវិញទៀតនាំឲ្យមានមោឃភាពផងដែរ ករណីមានការបំពានលើវិធាន ឬទម្រង់ការសំខាន់ណាមួយដែលបានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលរងការបំពាន។ ឧទាហរណ៍៖ ការសួរចម្លើយជនត្រូវចោទជាអនីតិជនពុំមានមេធាវីអមយោងតាមមាត្រា១៤៣កថាខណ្ឌទី៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ លើសពីនេះមាត្រា១០៩ និងមាត្រា១១៧នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បញ្ញត្តិពីករណីមោឃភាពនៃលិខិតនៃនីតិវិធីដែលបានធ្វើនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមដែរ។

### ៣.៣.៦.២ បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ

យោងតាមមាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា បើសិនជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃភាព មេធាវីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើពាក្យសុំដោយមានសំអាងហេតុជូនទៅសភាស៊ើបសួរ និងជូនដំណឹងទៅចៅក្រមព្រោះមានតែសភាស៊ើបសួរប៉ុណ្ណោះដែលមានសមត្ថកិច្ចក្នុងការពិនិត្យមោឃភាពនៃលិខិតនីតិវិធី។

ពាក្យសុំឲ្យពិនិត្យមោឃភាពនៃកិច្ចនីតិវិធីនេះ មេធាវីត្រូវជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុហើយត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ លើសពីនេះ ពាក្យសុំនេះត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរភ្លាម បន្ទាប់មកក្រឡាបញ្ជីសុំឲ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនីតិវិធីមកឲ្យខ្លួនភ្លាម។[68]

បន្ទាប់ពីសភាស៊ើបសួរបានពិនិត្យពីមោឃភាពនៃលិខិតនៃនីតិវិធីរួចហើយ សេចក្តីសម្រេចរបស់សភាស៊ើបសួរមានពីរគឺ សភាស៊ើបសួរសម្រេចមិនទទួលពាក្យបណ្តឹងសុំមោឃកម្ម និងសម្រេចទទួលពាក្យសុំមោឃកម្ម។ មានតែដីកាសម្រេចប៉ុណ្ណោះដែលអាចជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍បាន ប៉ុន្តែដីកាបង្គាប់ចេញដោយចៅក្រមស៊ើបសួរពុំអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បានឡើយ។ សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ត្រូវបានកម្រិតចំពោះជនត្រូវចោទដោយអាចប្តឹងឧទ្ធរណ៍បានចំពោះតែដីកាសម្រេចដែលបានកំណត់ក្នុងមាត្រា ២៦៧ (បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ) តែប៉ុណ្ណោះ។ រយៈពេលបណ្តឹងឧទ្ធរណ៍គឺ ១ខែ

[68] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សម្រាប់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ យ៉ាងយូរគិតពីពេលប្រកាសដីកា ៥ថ្ងៃ សម្រាប់ជនត្រូវចោទគិតចាប់ពីការជូនដំណឹងដីកា។ ចំពោះការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ មេធាវីជនត្រូវចោទ ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការជាន់ដំបូង យោងតាមមាត្រា២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ពុំនាំឲ្យនីតិវិធីនៃការស៊ើបសួរត្រូវផ្អាកទេលើកលែងតែបណ្ដឹងឧទ្ធរណ៍ ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរប៉ុន្តែប្រធានសភាស៊ើបសួរអាចសម្រេចឲ្យផ្អាកនីតិវិធីនៃការស៊ើបសួរបានក្នុងករណីមួយចំនួន។ ទន្ទឹមនឹងនេះ សេចក្ដីសម្រេចនេះមិនអាចប្ដឹងតវ៉ាបានឡើយ។[69]

## ៣.៤ ដំណាក់កាលជំនុំជម្រះ

ការសម្រេចសេចក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមជាប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន យោងតាមមាត្រា១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញ។ ដំណាក់កាលជំនុំជម្រះ គឺជាដំណាក់កាលមួយដ៏សំខាន់បន្ទាប់ពីដំណាក់ស៊ើបសួរត្រូវបានបិទបញ្ចប់។ ដំណាក់កាលនេះ ជាដំណាក់កាលដែលត្រូវសម្រេចអំពីការពិតណាមួយ និងការទទួលខុសត្រូវតាមផ្លូវច្បាប់។ លើសពីនេះ តុលាការព្រហ្មទណ្ឌអាចបើកសវនាការជំនុំជម្រះបានចំពោះជនណា ដែលបានបញ្ជូនមកក្នុងឋានៈជាជនជាប់ចោទប៉ុណ្ណោះ ហើយស្ថិតក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះមាន តួនាទីសម្រេចការចេញសាលក្រម។ ក្នុងដំណាក់កាលជំនុំជម្រះ មេធាវីក៏មានតួនាទីក្នុងការជជែកដេញដោល ការតទល់គ្នា ការទាញហេតុផល ដើម្បីការពារកូនក្ដីឲ្យរួចពីការផ្ដន្ទាទោសតាមរយៈការចេញសាលក្រមដែលត្រូវធ្វើឡើងនៅពេលសវនាការ។

ដំណាក់កាលជំនុជម្រះ មេធាវីមានភារកិច្ចការពារសិទ្ធិឲ្យជនជាប់ចោទ សម្រាប់ការពិនិត្យមើលអំពីការដឹកនាំនីតិវិធីសវនាការរបស់ចៅក្រមជំនុំជម្រះ និងធ្វើការតវ៉ាភ្លាមៗសម្រាប់ការដឹកនាំមិនត្រឹមត្រូវតាមច្បាប់កំណត់។ មេធាវីអាចតំណាងឲ្យជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការបានដើម្បីបំភ្លឺអង្គហេតុ ឬភស្តុតាងនានា។ មេធាវីជាអ្នកបំពេញកាតព្វកិច្ចមធ្យោបាយតាមផ្លូវច្បាប់ឲ្យកូនក្ដីរបស់ខ្លួនដើម្បីប្រើប្រាស់សិទ្ធិដែលច្បាប់បានប្រគល់ជូនភាគីនៃបណ្ដឹងជាអតិបរមាដែលអាចធ្វើទៅបាន។ ដូច្នេះ មេធាវីមានភារកិច្ចធ្វើយ៉ាងណាឲ្យកូនក្ដីរបស់ខ្លួនទទួលបានសិទ្ធិជំនុំជម្រះក្ដីដោយយុត្តិធម៌។

### ៣.៤.១ នីតិវិធីមុនពេលសវនាការ

#### ៣.៤.១.១ នីតិវិធីនៃការសម្រេចមុនអង្គសេចក្ដី

ក្រោយពីទទួលបានការជំនុំជម្រះដល់អង្គសេចក្ដី ក្រមនីតិវិធីព្រហ្មទណ្ឌបាន អនុញ្ញាតឲ្យជនជាប់ចោទ និងមេធាវីអាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំវិញបានដោយយោងតាមមាត្រា ៣០៧ នៃក្រមនីតិវិធីព្រហ្ម-

[69] មាត្រា ២៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ទណ្ឌ។ ចំពោះការដោះលែងឲ្យនៅក្រៅឃុំនេះ ជនជាប់ចោទអាចស្នើសុំដោយផ្ទាល់មាត់នាពេលសវនាការ ឬធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរ។ ប្រសិនបើពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់នាពេលសវនាការក្រឡាបញ្ជីត្រូវកត់ត្រាចូលក្នុងកំណត់ហេតុ។ តុលាការនឹងសម្រេចបន្ទាប់ពីទទួលបានពាក្យសុំ និងស្តាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ។ ចំពោះការសម្រេចត្រូវធ្វើឡើងជាសាលក្រមក្នុងរយៈពេល១០ថ្ងៃ ក្រោយពីការសុំដោយផ្ទាល់ ឬក្រោយពីទទួលពាក្យសុំដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយការសម្រេចសេចក្តីនេះតុលាការធ្វើឡើងដោយផ្អែកលើមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរ។

តុលាការអាចសម្រេចការដោះលែងជនជាប់ចោទ ក្រោយពីស្តាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ ព្រមទាំងព្រះរាជអាជ្ញា។ យោងតាមមាត្រា៣០៦ បញ្ញត្តិអំពីការដោះលែងជនជាប់ចោទដែលជាប់ឃុំឲ្យមានសេរីភាពដោយឯកឯងមានន័យថានៅគ្រប់ពេលវេលាតុលាការអាចបង្គាប់ឲ្យដោះលែងជនជាប់ចោទដែលជាប់ឃុំឲ្យមានសេរីភាពវិញបានឬបន្តការឃុំខ្លួនជាប់ចោទដោយយោងតាមមាត្រា២០៥ បញ្ញត្តិអំពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ៣.៤.២ នីតិវិធីក្នុងពេលសវនាការ

មុននឹងចាប់ផ្តើមសវនាការ ក្រឡាបញ្ជី ផ្ទៀងផ្ទាត់វត្តមានរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើម្បីរាយការណ៍ជូនតុលាការ។

តុលាការព្រហ្មទណ្ឌអាចបើកសវនាការជំនុំជម្រះបាន ចំពោះជនណាដែលបានបញ្ជូនមកក្នុងឋានៈជាជនជាប់ចោទប៉ុណ្ណោះ ហើយស្ថិតក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះមាន តួនាទីសម្រេចការចេញសាលក្រម។ ក្នុងដំណាក់កាលជំនុំជម្រះ មេធាវីក៏មានតួនាទីក្នុងការជជែកដេញដោល ការតទល់គ្នា ការទាញហេតុផល ដើម្បីការពារកូនក្តីឲ្យរួចពីការផ្តន្ទាទោសតាមរយៈការចេញសាលក្រម ដែលត្រូវធ្វើឡើងនៅពេលសវនាការ។ ក្រោយពីទទួលបានដំណឹងអំពីកាលបរិច្ឆេទនៃការចូលបង្ហាញខ្លួន ជនជាប់ចោទត្រូវបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។[70] មេធាវី ត្រូវនៅអមជនជាប់ចោទបន្ទាប់ពីទទួលបានជ្រើសរើស ឬស្នើសុំឲ្យតុលាការចាត់តាំងខ្លួនជាមេធាវីជំនួស ប៉ុន្តែជនជាប់ចោទអាចមិនត្រូវការមេធាវីបើខ្លួនយល់ថាអាចការពារខ្លួនបាននៅចំពោះមុខតុលាការ។ ករណីបទឧក្រិដ្ឋ ឬកាលណាជនជាប់ចោទជាអនីតិជន ការមិនមានមេធាវីមិនត្រូវបានអនុវត្តឡើយ។

[70] មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

មេធាវីជនជាប់ចោទ ត្រូវមានវត្តមាននៅពេលដែលប្រធានសវនាការធ្វើការសួរចម្លើយនៅចំពោះមុខព្រះរាជអាជ្ញា និងក្រឡាបញ្ជីលើកលែងតែជនជាប់ចោទបោះបង់សិទ្ធិមានមេធាវី។ លើសពីនេះការសួរចម្លើយត្រូវធ្វើកំណត់ហេតុ ដោយផ្អែកលើមាត្រា២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានតំណាងដោយមេធាវីផងដែរ។

### ៣.៤.២.១ ការពិភាក្សាដេញដោល

ចំពោះការពិភាក្សាដេញដោល ដែលធ្វើឡើងនាពេលសវនាការនេះមានវត្តមានដូចជា ក្រឡាបញ្ជី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី ជនជាប់ចោទ និងមេធាវី។ កំណត់ហេតុសវនាការរៀបរាប់អំពីដំណើរប្រព្រឹត្តទៅនៃសវនាការ និងសំណួរចម្លើយដល់ជនពាក់ព័ន្ធនៅក្នុងសវនាការ យោងតាមមាត្រា៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល ១០ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម។

តួនាទីរបស់មេធាវីនៅក្នុងការពិភាក្សាដេញដោល គឺមានលក្ខណៈដូចគ្នានឹងព្រះរាជអាជ្ញាដែរ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀតត្រូវបានសួរតាមរយៈប្រធានសវនាការ។ មេធាវីត្រូវបានអនុញ្ញាតឲ្យសួរសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីក៏បានផ្តល់សិទ្ធិក្នុងការសាកសួរចម្លើយពីសាក្សីដែលពាក់ព័ន្ធ ហើយក្រៅពីសំណួរមេធាវីសំណួរផ្សេងទៀតត្រូវបានសួរតាមរយៈប្រធានសវនាការភាគីអាចសុំឲ្យតុលាការស្តាប់ចម្លើយសាក្សីប៉ុន្តែត្រូវមានការយល់ព្រមពីប្រធានសវនាការ។

ពេលចាប់ផ្តើមបើកការជំនុំជម្រះ ចៅក្រមប្រាប់ជនជាប់ចោទពីកាតព្វកិច្ចដែលត្រូវនិយាយទាក់ទងនឹងបទល្មើសដែលបានចោទ រួមទាំងសិទ្ធិទទួលបានមេធាវីការពារ និងសិទ្ធិថ្លែងសម្តីចុងក្រោយក៏ត្រូវបានប្រាប់ឲ្យបានដឹងនៅពេលនោះដែរ។ សិទ្ធិមានមេធាវីតំណាងត្រូវបានអនុញ្ញាត ដោយចៅក្រមត្រូវបញ្ជាក់ប្រាប់ជនរងគ្រោះពីសិទ្ធិរបស់គេដើម្បីបង្ហាញភស្តុតាង សិទ្ធិធ្វើសំណូមពរ។ អំឡុងពេលចៅក្រមចាប់ផ្តើមសួរទៅកាន់ជនជាប់ចោទទាក់ទងនឹងដំណើររឿងដែលគេចោទថាបានប្រព្រឹត្តបទល្មើសនោះ ជនជាប់ចោទអាចឆ្លើយទទួលពិរុទ្ធភាព ឬមិនទទួលយកបទចោទប្រកាន់ក៏បាន។ ករណីជនជាប់ចោទមិនទទួលបទចោទទេ ចៅក្រមនឹងហៅមេធាវីការពារជនជាប់ចោទរួចហើយ មេធាវីការពារជនជាប់ចោទ និងមេធាវីការពារជនរងគ្រោះអាចធ្វើការសួរសំណួរទៅជនរងគ្រោះតែម្តង។

ជាពិសេសមេធាវីជនជាប់ចោទអាចសួរសំណួរដោយផ្ទាល់ទៅជនជាប់ចោទ ឬសាក្សីបន្ទាប់ពីមានការយល់ព្រមពីចៅក្រម។ ក្រោយពីបានស្នើសុំទៅចៅក្រមរួចហើយមេធាវីការពារជនជាប់ចោទឡើងថ្លែងការពារជន

ជាប់ចោទដោយផ្តល់ភស្តុតាង ហៅសាក្សី និងធ្វើការជំទាស់ពាក្យចោទប្រកាន់។ នៅចំណុចនេះប្រសិនបើចាំបាច់ចៅក្រមអាចស្នើសុំឲ្យសាក្សី និងជនជាប់ចោទសួរតទល់គ្នា។

ជនជាប់ចោទ ឬមេធាវីការពារជនជាប់ចោទមានសិទ្ធិដូចព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីដែរ ក្នុងការលើកអញ្ញត្រកម្មមួយមកដោះស្រាយ ប៉ុន្តែអញ្ញត្រកម្មត្រូវលើកឡើងមុនដំណាក់កាលការពារដល់អង្គសេចក្តីបើពុំដូច្នេះមិនអាចទទួលយកបានទេ។[71] អញ្ញត្រកម្ម គឺជាមធ្យោបាយមួយដែលភាគីលើកឡើងដើម្បីទាមទារឲ្យចៅក្រមពិនិត្យមើលសំអាងរបស់ភាគីម្ខាងទៀត ពិនិត្យមើលអសមត្ថកិច្ចរបស់តុលាការ ឬភាពមិនប្រក្រតីនៃនីតិវិធីជាដើម។ បន្ទាប់មក ចៅក្រមស្តាប់ភាគី និងសាក្សីទាំងសងខាងហើយសុំឲ្យភាគីទាំងអស់ធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ បើសិនជាមានភស្តុតាងគ្រប់គ្រាន់។ ក្រោយពេលចៅក្រមធ្វើសេចក្តីសន្និដ្ឋានអំពីទោសទណ្ឌកម្មរួចហើយ មេធាវីការពារក្តីរបស់ជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានចុងក្រោយគេ។

### ៣.៤.២.២ សិទ្ធិនិយាយខាងបន្តបន្ទាប់

ក្រោយពីបានពិភាក្សាដេញដោល ប្រធានសវនាការបានបើកឲ្យដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ខ្លីៗ។

- មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានការពារ
- ព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ
- មេធាវីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ

បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចធ្វើការឆ្លើយតបទៅវិញហើយ ប៉ុន្តែជនជាប់ចោទ និងមេធាវីរបស់ខ្លួនត្រូវនិយាយក្រោយគេបង្អស់។ ក្រោយមក តុលាការត្រូវធ្វើការពិភាក្សាដើម្បីសម្រេចសេចក្តី។ ចាប់ពីពេលនេះតទៅគ្មានបណ្តឹងសុំណាមួយត្រូវដាក់ជូនតុលាការបានឡើយ យោងតាមមាត្រា៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ៣.៤.២.៣ សេចក្តីសន្និដ្ឋានរបស់មេធាវី

បន្ទាប់ពីកិច្ចពិភាក្សាដេញដោល ភាគីទាំងអស់មានឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន។ សេចក្តីសន្និដ្ឋានចុងក្រោយត្រូវធ្វើតាមលំដាប់លំដោយដែលមានចែងក្នុងមាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដូចតទៅ៖

១. ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ខ្លី

[71] មាត្រា ៣៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

២. មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋានការពារ

៣. ព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

៤. មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋានការពារ

៥. មេធាវីរបស់ជនត្រូវចោទធ្វើសេចក្ដីសន្និដ្ឋានការពារ

មុនពេលចៅក្រមធ្វើការសម្រេចសេចក្ដី មេធាវីត្រូវធ្វើសេចក្ដីសន្និដ្ឋានការពារកូនក្ដីដែលមេធាវីនឹងស្នើទៅតុលាការមានដូចជា សុំឲ្យមានសំណងជម្ងឺចិត្ត និងអាចធ្វើការបដិសេធចំពោះពាក្យចោទរបស់ភាគីម្ខាងទៀតបាន។ ការសន្និដ្ឋានរបស់មេធាវីអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ ចំពោះសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមេធាវីអាចធ្វើឡើងនៅពេលសវនាការ ឬក្រោយពេលសវនាការក៏បាន។

ការប្រកាសសាលក្រម ត្រូវធ្វើនៅពេលសវនាការដែលធ្វើការពិភាក្សាដេញដោល ឬក៏នៅពេលសវនាការលើកក្រោយដែលកាលបរិច្ឆេទកំណត់ប្រធានសវនាការ។[72] ការប្រកាសសាលក្រមលើអង្គសេចក្ដីអាចធ្វើតាមរយៈសាលក្រមចំពោះមុខ សាលក្រមចាត់ទុកថាចំពោះមុខ និងសាលក្រមកំបាំងមុខ។ សាលក្រមជាសេចក្ដីសម្រេចចុងក្រោយបង្អស់នៃដំណើរការនីតិវិធីតាំងពីពេលចាប់ផ្ដើមរហូតត្រូវបានបញ្ចប់។ បន្ទាប់ពីសាលក្រមបានចូលជាស្ថាពរហើយ ពិរុទ្ធជនអាចប្ដឹងទាស់សាលក្រមដែលប្រកាសដោយកំបាំងមុខមានរយៈពេល ១៥ថ្ងៃដោយផ្អែកលើមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ៣.៥ ដំណាក់កាលក្រោយពេលសវនាការ

### ៣.៥.១ កិច្ចនីតិវិធីការពារឲ្យជនជាប់ចោទ

បន្ទាប់ពីតុលាការចេញសាលក្រមសម្រេចរួច មេធាវីនៅតែបន្តតួនាទីរបស់ខ្លួនក្នុងការណែនាំបង្ហាញផ្លូវទាក់ទងនឹងសិទ្ធិក្នុងការធ្វើបណ្ដឹងតវ៉ាដល់កូនក្ដីរបស់ខ្លួនករណីកូនក្ដីមិនសុខចិត្តនឹងសេចក្ដីសម្រេចតុលាការ។

មេធាវី ត្រូវធ្វើការពន្យល់ណែនាំទាក់ទងនឹងសាលក្រមដែលបានចេញដោយតុលាការរួចហើយនោះដល់កូនក្ដីឲ្យបានយល់ច្បាស់អំពីការសម្រេចសេចក្ដីរបស់តុលាការចំពោះរឿងក្ដី។ មេធាវីក៏ត្រូវពន្យល់បន្ថែមអំពីនីតិវិធីនៃការធ្វើបណ្ដឹងតវ៉ាដើម្បីឲ្យកូនក្ដីបានយល់ពីនីតិវិធីនៃការតវ៉ាតទៅមុខទៀត បើសិនជាកូនក្ដីមិនមានការសុខចិត្តក្នុងការទទួលយកសាលក្រមរបស់សាលាដំបូងដែលបានចេញរួចហើយនោះ។

[72] មាត្រា ៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ជាគោលការណ៍ បណ្តឹងតវ៉ានេះអាចធ្វើទៅបានក្នុងករណីដែលតុលាការបើកសវនាការជំនុំជម្រះលើពិរុទ្ធជន ឬជនជាប់ចោទណាម្នាក់ ដោយកំបាំងមុខទើបពិរុទ្ធជនអាចធ្វើការប្តឹងឲ្យតុលាការជំនុំជម្រះឡើងវិញបាន។ ហេតុនេះ នាំឲ្យបណ្តឹងតវ៉ាត្រូវបានធ្វើឡើងយ៉ាងទូលាយហើយមានពីរប្រភេទដែលក្នុងនោះមានដូចជា៖ បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍។

### ៣.៥.១.១ បណ្តឹងទាស់

ក្រោយពីសាលក្រមត្រូវបានប្រកាសហើយនោះ ភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌអាចប្តឹងទាស់បានក្នុងករណីដែលសាលក្រមនោះត្រូវបានប្រកាសដោយកំបាំងមុខ។ យោងតាមមាត្រា៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌករណីសាលក្រមត្រូវបានប្រកាសដោយកំបាំងមុខ ពិរុទ្ធជនអាចធ្វើការប្តឹងទាស់បាន។

មេធាវី ត្រូវបានតំណាងឲ្យពិរុទ្ធជនក្នុងការដាក់ពាក្យបណ្តឹងទាស់ ប៉ុន្តែត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើបណ្តឹងទាស់ជាមុនទើបបាន។ បណ្តឹងទាស់ត្រូវបានធ្វើឡើងតាមរយៈពាក្យបណ្តឹង ដោយមេធាវីត្រូវរៀបចំពាក្យបណ្តឹងមានលក្ខណៈជាលាយលក្ខណ៍អក្សរ ហើយយកពាក្យបណ្តឹងទាស់នោះដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម និងនៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ។ ករណី ពិរុទ្ធជនជាអនីតិជនអាចត្រូវបានតំណាងដោយមានឪពុកម្តាយ ឬអាណាព្យាបាល ពុំចាំបាច់មានលិខិតប្រគល់សិទ្ធិឡើយ។

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចតំណាងដោយមេធាវី និងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្តឹងទាស់។ បណ្តឹងទាស់អាចធ្វើក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យសាមីខ្លួនដោយផ្ទាល់ ឬថ្ងៃដែលសាមីខ្លួនបានដឹងប្រាកដអំពីសាលក្រម កាលណាសាលក្រមមិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ទេ។ សំណុំរឿងដែលជាកម្មវត្ថុនៃបណ្តឹងទាស់នឹងត្រូវលើកយកមកជំនុំជម្រះនៅតុលាការ ហើយភាគីទាំងអស់ត្រូវចូលរួមតាមរយៈការកោះហៅរបស់ព្រះរាជអាជ្ញា។ ករណីកោះហៅត្រូវបានអនុវត្តត្រឹមត្រូវហើយ ប៉ុន្តែអ្នកប្តឹងទាស់អវត្តមាននៅអំឡុងពេលសវនាការនាំឲ្យបណ្តឹងទាស់ត្រូវបានតុលាការចាត់ទុកថាជាឯកសារឥតបានការ និងតម្កល់សាលក្រមដែលប្តឹងទាស់នោះទុកជាបានការ។[73] ម្យ៉ាងវិញទៀត សាលក្រមដែលប្តឹងទាស់មិនអាចធ្វើការកែប្រែបានឡើយ និងមានអានុភាពចំពោះភាគីទាំងអស់។ លើសពីនេះសាលក្រមដែលសម្រេចលើបណ្តឹងទាស់អាចប្តឹងឧទ្ធរណ៍បានក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[73] មាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.៥.១.២ បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ ជាបណ្តឹងដែលសំណុំរឿងត្រូវបានផ្ទេរទៅសាលាឧទ្ធរណ៍នៅក្នុងព្រំដែន ដែលបានកំណត់ចំពោះការប្តឹងឧទ្ធរណ៍។ មេធាវីអាចតំណាងឲ្យពិរុទ្ធជនបន្ទាប់ពីមានលិខិតប្រគល់សិទ្ធិធ្វើជាអ្នកតំណាងក្នុងការប្តឹងឧទ្ធរណ៍។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវ ក៏អាចតំណាងដោយមេធាវីខ្លួនតាមរយៈលិខិតប្រគល់សិទ្ធិផងដែរ។

ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍តាមរយៈមេធាវីរបស់ខ្លួនបានក្នុងរយៈពេល ១ខែ គិតចាប់ពីពេលដែលសាលក្រមត្រូវបានប្រកាស បើសាលក្រមនោះជាសាលក្រមចំពោះមុខ ឬគិតពីពេលទទួលដំណឹងសាលក្រម ករណីសាលក្រមនោះជាសាលក្រមចាត់ទុកចំពោះមុខ។ ហេតុនេះ យោងតាមមាត្រា ៣៨២ សាលក្រមកំបាំងមុខមិនអាចប្តឹងឧទ្ធរណ៍បានឡើយ មានតែសាលក្រមចំពោះមុខ និងសាលក្រមចាត់ទុកចំពោះមុខប៉ុណ្ណោះដែលអាចប្តឹងឧទ្ធរណ៍បាន។ ករណីអនុវត្តជាក់ស្តែង ទោះបីសាលក្រមកំបាំងមុខក៏អាចធ្វើការប្តឹងឧទ្ធរណ៍បានដែរ។ នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រមរួចហើយ ក្រឡាបញ្ជីនឹងធ្វើការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ នៅក្នុងរយៈពេលមួយដែលខ្លីបំផុតទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។[74] បន្ទាប់ពីទទួលបានសំណុំរឿង នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍ត្រូវចាប់ផ្តើមកំណត់កាលបរិច្ឆេទសវនាការរហូតដល់ការប្រកាសសាលដីកា។

### ៣.៥.២ កិច្ចនីតិវិធីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

មេធាវី មានតួនាទីសកម្មបំផុតនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ មេធាវីជាអ្នកធ្វើសកម្មភាពរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងបណ្តឹង។ មេធាវីអាចជាអ្នកដាក់ពាក្យបណ្តឹង អាចជាអ្នករៀបចំឯកសារ មេធាវីជាអ្នកឆ្លើយដោះសារ ឆ្លើយការពារ ឬជាអ្នកផ្តល់យោបល់តាមផ្លូវច្បាប់ ដើម្បីឲ្យភាគីយល់ដឹងពីខ្លឹមសារច្បាប់នោះបានច្បាស់លាស់។ មេធាវីជាអ្នកបង្ហាញផ្លូវដើម្បីឲ្យភាគីអនុវត្តសិទ្ធិនោះពេញលេញ ត្រឹមត្រូវមានភាពសុចរិតចំពោះបណ្តឹងរបស់ខ្លួន។

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺជាជនរងគ្រោះដែលចូលរួមក្នុងនាមជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ។ ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិទូលំទូលាយស្រដៀងគ្នាទៅនឹងសិទ្ធិរបស់សហព្រះរាជអាជ្ញា និងក្រុមចុងចោទដែរ ហើយដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំបាននូវសំណងផ្លូវចិត្ត និង

[74] មាត្រា ៣៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌទី២ ឆ្នាំ២០០៧

សំណងសមូហភាព។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិមានអ្នកតំណាងម្នាក់ជាមេធាវីជនជាតិខ្មែរ ឬមេធាវីអន្តរជាតិ។ នៅក្នុងដំណាក់កាលស៊ើបអង្កេត ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសហចៅក្រមស៊ើបអង្កេតឲ្យស្តាប់ចម្លើយរបស់ខ្លួន សាកសួរសាក្សី ចុះទៅទីតាំងឧក្រិដ្ឋកម្ម ឬប្រមូលភស្តុតាងផ្សេងទៀតតាងនាមឲ្យខ្លួន។

### ៣.៥.២.១ ការជូនដំណឹងដល់ជនត្រូវចោទសងសំណង

នៅក្នុងរឿងក្តីព្រហ្មទណ្ឌពិតណាស់គឺតែងតែមានការប្តឹងទាមទារសំណងរដ្ឋប្បវេណី ដោយដើមបណ្តឹងរដ្ឋប្បវេណីទៅតាមបែបបទនៃរឿងក្តីដែលបានកើតឡើង។ សម្រាប់ការជូនដំណឹងដល់ជនត្រូវចោទសងសំណងនៅក្នុងបណ្តឹងរដ្ឋប្បវេណី នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីពឹងពាក់អ្នកតំណាង ដែលជាមេធាវីហើយនោះមេធាវីនឹងចាត់ចែងគ្រប់កិច្ចនីតិវិធី។ ជំហានទី១ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើនោះ គឺដាស់តឿនដោយដាក់ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿននៅសាលាដំបូង និងកំណត់ពេលសងជាថ្មី ដែលអាចមានមួយសប្តាហ៍ឬ ១០ ថ្ងៃជាដើម។[75] បើកូនបំណុលហាក់គ្មានឆន្ទៈសង ហើយមានការបំពានកាន់តែងខ្លាំងពេលនោះដើមបណ្តឹងរដ្ឋប្បវេណីអាចពិគ្រោះជាមួយមេធាវី ដើម្បីធ្វើវិធានការបន្តក្នុងការប្តឹងទៅតុលាការជាដើម។ មួយវិញទៀតប្រសិនបើប្តឹងទៅតុលាការហើយកូនបំណុលគ្មានទ្រព្យសម្បត្តិសងទេ ទោះបីម្ចាស់បំណុលឈ្នះក្តីក៏ដោយក៏ម្ចាស់បំណុលមិនដឹងថាយកសាលក្រមនោះ ឬយកសេចក្តីសម្រេចរបស់តុលាការទៅអនុវត្តដើម្បីរឹបអូសទ្រព្យសម្បត្តិកូនបំណុលបានដែរ។ មានន័យថាបើកូនបំណុលជំពាក់លុយ១ ម៉ឺនដុល្លារយើងអាចយល់ដឹងពីទ្រព្យសម្បត្តិរបស់កូនបំណុលមានដូចជា ផ្ទះ ឡានឬលុយនៅក្នុងធនាគារ ជាអាទិ៍ វិធានការដែលយើងត្រូវធ្វើមុនគេគឺពាក់ព័ន្ធជាមួយនឹងប្រព័ន្ធរក្សាការពារ។ ដើម្បីរឹបអូសទ្រព្យរបស់កូនបំណុលទុកធានាសងសិទ្ធិលើបំណុលរបស់យើងនៅពេលដើមបណ្តឹងរបស់យើងបានចប់សព្វគ្រប់។

### ៣.៥.២.២ ការដាក់ពាក្យសុំអនុវត្តបង្ខំលើរូបកាយ

ការបង្ខំដល់រូបកាយគឺមានលក្ខខណ្ឌដូចទៅនឹងការជាប់ពន្ធនាគារដែរ ហើយអាចអនុវត្តទៅបានក្នុងករណីដែលបុគ្គល ឬទណ្ឌិតដែលត្រូវផ្តន្ទាទោសមិនបានបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី។[76]

ក្នុងករណីនេះដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំអនុវត្តបង្ខំលើរូបកាយ កាលណាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណងជម្ងឺចិត្តពីទណ្ឌិតទេ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងទៅព្រះរាជអាជ្ញាដើម្បីឲ្យធ្វើការបង្ខំលើរូបកាយ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវជូនភស្តុតាងដល់ព្រះរាជអាជ្ញាថាខ្លួនបានប្រើ

[75] មាត្រា ៣២០ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[76] មាត្រា ៥២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

គ្រប់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬអចលនវត្ថុជាដើម។ ទោះបីទណ្ឌិតដែលទទួលការបង្ខំលើរូបកាយនោះនៅតែជំពាក់ទឹកប្រាក់ដែលត្រូវបង់ក្តី ក៏ទណ្ឌិតមិនត្រូវទទួលការបង្ខំលើរូបកាយចំពោះបំណុលនោះទៀតដែរ ដោយផ្អែកលើមាត្រា៥៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ៣.៥.២.៣ ការដាក់ពាក្យសុំអនុវត្តលើទ្រព្យសម្បត្តិ

ប្រសិនបើមេធាវីមើលឃើញថាកូនបំណុលហាក់គ្មានឆន្ទៈសង ហើយមានការបំពានកាន់តែងខ្លាំងពេលនោះ មេធាវីដែលជាអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើវិធានការក្នុងការដាក់ពាក្យសុំអនុវត្តដោយបង្ខំលើទ្រព្យសម្បត្តិ ហើយប្រសិនបើកូនបំណុលគ្មានទ្រព្យសម្បត្តិទេមេធាវីអាចសុំដាក់ពាក្យអនុវត្តចំពោះអចលនវត្ថុរបស់កូនកំណុល។ ក្នុងករណីដាក់ពាក្យសុំអនុវត្តចំពោះអចលនវត្ថុមេធាវីត្រូវដាក់ឯកសារដែលហៅថា " ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ" ។ ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ ហើយនៅក្នុងពាក្យសុំឲ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចជា៖

ក- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការការអនុវត្ត និងកូនបំណុលនៃការអនុវត្តហើយឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ- សញ្ញាណនៃលិខិតអនុវត្ត

គ- សេចក្តីសុំឲ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល

ឃ-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។

ង- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឲ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឲ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និង ទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឲ្យអនុវត្តដោយបង្ខំ ដោយយោងតាមមាត្រា ៣៤៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សម្រាប់ទីកន្លែងដែលត្រូវដាក់ពាក្យសុំក្នុងការអនុវត្តចំពោះអចលនវត្ថុ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃអចលនវត្ថុគឺតុលាកាអនុវត្តពាក្យសុំអនុវត្តដោយបង្ខំត្រូវដាក់ទៅតុលាការអនុវត្តនោះ។[77] សម្រាប់ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យសុំមាន លិខិតអនុវត្ត លិខិតបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្តរូបមន្តអនុវត្ត និងពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ។

[77] មាត្រា ៤១៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់បំផុត ក៏ដូចជាការសរសេរយ៉ាងលម្អិតជាប់ទាក់ទងទៅនឹងតួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូងរួចមកគឺ យើងខ្ញុំអាចធ្វើសេចក្តីសន្និដ្ឋានបានថាមេធាវីគឺជាបុគ្គលដែលសំខាន់ក្នុងការការពារ និងស្វែងរកយុត្តិធម៌ដល់កូនក្តីដែលខ្លួនតំណាងចាប់តាំងពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ការប្រកាសសាលក្រម មេធាវីគឺមានតួនាទីនៅអមជាមួយតំណាងកូនក្តីរបស់ខ្លួនជានិច្ចដើម្បីការពារប្រយោជន៍ដល់ពួកគេ។

មេធាវី គឺជាបុគ្គលដែលមានវិជ្ជាជីវៈផ្នែកច្បាប់ និងជាបុគ្គលដែលមានចំណេះដឹងជ្រៅជ្រះទូលំទូលាយនៅក្នុងសង្គមជាតិ ជាពិសេសមេធាវីអាចធ្វើការដោះស្រាយបញ្ហាទាក់ទងនឹងទំនាស់ផលប្រយោជន៍ ជាជំនួយឬការចោទប្រកាន់ណាមួយដោយអយុត្តិធម៌ និងជាអ្នកផ្តល់ការប្រឹក្សាយោបល់ធ្វើការណែនាំផ្នែកច្បាប់ដល់បុគ្គលគ្រប់រូប។ មេធាវីក៏ជាអ្នកផ្តល់យោបល់ ឬទីប្រឹក្សាដល់គូភាគីដែលមានជម្លោះដែលត្រូវការការណែនាំ និងផ្តល់យោបល់ផ្នែកច្បាប់ដើម្បីការពារផលប្រយោជន៍របស់ពួកគេបាន។ ដើម្បីអាចក្លាយជាអ្នកប្រកបវិជ្ជាជីវៈមេធាវីបាននោះគឺត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីទើបមេធាវីអាចប្រកបវិជ្ជាជីវៈនេះបាន។

មេធាវីក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួន មេធាវីត្រូវតែទទួលបាននូវសិទ្ធិគ្រប់គ្រាន់ដើម្បីការពារខ្លួនពីបទចោទ ឬការដាក់គំនាបណាមួយ។ ដែលសិទ្ធិទាំងនោះមានចែងនៅក្នុង"គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី" ។ ហើយសិទ្ធិទាំងនោះរួមមានៈ សិទ្ធិក្នុងការបំពេញមុខវិជ្ជាជីវៈដោយគ្មានការជ្រៀតជ្រែក សិទ្ធិក្នុងការទទួលបានការការពារ សិទ្ធិទទួលបានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌ សិទ្ធិក្នុងការតំណាងកូនក្តី សិទ្ធិក្នុងការទទួលបានកូនក្តី និងព័ត៌មានចាំបាច់សំរាប់ការពារកូនក្តី សិទ្ធិមិនត្រូវសំដែងមានសមានចិត្តជាមួយកូនក្តី ឬបុព្វហេតុរបស់កូនក្តី សិទ្ធិក្នុងការទទួលបានការសម្ងាត់ផ្នែកវិជ្ជាជីវៈមេធាវីៈ សិទ្ធិទទួលបានការអប់រំ និងការបណ្តុះបណ្តាល សិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម។ សិទ្ធិទាំងនេះគឺដើម្បីឲ្យមេធាវីមានឯករាជ្យភាពនៃការប្រកបវិជ្ជាជីវៈបានល្អ និងមិនស្ទាក់ស្ទើរក្នុងការតំណាងជូនកូនក្តីរបស់ខ្លួន។

មេធាវីក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ វត្តមានរបស់មេធាវីការពារក្តីគឺមានសារៈសំខាន់ និងចាំបាច់បំផុតសម្រាប់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ពិរុទ្ធជន ដើម្បីរួមចំណែកក្នុងការធានាថា កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលទាំងនោះបានប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌។ ក្នុងរឿងក្តី

ព្រហ្មទណ្ឌ មេធាវីមានតួនាទីយ៉ាងសំខាន់ក្នុងការណែនាំកូនក្តីរបស់ខ្លួនអំពីសិទ្ធិ និង ករណីយកិច្ចផ្សេងៗដែលអាចអនុវត្តបានក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។ មេធាវីត្រូវមានវត្តមានចាប់តាំងពីពេលដែលជនត្រូវចោទ ឬជនជាប់ចោទ ត្រូវបានឃាត់ខ្លួនដោយនគរបាលយុត្តិធម៌ រហូតដល់ការចេញសេចក្តីសម្រេចរបស់តុលាការថាតើជនត្រូវចោទមានកំហុស ឬក៏គ្មាន។ ក្នុងករណីដែលមេធាវីជាអ្នកការពារសិទ្ធិឲ្យជនល្មើស មេធាវីមានតួនាទីចូលរួមពិនិត្យមើលអំពីការទទួលស្គាល់ និងប្រើប្រាស់សិទ្ធិសម្រាប់ជនល្មើសពីសំណាក់អាជ្ញាធរសមត្ថកិច្ចតាមដំណាក់កាលនីតិវិធី។ នៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម មេធាវីអមជាមួយជនជាប់សង្ស័យដែលជននេះ ផ្តល់ចម្លើយតាមការសាកសួរពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា ប៉ុន្តែក្នុងករណីដែលជនជាប់សង្ស័យគ្មានមេធាវីហើយត្រូវបានឃាត់ខ្លួន ឬជនល្មើសត្រូវបានឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែងជននេះអាចមានសិទ្ធិមានមេធាវីបានបន្ទាប់ពីមានការឃាត់ខ្លួនក្នុងរយៈពេល ២៤ម៉ោងកន្លងផុត។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាបានធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើហិង្សាដើម្បីឲ្យជនល្មើស ឬជនជាប់សង្ស័យផ្តល់ចម្លើយតាមការបង្ខំ ឬឲ្យឆ្លើយសារភាព មេធាវីអាចប្តឹងលើកំណត់ហេតុនោះទុកជាមោឃៈដើម្បីដកចេញពីសំណុំរឿង។ កំណត់ហេតុនៅដំណាក់កាលស៊ើបអង្កេត ជាឯកសារដើមដែលត្រូវបានរក្សាទុកក្នុងសំណុំរឿង ហេតុនេះកាលណាគ្មានភស្តុតាងផ្ទុយទេតុលាការនឹងសម្រេចដោយយោងទៅលើកំណត់ហេតុនោះដែលជាភស្តុតាងដាក់បន្ទុក។ ក្នុងដំណាក់កាលចៅក្រមស៊ើបសួរ មេធាវីមានតួនាទីត្រួតពិនិត្យអំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការការពារសិទ្ធិរបស់ជនត្រូវចោទដែលជាកូនក្តីរបស់ខ្លួនជៀសវាងមានការបំពានសិទ្ធិរបស់ជនត្រូវចោទ។ មេធាវី មានសិទ្ធិដឹងរាល់ការសម្រេចរបស់ចៅក្រមស៊ើបសួរលើជនត្រូវចោទតាមរយៈការជូនដំណឹង។ រីឯដំណាក់កាលជំនុំជម្រះមេធាវីមានភារកិច្ចការពារសិទ្ធិឲ្យជនជាប់ចោទសម្រាប់ការពិនិត្យមើលអំពីការដឹកនាំនីតិវិធីសវនាការរបស់ចៅក្រមជំនុំជម្រះ និងធ្វើការតវ៉ាភ្លាមៗសម្រាប់ការដឹកនាំមិនត្រឹមត្រូវតាមច្បាប់កំណត់។ មេធាវីអាចធ្វើការប្តឹងឧបាស្រ័យលើការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះតាមរយៈការប្រគល់សិទ្ធិពីកូនក្តីរបស់ខ្លួន។

សរុបរួមមកមេធាវីជាអ្នកវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌នឹងជួយពង្រឹងនីតិរដ្ឋដល់សង្គមជាតិតាមរយៈបទបញ្ញត្តិច្បាប់ជាធរមាន។ ហើយមេធាវីមានភារកិច្ចធ្វើយ៉ាងណាឲ្យកូនក្តីរបស់ខ្លួនទទួលបានសិទ្ធិជំនុំជម្រះក្តីដោយយុត្តិធម៌។ មិនតែប៉ុណ្ណោះមេធាវីមិនត្រឹមតែជាអ្នកតំណាង និង ជួយការពារក្តីទេប៉ុន្តែថែមទាំងមានតួនាទីសំខាន់ក្នុងការបង្កើតវិធានច្បាប់ក្នុងសង្គមទៀតផង។ ហើយពិតណាស់មេធាវីក៏ជាបុគ្គលមួយរូបដែលអាចផ្តល់ការប្រឹក្សាយោបល់នូវគំនិតល្អៗដោយស្របតាមមូលដ្ឋានច្បាប់លើគ្រប់វិស័យ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងធ្វើការស្វែងយល់អំពីតួនាទីមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូងយ៉ាងលម្អិត ក៏ដូចជាការធ្វើសេចក្តីសន្និដ្ឋានរួមមក ក្រុមយើងខ្ញុំយល់ឃើញថា ការអនុវត្តន៍តាមច្បាប់ ក៏ដូចជាកិច្ចនៃនីតិវិធីក្នុងដំណើរនៃរឿងក្តីព្រហ្មទណ្ឌ គឺប្រព្រឹត្តទៅដោយរលូន និងមានភាពប្រទាក់ក្រឡាគ្នារហូតដល់ចប់នីតិវិធី ប៉ុន្តែនៅតែមានបញ្ហាប្រឈមក្នុងការអនុវត្តន៍ក្នុងកិច្ចនីតិវិធី ដោយការអសកម្មពាក់ព័ន្ធនិងបញ្ហាបច្ចេកទេស ស្ថាប័ន និងការរួមសហការ ដែលជាហេតុធ្វើឲ្យមានការចន្លោះប្រហោង និងយឺតយ៉ាវក្នុងការបំពេញការងាររបស់មន្ត្រីគ្រប់ជាន់ថ្នាក់ជាពិសេសគឺមេធាវីផ្ទាល់។ ដើម្បីជាការរួមចំណែកធ្វើឲ្យកាន់តែប្រសើរឡើងក្នុងវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំជានិស្សិតសរសេរសារណាសូមចូលរួមជាគំនិតខ្លះៗដើម្បីបានផ្តល់ជាអនុសាសន៍បន្ថែមទៅលើចំណុចខ្វះខាតទាំងនោះដូចជា៖

**ក. កង្វះខាតឧបករណ៍ បច្ចេកទេស មធ្យោបាយប្រើប្រាស់**

- ការងារមួយចំនួនអសកម្ម ដោយសារកង្វះខាតនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើង បានធ្វើឲ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលមានបទល្មើសកើតឡើង។
- សម្រាប់ការងារស៊ើបអង្កេត និងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបទៅតាមសំណូមពរ និងទិសដៅផែនការការងារនៅឡើយ។
- ក្នុងកិច្ចដំណើរការរបស់មេធាវី មិនទាន់បានរលូនល្អដោយសារនៅមានការមិនសហការពីមន្ត្រីគ្រប់ជាន់ថ្នាក់មួយចំនួនតូច។
- ដោយសារខ្វះមធ្យោបាយ សម្ភារៈ ថវិកា ដើម្បីបម្រើឲ្យកិច្ចប្រតិបត្តិការស្រាវជ្រាវធ្វើឲ្យការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌមិនទាន់ពេលវេលា ពេលខ្លះមានមធ្យោបាយតែខ្វះ ប្រេង សាំង យានជំនិះ ក្នុងការធ្វើដំណើរស្វែងរកភស្តុតាង។

**ខ. ការពង្រឹងការអនុវត្តច្បាប់**

- ការលុបបំបាត់អំពើពុករលួយ៖ យើងដឹងហើយថាជាគោលការណ៍ មន្ត្រីមានសមត្ថកិច្ច មិនត្រូវយកតួនាទីខ្លួនទៅការពារជនល្មើស ឬក្រុមប្រព្រឹត្តបទល្មើស ឬជនប្រព្រឹត្តសកម្មភាពចាប់ជំរិត លួច ឆក់ ប្លន់ កេងប្រវ័ញ្ចសម្បត្តិជាតិ ឬកេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃដែលស្របច្បាប់។ ហើយមន្ត្រីគ្រប់ជាន់ថ្នាក់គួរគប្បីសហការគ្នាក្នុងការស្វែងរកយុត្តិធម៌សម្រាប់បទល្មើសព្រហ្មទណ្ឌណាដែលកើតឡើងទាំង ឯកជន និងរឿងក្តីព្រហ្មទណ្ឌដែលប៉ះពាល់ដល់សម្បត្តិជាតិ។

- ពង្រឹង និងលុបបំបាត់វប្បធម៌អន្តរាគមន៍៖ សង្គមខ្មែរបច្ចុប្បន្ន គឺតែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប់វាគឺជាទម្លាប់របស់ពលរដ្ឋខ្មែរ។ អ្នកដែលមានអំណាច មានឋានៈ តួនាទីនៅក្នុងសង្គមមួយចំនួនតែងតែលូកលាន់នៅក្នុងកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាតុលាការដែលធ្វើឲ្យការបំពេញតួនាទីមិនទាន់បានល្អប្រសើរ។ ដើម្បីលុបបំបាត់នូវបញ្ហាទាំងនោះចាំបាច់ត្រូវពង្រឹង តួនាទីភារកិច្ច មន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់ជាមូលដ្ឋានគ្រឹះ។ បើមន្ត្រីណាម្នាក់ដែលមិនបានប្រតិបត្តិតាមច្បាប់ត្រូវតែទទួលខាងវិន័យ និងដាក់ទណ្ឌកម្មជាដាច់ខាតដោយមិនត្រូវលើកលែងឡើយ។

**គ. បង្កើតបន្ថែម បណ្តុះបណ្តាលជំនាញបច្ចេកទេស និង ច្បាប់**

- ការជ្រើសរើសមន្ត្រីតុលាការ៖ ក្នុងការជ្រើសរើសមន្ត្រីរាជការ ក្រឡាបញ្ជី ចៅក្រម ព្រះរាជអាជ្ញា ដើម្បីឲ្យបម្រើការងារនៅតាមស្ថាប័នតុលាការឲ្យបានគ្រប់ចំនួនព្រោះដើម្បីឲ្យដំណើរនៃនីតិវិធីតុលាការបានរលូនជាងនេះ ដោយយើងសង្កេតឃើញថាសព្វថ្ងៃនេះគឺមានការខ្វះមន្ត្រីផ្នែកតុលាការជាច្រើន។
- ការផ្សព្វផ្សាយវិស័យយុត្តិធម៌ឲ្យកាន់តែទូលំទូលាយ៖ កត្តាបណ្តុះបណ្តាល និងធ្វើការផ្សព្វផ្សាយពាក់ព័ន្ធទៅនឹងវិស័យយុត្តិធម៌គឺនៅមានភាពចង្អៀតនៅឡើយ មិនទាន់បានទូលំទូលាយនោះទេ ដូច្នេះត្រូវការការចូលរួមយ៉ាងសកម្ម អំពីសំណាក់ក្រសួងស្ថាប័នក៏ដូចជាបុគ្គលដែលមានសមត្ថកិច្ចធ្វើយ៉ាងណាបណ្តុះបណ្តាល ផ្សព្វផ្សាយច្បាប់ឲ្យបានដល់ប្រជាពលរដ្ឋទូទៅដើម្បីបានយល់ដឹង។
- ការផ្សព្វផ្សាយពីវិជ្ជាជីវៈមេធាវី៖ ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរយល់ដឹងអំពីសិទ្ធិខ្លួនក្នុងការទទួលបានការការពារពីសំណាក់បុគ្គលអ្នកច្បាប់ ដើម្បីឲ្យពួកគាត់យល់ថាគ្រប់ពេលដែលជួបរឿងអយុត្តិធម៌ត្រូវតែបង្ហាញហើយជឿជាក់ថាប្រទេសមានច្បាប់ក៏ដូចជាអ្នកតំណាងជាមេធាវីសម្រាប់ការពារខ្លួនជានិច្ច។
- ការបង្កើតនៅកន្លែងសម្រាប់បណ្តុះបណ្តាលជំនាញការពារក្តីសម្រាប់មេធាវី៖ ពិតណាស់ដើម្បីក្លាយជាមេធាវីបានលុះត្រាតែឆ្លងកាត់ការប្រឡង និងទទួលបានការបណ្តុះបណ្តាលជំនាញជាមុនសិនប៉ុន្តែដើម្បីឲ្យមេធាវីបង្កើននូវជំនាញ និងចំណេះផ្នែកច្បាប់ក្នុងការអនុវត្តន៍ ឬតំណាងឲ្យអតិថិជន គួរគប្បីតែបង្កើតកន្លែងបណ្តុះបណ្តាលជារួមសម្រាប់វិជ្ជាជីវៈមេធាវីក៏ដូចជាវិជ្ជាជីវៈដទៃទៀតជាប្រចាំខែ ឬ ឆ្នាំ។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

## ១. ឯកសារជាភាសាខ្មែរ

### ១.១. លិខិតបទដ្ឋានគតិយុត្ត

#### ក. អំពីក្រម

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ១៩៧២។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយរដ្ឋសភាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧។
- ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រៀបរៀងដោយគណៈមេធាវី ឆ្នាំ២០១២។

#### ខ. អំពីច្បាប់

- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីប្រកាសឲ្យប្រើដោយរដ្ឋសភា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។
- ច្បាប់ស្តីពី យុត្តិធម៌អនីតិជន ដែលអនុម័តដោយរដ្ឋសភា ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ២០១៦។
- ច្បាប់ស្តីពី ពន្ធនាគារ ដែលអនុម័តដោយរដ្ឋសភា ថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០០១។
- អនុក្រឹតស្តីពី ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឆ្នាំ ២០០៨។
- បទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រៀបរៀងដោយគណៈមេធាវី នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។
- សេចក្តីសម្រេចស្តីពីនីតិវិធីទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧។
- គោលការណ៍ជាមូលដ្ឋាន ស្តីពីតួនាទីរបស់មេធាវី ដែលត្រូវបានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការបង្ការបទល្មើស និងការប្រព្រឹត្តលើជនល្មើសដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងឡាហាវ៉ាន ប្រទេសគុយបា ចាប់ពីថ្ងៃទី២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែកញ្ញាឆ្នាំ១៩៩០ ហើយត្រូវបានតម្កល់ដោយសេចក្តីសម្រេចលេខ៤៨/១៣៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ របស់មហាសន្និបាត អ.ស.ប.។

- អនុសាសន៍ស្ដីពីសេចក្ដីព្រាងវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រៀបរៀងដោយគណៈកម្មាធិកាប្រព្រឹត្តកម្ម និងអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជាចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៦។

**គ. អំពីឯកសារជាសៀវភៅ និងអត្ថបទ**

- ឯកសារស្រាវជ្រាវសង្ខេបរបស់គណៈកម្មការទី៦នៃព្រឹទ្ធសភា ស្ដីពីតួនាទី និងភារកិច្ចរបស់មេធាវីនៅប្រទេសកម្ពុជា រៀបរៀងដោយវិទ្យាស្ថានសភាកម្ពុជា ខែកុម្ភៈ ឆ្នាំ២០១៧។
- ឯកសារមេរៀននីតិវិធីព្រហ្មទណ្ឌ បង្រៀនដោយសាស្ត្រាចារ្យ មីន សំអុល ឆ្នាំ២០២០។
- ឯកសារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាស្ដីពីស្ថិតិមេធាវី៖
https://www.bakc.org.kh/index.php/km/2020-02-02-04-06-24

**ឃ. អំពីវចនានុក្រម និង សន្ធានុក្រម**

- វចនានុក្រមខ្មែរ ដោយសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពផ្សាយដោយសាសនាបណ្ឌិត ភ្នំពេញ ឆ្នាំ១៩៦៧។
- វចនានុក្រមច្បាប់ ស្នាដៃនិពន្ធទី៦ ដោយ ហ៊ីង ធីឫទ្ធិ បោះពុម្ពលើកទី៤ ឆ្នាំ២០១៤។
- សន្ធានុក្រមពាក្យច្បាប់ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១២ សម្ព័ន្ធបញ្ញាវន្តដើម្បីអភិវឌ្ឍន៍ ឆ្នាំ២០១២។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំធ្វើកម្មសិក្សា

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....................អត្តលេខ........ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ..........ផ្លូវលេខ........ភូមិ.............សង្កាត់/ឃុំ.............ខណ្ឌ/ស្រុក.................រាជធានី/ខេត្ត................ ។

**សូមគោរពជូន**
**ឯកឧត្តមប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : សុំធ្វើកម្មសិក្សារយៈពេល១ឆ្នាំ ជាមួយលោក/លោកស្រី/កញ្ញាមេធាវី............អត្តលេខ........ ។

**យោង** : -មាត្រា ៣៥ និងមាត្រា ៣៦ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។
-ប្រការ៣៤ នៃសេចក្តីសម្រេចលេខ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ។
-ការធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ នាថ្ងៃទី .........ខែ..........ឆ្នាំ........... ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា បន្ទាប់ពីក្រុមប្រឹក្សាគណៈមេធាវីបានសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមសេចក្តីសម្រេចលេខ............/សសគម/........ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... ខ្ញុំបាទ/នាងខ្ញុំបានធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍រួចហើយ កាលពីថ្ងៃទី.............ខែ.............ឆ្នាំ.............ហើយច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតម្រូវឱ្យខ្ញុំបាទ/នាងខ្ញុំ ធ្វើកម្មសិក្សារយៈពេល១ឆ្នាំ មុននឹងក្លាយទៅជាមេធាវីពេញសិទ្ធិ ។ ដូច្នេះ ខ្ញុំបាទ/នាងខ្ញុំស្នើសុំធ្វើកម្មសិក្សាជាមួយលោក/លោកស្រី/កញ្ញាមេធាវី....................... អត្តលេខ........... ដែលមានការិយាល័យ/ក្រុម/ក្រុមហ៊ុនមេធាវីឈ្មោះ..........................................ជាអក្សឡាតាំង.. ......................... ស្ថិតនៅផ្ទះលេខ..........ផ្លូវលេខ.......... ភូមិ........................សង្កាត់/ឃុំ ......................ខណ្ឌ/ស្រុក.....................រាជធានី/ខេត្ត...................... ដើម្បីដកស្រង់បទពិសោធន៍ក្នុងការប្រកបវិជ្ជាជីវៈមេធាវី ។ ខ្ញុំបាទ/នាងខ្ញុំសូមធានាអះអាងថា ខ្ញុំបាទ/នាងខ្ញុំពុំមានការងារដែលមានវិសមិតភាពជាមួយវិជ្ជាជីវៈមេធាវីនិងពុំមែនជាញាតិលោហិតរហូតដល់ថ្នាក់ទី២ឬជាសហព័ទ្ធរបស់គ្រូកម្មសិក្សាឡើយ ។ បើខុសពីការធានាអះអាងនេះ ខ្ញុំបាទ/នាងខ្ញុំយល់ព្រមទទួលខុសត្រូវចំពោះមុខច្បាប់ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

ថ្ងៃ...............ខែឆ្នាំ................................ព...........ស.
..............., ថ្ងៃទី...........ខែ...........ឆ្នាំ...........

**ហត្ថលេខា និងឈ្មោះ**

**បានឃើញ និងយល់ព្រម**
ធ្វើជាគ្រូកម្មសិក្សា ។
..........., ថ្ងៃទី.........ខែ.........ឆ្នាំ...........
**ហត្ថលេខា និងត្រា**

**ឧបសម្ព័ន្ធ២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងមេធាវី និងអតិថិជន

- កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី………ខែ…………ឆ្នាំ……………………………នៅស្នាក់ការ

ការិយាល័យ មេធាវី ……………………………………………។

- កិច្ចព្រមព្រៀងនេះធ្វើឡើងរវាងៈ

**ភាគី(ក)**

មេធាវីទទួលបន្ទុកអនុវត្តរឿងក្តី…………………លេខ…………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់តុលាការ…………………ដែលមានឈ្មោះ……………អត្តលេខ………ភូមិ……………………ឃុំ/សង្កាត់……………ស្រុក/ខណ្ឌ…………ខេត្ត/រាជធានី………………។

**ភាគី(ខ)**

អតិថិជន/កូនក្តីទទួលខុសត្រូវដោយលោក/លោកស្រី…………………អាយុ………ឆ្នាំ , មុខរបរ…………ជនជាតិ……………សញ្ជាតិ…………អាសយដ្ឋានផ្ទះលេខ………ផ្លូវលេខ………ភូមិ……………ឃុំ/សង្កាត់………ស្រុក/ខណ្ឌ……………ខេត្ត/រាជធានី……………។ទូរស័ព្ទ:………………………EMAIL: …………………………ទូរសារ……………ត្រូវជា…………ក្នុងសំណុំរឿង………………លេខ…………ចុះថ្ងៃទី………ខែ………ឆ្នាំ………របស់(សាលាដំបូង)…………………………………។

## ភាគីទាំង២បានព្រមព្រៀងដូចខាងក្រោម៖

**ប្រការ១៖** ភាគី(ខ)យល់ព្រមពឹងពាក់ឱ្យភាគី(ក)ជាមេធាវីការពារក្តីឬតំណាងឱ្យដើមបណ្តឹង/ជនរងគ្រោះក្នុងសំណុំរឿង**.........**លេខ…………ចុះថ្ងៃទី……ខែ……ឆ្នាំ…………របស់សាលាដំបូង…………។

ភាគី(ក)ក៏ព្រមព្រៀងសុខចិត្តបំពេញការងារជាមេធាវីឱ្យភាគី(ខ)តាមការព្រមព្រៀងអនុលោមតាមក្របខណ្ឌច្បាប់ កំណត់។

ប្រការ២៖ ភាគី(ក)បានព្រមព្រៀងបំពេញការងារការពារក្តី/តំណាងឱ្យភាគី(ខ)ដែលជាភាគី……….. នៃរឿងក្តី……………លេខ……….ចុះថ្ងៃទី…..ខែ…….ឆ្នាំ…….របស់សាលាដំបូង……………….ចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា និងបំពេញបែបបទតាមនីតិវិធីរហូតចប់កាតព្វកិច្ច នៃកិច្ចសន្យាដោយអនុលោមតាមច្បាប់កំណត់ តាមស្ថានភាព លទ្ធភាពនៃរឿងក្តី។

**ប្រការ៣÷ កំរិតអនុវត្តការងារ**

ភាគី(ក) បានយល់ព្រមទទួលការងារលើសេវាច្បាប់ការពារ/តំណាងឱ្យភាគី(ខ) ក្នុងកំរិតក្របខ័ណ្ឌមួយសាលាក្តីនៅ…………………………………………………………………………………។

- កាតព្វកិច្ច ភាគី(ក) ត្រូវចប់នៅពេលតុលាការប្រកាសសាលក្រម/សាលដីកា។
- ការងារបន្តត្រូវមានការព្រមព្រៀង និងចុះកិច្ចសន្យាថ្មី។

**ប្រការ៤÷ កម្រៃការងារ**

កម្រៃការងារអាចត្រូវបង់ជូនដូចតទៅ៖

១. ការងារបំពេញបែបបទ និងរៀបចំសំណុំរឿង

២. រៀបចំប្រមូលភស្តុតាង ការតទល់នៅ…………………………………………………………

៣. ត្រៀមសវនាការ សវនាការ

៤. ការបង់ប្រាក់ផ្តាច់មួយចប់ក្តីនៅតុលាការមួយថ្នាក់។

**ប្រការ៥÷ ប្រាក់កក់/ការទូទាត់បង់ប្រាក់កម្រៃ**

៥/១ ប្រាក់កក់ ភាគី(ខ) ត្រូវបង់ឱ្យមេធាវីចំនួន……………………………………………………

៥/២ នៅពេលការងារអនុវត្តដំណាក់កាលទី២ត្រូវបង់………………………………………………

៥/៣ បង់ដំណាក់កាលទី៣ នៅមុនសវនាការចំនួន…………………………………………………

៥/៤ ការបង់ប្រាក់សរុបសំរាប់រឿងចប់មួយថ្នាក់………………………… ………………………

៥/៥ រាល់ការបង់ប្រាក់ត្រូវមានវិក័យប័ត្រ។

**ប្រការ៦÷ ការតព្វកិច្ចភាគី(ក)**

៦/១ បំពេញការងារត្រង់កំរិតព្រមព្រៀងនៅ…………………………………………………………

៦/២ ខិតខំបំពេញការងារឱ្យអស់លទ្ធភាពដើម្បីឱ្យលទ្ធផលសំរេចបានល្អ

៦/៣ មិនធ្វេសប្រហែស ឬបោះបង់ការងារនាំឱ្យខូចប្រយោជន៍កូនក្តី។

**ប្រការ៧៖ ការគោរពកិច្ចភាគី(ខ)**

៧/១ គោរពពេលណាត់ធ្វើការងារ ផ្តល់រាល់ឯកសារពតិមានឱ្យភាគី(ក)

៧/២ គោរពបង់ប្រាក់កម្រៃមិនឱ្យខកខាន យឺតយ៉ាវ

៧/៣ ករណីខកខានក្នុងការងារ ឬ មិនបានបង់ប្រាក់ទាន់ពេលវេលា សុខចិត្តឱ្យមេធាវីបញ្ចប់ការងារដោយគ្មានតវ៉ា ។

**ប្រការ៨៖ ឧប្បត្តិហេតុ**

១. មេធាវីមានសិទ្ធិបញ្ចប់ការពារអតិថិជន ក្នុងករណីអតិថិជនមិនបានគោរពកាតព្វកិច្ច ។

២. អតិថិជនមានសិទ្ធិបញ្ចប់ការពឹងពាក់ ករណីមេធាវីធ្វើការមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន

៣. ក្នុងករណីមានវិវាទលើកិច្ចព្រមព្រៀង គណៈមេធាវីមានសមត្ថកិច្ចដោះស្រាយ (មាត្រា២២ ក្រមសីលធម៌វិជ្ជាជីវៈមេធាវី ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ។

**ប្រការ៩៖ សុពលភាព**

- មានសុពលភាពពីថ្ងៃចុះហត្ថលេខា រហូតដល់ថ្ងៃបញ្ចប់ការងារ
- ធ្វើជាភាសាខ្មែរ និងអង់គ្លេស
- និងចុះហត្ថលេខាជាសក្ខីកម្មចំពោះមុខច្បាប់ ។

ថ្ងៃទី……………ខែ…………ឆ្នាំ២០………

**ភាគី(ខ)** **ភាគី(ក)**

**ឧបសម្ព័ន្ធ៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យការពារក្តី

ខ្ញុំមេធាវី……………………….អត្តលេខ………… ស្នាក់ការការិយាល័យ……………………………… ដែលមានអាសយដ្ឋានផ្ទះលេខ………ផ្លូវលេខ………ភូមិ………………ឃុំ/សង្កាត់………………ស្រុក/ខណ្ឌ…………… ខេត្ត/រាជធានី…………………….ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ…………………។

## សូមគោរពជូន

……………………………………………………………………………

**សូមទានជ្រាប:**

**កម្មវត្ថុ:** ការចូលការពារក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ……ចុះថ្ងៃទី………ខែ……… ឆ្នាំ………… នៅ………………………………………………………………………… ។

**យោង:** - ពាក្យសុំពឹងពាក់មេធាវីរបស់ឈ្មោះ…………………………ចុះថ្ងៃទី………ខែ……ឆ្នាំ…………

- មាត្រា២ និងមាត្រា៣នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- មាត្រា៩៨ និងមាត្រា២៤៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន……………………………… មេត្តាជ្រាបថា: ខ្ញុំត្រូវបានឈ្មោះ………………………… សុំពឹងពាក់ឱ្យការពារក្តីក្នុងសំណុំរឿងខាងលើ តាមនីតិវិធី ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម……………………………… មេត្តាជ្រាបតាមការគួរ។

សូម…………………………………………មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ……………, ថ្ងៃទី…………ខែ……… ឆ្នាំ…………

**ហត្ថលេខា និងត្រា**

---

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ…………… ខេត្ត/រាជធានី…………ទូរស័ព្ទ:………………………………ទូរសារ:…………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ៣ (ក)**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង**

ខ្ញុំមេធាវី…………………អត្តលេខ……………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឱ្យឈ្មោះ…………………………ត្រូវជា……………………ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់សាលាដំបូង……………………………………។

**សូមគោរពជូន**

………………………………………………………………………

**កម្មវត្ថុ:** - សុំពិនិត្យ និងថតចម្លងសំណុំរឿងព្រហ្មទណ្ឌលេខ………… ចុះថ្ងៃទី……… ខែ……… ឆ្នាំ………

របស់…………………………………………………………។

**យោង:** - មាត្រា១២៩, ៣១៩, ៤២៨និង៤៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ២០០៧/០៨/

- ពាក្យការពារក្តី ចុះថ្ងៃទី……… ខែ………… ឆ្នាំ……………

តបតាមកម្មវត្ថុ និងយោងខាងលើ សូម…………………………………………… មេត្តាអនុញ្ញាត អោយខ្ញុំបានពិនិត្យ និងថតចម្លងសំណុំរឿងខាងលើដោយក្តីអនុគ្រោះ។

សូម…………………………………………………… ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ……………………, ថ្ងៃទី……… ខែ…………ឆ្នាំ……………

**ហត្ថលេខា និងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់…………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:…………………………………ទូរសារ:…………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ៣ (ខ)**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំពឹងពាក់មេធាវី**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ…………………អាយុ…………ឆ្នាំ…..សញ្ជាតិ…………..មុខរបរ……………..……………………..ទីលំនៅបច្ចុប្បន្នផ្ទះលេខ………..ផ្លូវ………….ក្រុម…………… ភូមិ……………………..ឃុំ/សង្កាត់………………..ស្រុក/ខណ្ឌ…………….ខេត្ត/រាជធានី…………….ត្រូវជា……………………….។

**សុំពឹងពាក់**

លោក/លោកស្រីមេធាវី……………………..អត្តលេខ……..ការិយាល័យ……………………….. អាសយដ្ឋានផ្ទះលេខ……………..ផ្លូវលេខ………..ភូមិ…………………..ឃុំ/សង្កាត់…………………..ស្រុក/ខណ្ឌ………………………ខេត្ត/រាជធានី……………..ដើម្បីការពារសិទ្ធិអោយខ្ញុំបាទ/នាងខ្ញុំនៅចំពោះមុខ………………………………………………………ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ…………ចុះថ្ងៃទី…….ខែ………..ឆ្នាំ……..របស់……………………..ក្នុងនាមជា: ………………………….។

ចាប់ពីថ្ងៃខ្ញុំបាទ/នាងខ្ញុំចុះហត្ថលេខា វីផ្តិតម្រាមដៃនេះតទៅ គឺមេធាវីខាងលើមានសិទ្ធិការពារ ផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ……………………..ថ្ងៃទី……..ខែ………….. ឆ្នាំ……….

**ស្នាមម្រាមដៃសាមីខ្លួន**

បានឃើញ និង យល់ព្រម

ធ្វើនៅ………………..ថ្ងៃទី…….. ខែ…………..ឆ្នាំ………….

**ហត្ថលេខា និង ត្រា**

**ឧបសម្ព័ន្ធ៤**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>លិខិតតំណាងដោយអាណត្តិ</u>

ខ្ញុំមេធាវី……………………….អត្តលេខ…………ស្នាក់ការការិយាល័យ…………………ដែលមាន អាសយដ្ឋានផ្ទះលេខ………ផ្លូវលេខ………ភូមិ………………ឃុំ/សង្កាត់……………ស្រុក/ខណ្ឌ…………ខេត្ត/រាជធានី………………ជាមេធាវីតំណាងឱ្យដើមបណ្តឹងរប្បវេណីឈ្មោះ……………………………។

## <u>សូមគោរពជូន</u>

……………………………………………………………………………

<u>**សូមឆានជ្រាបៈ**</u>

<u>**កម្មវត្ថុៈ**</u> សុំតំណាងអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ………………………………………………………។
សំណុំរឿងព្រហ្មទណ្ឌលេខ…………………ចុះថ្ងៃទី………របស់អយ្យការអមសាលាដំបូង…………។

<u>**យោងៈ**</u> - លិខិតប្រគល់អាណត្តិចុះថ្ងៃទី……………………របស់ឈ្មោះ…………………………………………។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន………………………………… មេត្តាជ្រាបថាៈ ខ្ញុំត្រូវបានឈ្មោះ………………………… បានប្រគល់អាណត្តិតំណាងក្នុងសំណុំរឿងខាងលើតាមនីតិវិធី ។

សូម………………………………………… មេត្តាពិនិត្យ និង អនុញ្ញាតដោយក្តីអនុគ្រោះ។

សូម…………………………………………មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ……………, ថ្ងៃទី…………ខែ……… ឆ្នាំ…………

**ហត្ថលេខា និង ត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទៈ……………………………ទូរសារៈ…………………………………អ៊ីម៉ែលៈ……………

**ឧបសម្ព័ន្ធ៤ (ក)**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

ខ្ញុំមេធាវី…………………អត្តលេខៈ……………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឱ្យឈ្មោះ………………………ត្រូវជា……………………ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់សាលាដំបូង…………………………………។

**សូមគោរពជូន**

…………………………………………………………………………

**កម្មវត្ថុៈ** - សុំពិនិត្យ និងថតចម្លងសំណុំរឿងព្រហ្មទណ្ឌលេខ………… ចុះថ្ងៃទី……… ខែ……… ឆ្នាំ……… របស់…………………………………………………………………។

**យោងៈ** - មាត្រា១២៩, ៣១៩, ៤២៨និង៤៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ២០០៧/០៨/

- ពាក្យការពារក្តី ចុះថ្ងៃទី……… ខែ………… ឆ្នាំ……………

តបតាមកម្មវត្ថុ និងយោងខាងលើ សូម……………………………………………… មេត្តាអនុញ្ញាត អោយខ្ញុំបានពិនិត្យ និងថតចម្លងសំណុំរឿងខាងលើដោយក្តីអនុគ្រោះ។

សូម……………………………………………… ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ……………………, ថ្ងៃទី……… ខែ………… ឆ្នាំ……………

**ហត្ថលេខា និងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:…………………………………ទូរសារ:…………………………………អ៊ីម៉ែល:……………

ឧបសម្ព័ន្ធ៤ (ខ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតប្រគល់អាណត្តិ

នាងខ្ញុំឈ្មោះ ....................អាយុ.........ឆ្នាំ... ជាតិ..........អត្តសញ្ញាណបណ្ណលេខ ...........................ចុះថ្ងៃទី......ខែ...........ឆ្នាំ.........លំនៅបច្ចុប្បន្នផ្ទះលេខ................ភូមិ...... សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ....................................។

# សូមប្រគល់អាណត្តិតំណាង

ជូនមេធាវី........................អត្តលេខ ...........ការិយាល័យមេធាវី.............................. ទូរសព្ទទំនាក់ទំនងលេខ......................ដើម្បីតំណាងអាណត្តិឲ្យនាងខ្ញុំ ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសុំណុំរឿងព្រហ្មទណ្ឌលេខ............................................ចុះថ្ងៃទី.............................. របស់អយ្យការអមសាលាដំបូង..........................................................................។

ពន្ធដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ជាបន្ទុករបស់កូនក្តី។

សូមផ្តិតស្នាមម្រាមដៃជូនមេធាវី អនុវត្តសិទ្ធិតាមច្បាប់តទៅ។

ធ្វើនៅ..........., ថ្ងៃទី......... ខែ...........ឆ្នាំ...............

យល់ព្រម

**ស្នាមម្រាមដៃ**

ធ្វើនៅ..........., ថ្ងៃទី......... ខែ...........ឆ្នាំ..............

**ហត្ថលេខា និង ត្រា**

_______________

អាសយដ្ឋានផ្ទះលេខ......... ផ្លូវលេខ......... ភូមិ.................... ឃុំ/សង្កាត់......................... ស្រុក/ខណ្ឌ..............
ខេត្ត/រាជធានី...........ទូរស័ព្ទ:......................................ទូរសារ:..................................អ៊ីម៉ែល:..............

**ឧបសម្ព័ន្ធ៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំឈប់តំណាងអាណត្តិ**

ខ្ញុំមេធាវី……………………..អត្តលេខ……….. ស្នាក់ការការិយាល័យ……………….ដែលមាន អាសយដ្ឋានផ្ទះលេខ……..ផ្លូវលេខ……..ភូមិ……………..ឃុំ/សង្កាត់…………..ស្រុក/ខណ្ឌ………. ខេត្ត/រាជធានី……………..ជាមេធាវីតំណាងឱ្យដើមបណ្តឹងរប្បវេណីឈ្មោះ…………………………។

**សូមគោរពជូន**

…………………………………………………………………….

**សូមទានជ្រាប:**

**កម្មវត្ថុ:** -សុំឈប់តំណាងអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ…………………………………. ។

**យោង:** -សំណុំរឿងព្រហ្មទណ្ឌលេខ……………….ចុះថ្ងៃទី……………………………………….

របស់អយ្យការអមសាលាដំបូង …………………………។

-លិខិតអញ្ជើញមេធាវីចុះថ្ងៃទី……………………………។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន…………………………… មេត្តាជ្រាបថា: ខ្ញុំបាទ/នាងខ្ញុំសុំឈប់តំណាងអាណត្តិឱ្យចុងចម្លើយឈ្មោះ………………………… ដោយ មូលហេតុសហចុងចម្លើយ ដែលដើមបណ្តឹងរដ្ឋប្បវេណី មានសហមេធាវីថ្មី និងឯកភាពមិនឱ្យខ្ញុំបាទ/នាងខ្ញុំ តំណាងអាណត្តិទៅទៀតឡើយ ។

សូម……………………………………… មេត្តាពិនិត្យ និង អនុញ្ញាតដោយក្តីអនុគ្រោះ។

សូម………………………………………មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ…………., ថ្ងៃទី……….ខែ…….. ឆ្នាំ……….

**ហត្ថលេខា និងត្រា**

**ឧបសម្ព័ន្ធ៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំអនុញ្ញាតជួបកូនក្តី**

ខ្ញុំមេធាវី………………អត្តលេខ:……………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឱ្យឈ្មោះ…………………………ត្រូវជា………………………ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់សាលាដំបូង………………………………។

**សូមគោរពជូន**

……………………………………………………………………………

**កម្មវត្ថុ:** - សុំអនុញ្ញាតជួបកូនក្តី ឈ្មោះ……………………………………………………………………។

**យោង:** - ពាក្យការពារក្តីចុះថ្ងៃទី………ខែ……………ឆ្នាំ……………

- មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន…………………………………………………
…………………………………………………………………………………………………………………។
អាស្រ័យហេតុនេះ សូម………………………………មេត្តាអនុញ្ញាតឱ្យខ្ញុំបានជួបកូនក្តីតាមនីតិវិធីច្បាប់។

សូម…………………………………… ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ………………………, ថ្ងៃទី……… ខែ……… ឆ្នាំ…………

**ហត្ថលេខា និងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:……………………………………ទូរសារ:…………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំបញ្ចូលភស្តុតាង

ខ្ញុំមេធាវី…………………… អត្តលេខ………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឱ្យឈ្មោះ………………………ត្រូវជា……………………ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ……….. របស់សាលាដំបូង…………………………………។

**សូមគោរពជូន**

………………………………………………………………………………

**កម្មវត្ថុ:** សុំដាក់បញ្ចូលភស្តុតាង ក្នុងសំណុំរឿង។

**យោង:** - មាត្រា១៥៣, ២៤៥ និងមាត្រា៣២១នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០២០០៧/០៨/

- សំណុំរឿងព្រហ្មទណ្ឌលេខ……… ចុះថ្ងៃទី……ខែ………ឆ្នាំ………របស់…………………។
- ពាក្យការពារក្តី ចុះថ្ងៃទី……… ខែ………… ឆ្នាំ………………

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន…………………………………… មេត្តា ជ្រាបៈ ខ្ញុំសូមដាក់ បញ្ចូលភស្តុតាងដូចខាងក្រោម ៖

១.……………………………………………

២.……………………………………………

៣.……………………………………………

អាស្រ័យហេតុនេះ សូម………………………… មេត្តាពិនិត្យ និងពិចារណាតាមនីតិវិធីច្បាប់។

សូមលោក…………………………………….មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ធ្វើនៅ……………… ,ថ្ងៃទី………ខែ……… ឆ្នាំ…………

**ហត្ថលេខា និងត្រា**

---

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ……………… ឃុំ/សង្កាត់…………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:…………………………………ទូរសារ:………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ៨**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំឱ្យកូនក្ដីនៅក្រៅឃុំ**

ខ្ញុំមេធាវី………………… អត្តលេខ:……………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឱ្យឈ្មោះ……………………………ត្រូវជា…………………..ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់សាលាដំបូង……………………………។

**សូមគោរពជូន**

………………………………………………………………………

**កម្មវត្ថុ:** សុំឱ្យកូនក្ដីឈ្មោះ……………………………ជាប់ចោទពីបទ…………………………… នៅក្រៅឃុំបណ្ដោះអាសន្ន។

**យោង:** - មាត្រា២០៣, ២០៥ និងមាត្រា២៤៥នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០/០៨/២០០៧

- សំណុំរឿងព្រហ្មទណ្ឌលេខ…………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់………………។
- ពាក្យការពារក្ដីចុះថ្ងៃទី............ ខែ............ ឆ្នាំ................

តបតាមកម្មវត្ថុនិងយោងខាងលើសូមជម្រាបជូន………………………………………… មេត្តាជ្រាបៈ ……………………………………………………………………………………… ……………………………………………………………………………………………… ……………………………………………………………………………………………។

អាស្រ័យហេតុនេះ សូម………………………………………… មេត្តាអនុញ្ញាតឱ្យកូនក្ដីរបស់ខ្ញុំបាននៅក្រៅឃុំជាបណ្ដោះអាសន្នដោយក្ដីអនុគ្រោះ។

សូមលោក…………………………….មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ធ្វើនៅ……………… ,ថ្ងៃទី………ខែ……… ឆ្នាំ…………

**ហត្ថលេខា និងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:…………………………………ទូរសារ:…………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ៩**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំពន្យារពេលចូលបំភ្លឺ**

ខ្ញុំមេធាវី…………………………អត្តលេខ…………ស្នាក់ការការិយាល័យ……………………ដែលមានអាសយដ្ឋានផ្ទះលេខ………ផ្លូវលេខ………ភូមិ…………………ឃុំ/សង្កាត់…………ស្រុក/ខណ្ឌ…………ខេត្ត/រាជធានី…………ជាមេធាវីការពារសិទ្ធិអោយឈ្មោះ……………………។

**សូមគោរពជូន**

……………………………………………………………

**កម្មវត្ថុ:** សុំពន្យារពេលចូលឆ្លើយបំភ្លឺនៅថ្ងៃទី……… ខែ……ឆ្នាំ…………

**យោង:** សំណុំរឿងព្រហ្មទណ្ឌលេខ………ចុះថ្ងៃទី………ខែ……ឆ្នាំ………របស់……………………

- ពាក្យការពារក្តី ចុះថ្ងៃទី……… ខែ…………ឆ្នាំ..........
- ដីកា…………………………………………………

តបតាមកម្មវត្ថុនិងយោងខាងលើខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន…………………………… មេត្តាជ្រាបថា:ដោយហេតុថា……………………………………………………………………………………
……………………………………………………………………………………………………………………។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក……………………………………… មេត្តាអនុញ្ញាតដោយក្តី អនុគ្រោះ។

សូមលោក……………………………………ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ……………………,ថ្ងៃទី…… ខែ…………ឆ្នាំ……………

**ហត្ថលេខា និងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់…………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:………………………………ទូរសារ:………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ១០**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ពាក្យស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ</u>**

ខ្ញុំមេធាវី………………………… អត្តលេខ……………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឱ្យឈ្មោះ…………………ត្រូវជា…………………………ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ……………ចុះថ្ងៃទី……ខែ………ឆ្នាំ……………របស់សាលាដំបូង………………។

**<u>សូមគោរពជូន</u>**

**លោកចៅក្រមស៊ើបសួរ**……………………………………….

**<u>កម្មវត្ថុ</u>:** សុំបំពេញកិច្ចស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌ។

**<u>យោង</u>:** -សំណុំរឿងព្រហ្មទណ្ឌលេខ…………ចុះថ្ងៃទី……ខែ………ឆ្នាំ………របស់សាលាដំបូង…………………

- ពាក្យការពារចុះថ្ងៃទី…………ខែ…………ឆ្នាំ…………………

- មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០/០៨/២០០៧។

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើ ដោយរឿងក្តីនេះមានចំណុចសំខាន់ត្រូវស្នើសុំ ឱ្យលោកចៅក្រមស៊ើបបំពេញកិច្ចស៊ើបសួរពីករណី……………………………… ……………

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

ដែលចម្លើយ ឯកសារកំណត់ហេតុនានាជាមូលដ្ឋានមានសារៈសំខាន់ក្នុងសំណុំរឿងក្តី។

អាស្រ័យហេតុនេះ សូមលោកចៅក្រមស៊ើបសួរ មេត្តាអនុញ្ញាតដំណើរការបំពេញកិច្ចស៊ើបសួរតាមពាក្យស្នើសុំខាងលើដោយក្តីអនុគ្រោះ។

សូមលោកចៅក្រមស៊ើបសួរទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ…………………ថ្ងៃទី……… ខែ………… ឆ្នាំ…………

**ហត្ថលេខា និងត្រា**

---

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់…………………… ស្រុក/ខណ្ឌ…………… ខេត្ត/រាជធានី…………ទូរស័ព្ទ:…………………………………ទូរសារ:……………………………អ៊ីម៉ែល:…………….

**ឧបសម្ព័ន្ធ១១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>ពាក្យសុំមោឃៈភាពនីតិវិធី</u>

ខ្ញុំមេធាវី……………………អត្តលេខ:……………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ………………………..ត្រូវជា……………………..ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់សាលាដំបូង……………………………។

**<u>សូមគោរពជូន</u>**

………………………………………………………………………….

**<u>កម្មវត្ថុៈ</u>** ប្តឹងសុំមោឃៈភាព

**<u>យោងៈ</u>** - មាត្រា៥៤ មាត្រា១០៩ និងមាត្រា១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- សំណុំរឿងព្រហ្មទណ្ឌលេខ………… ចុះថ្ងៃទី………ខែ………ឆ្នាំ………… របស់………………។
- ពាក្យការពារក្តី ចុះថ្ងៃទី……… ខែ………… ឆ្នាំ…………

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន……………………………មេត្តាជ្រាបៈ ……………………………………………………………………………………………………… ……………………………………………………………………………………………………។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម…………………………………………… មេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

សូមលោក……………………………….មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ធ្វើនៅ……………… ,ថ្ងៃទី………ខែ……… ឆ្នាំ…………

**ហត្ថលេខា និង ត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:……………………………………ទូរសារ:…………………………………អ៊ីម៉ែលៈ……………

**ឧបសម្ព័ន្ធ១២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>សេចក្តីសន្និដ្ឋានរបស់មេធាវី</u>**

ខ្ញុំមេធាវី……………អត្តលេខៈសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវី………….……………………..ការពារឱ្យឈ្មោះត្រូវជា……………………….ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ……………. ចុះថ្ងៃទីខែ………ឆ្នាំរបស់…............សាលាដំបូង……………………………….

**<u>សូមគោរពជូន</u>**

………………………………………………………………

**<u>កម្មវត្ថុ:</u>**សុំដាក់ជូននូវសេចក្តីសន្និដ្ឋានមេធាវីការពារឱ្យកូនក្តីឈ្មោះ………………….ជាភាគី………………។

**<u>យោងៈ</u>**សំណុំរឿងព្រហ្មទណ្ឌលេខ…………ចុះថ្ងៃទី……ខែ……ឆ្នាំ…………របស់សាលាដំបូង…………..

- លិខិតអញ្ជើញមេធាវីឱ្យចូលសវនាការចុះថ្ងៃទី………ខែ…………ឆ្នាំ......................
- ពាក្យការពារក្តីចុះថ្ងៃទី…….…ខែ…………ឆ្នាំ……………

ខ្លឹមដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំជាមេធាវីការពារឱ្យកូនក្តីឈ្មោះÉ………………………………….សូមធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីដូចតទៅ៖

១.អំពីអង្គហេតុ

២.ភស្តុតាងដាក់បន្ទុក

៣.ភស្តុតាងដោះបន្ទុក

៤.អង្គច្បាប់

៥.ធាតុផ្សំបទល្មើស

៦.ដំណើរការនីតិវិធី

៧.សន្និដ្ឋានលើអាទិភាពរបស់កូនក្តី

៨.សំណូមពរ

---

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់…………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:………………………………ទូរសារ:………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ១៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតប្រគល់សិទ្ធិប្តឹងទាស់**

នាងខ្ញុំឈ្មោះ ………………….អាយុ………ឆ្នាំ… សញ្ជាតិ………អត្តសញ្ញាណបណ្ណលេខ ………………………….ចុះថ្ងៃទី……ខែ…………ឆ្នាំ………លំនៅបច្ចុប្បន្នផ្ទះលេខ………………ភូមិ…… សង្កាត់………ខណ្ឌ…………រាជធានីភ្នំពេញ………………………………..។

**សូមប្រគល់សិទ្ធជូន**

ជូនមេធាវី………………………អត្តលេខ …………ការិយាល័យមេធាវី…………………………. នាងខ្ញុំសម្រេចប្រគល់សិទ្ធិជូនមេធាវីដើម្បីប្តឹងទាស់………………………………………………………. នឹងសាលក្រម/សាលដីកាលេខ…………របស់សាលាដំបូង………ចុះថ្ងៃទី………ខែ ………ឆ្នាំ……… ត្រង់ចំណុច………………………………………………………………………………។

នាងខ្ញុំចុះហត្ថលេខា ផ្តិតម្រាមដៃនេះតទៅ ដើម្បីប្រគល់សិទ្ធិជូនមេធាវីក្នុងការប្តឹងទាស់សាលក្រម ឬសាលដីកាខាងលើនេះ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់នាងខ្ញុំ។

ធ្វើនៅ…………, ថ្ងៃទី……… ខែ…………ឆ្នាំ……………

យល់ព្រម

**ស្នាមម្រាមដៃ**

ធ្វើនៅ…………, ថ្ងៃទី……… ខែ…………ឆ្នាំ……………

**ហត្ថលេខា និង ត្រា**

______________

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………. ឃុំ/សង្កាត់…………………….. ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:…………………………………ទូរសារ:………………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ១៣ (ក)**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹងទាស់**

ខ្ញុំមេធាវី……………………អត្តលេខៈ……………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ………………………ត្រូវជា………………………ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់សាលាដំបូង…………………………។

**សូមគោរពជូន**

………………………………………………………………………………

**កម្មវត្ថុៈ**ប្តឹងទាស់នឹងសាលក្រម/សាលដីកាលេខ………លេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់…………………………………………………………។

**យោងៈ** - មាត្រា ៣៦៥,៣៦៧,៣៦៦ , ៣៦៨ ៣៧០ ,៣៦៩ , និងមាត្រា៣៧២ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ចុះថ្ងៃទី១០២០០៧/០៨/

- សាលក្រម/ សាលដីកាកំបាំងមុខលេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ……………
- លិខិតជូនដំណឹងស្តីពីសាលក្រម/សាលដីកាកំបាំងមុខលេខ……ចុះថ្ងៃទី……ខែ………ឆ្នាំ…
- លិខិតប្រគល់សិទ្ធិប្តឹងទាស់ចុះថ្ងៃទី……ខែ………ឆ្នាំ……………

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនមេត្តាជ្រាបៈ……………………ដោយកូនក្តីខ្ញុំឈ្មោះមិនពេញចិត្តនឹងសាលក្រមត្រង់……………………………/សាលដីកាកំបាំងមុខខាងលើត្រង់ចំណុច………………………… ……………………………………………………នៃសាលក្រមកំបាំងមុខ។

សូម ………………………………………………………………… មេត្តាទទួល និងចាត់ការលើបណ្តឹងទាស់តាមនីតិវិធីនៃច្បាប់ដោយក្តីអនុគ្រោះ។

ធ្វើនៅ………………ចុះថ្ងៃទី……ខែ………ឆ្នាំ…………

**ហត្ថលេខា និងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទៈ…………………………………ទូរសារៈ…………………………………អ៊ីម៉ែលៈ……………

**ឧបសម្ព័ន្ធ១៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹងឧទ្ធរណ៍**

ខ្ញុំមេធាវី…………………អត្តលេខៈ…………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឱ្យឈ្មោះ………………ត្រូវជា……………ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ…………… ចុះថ្ងៃទី……ខែ………ឆ្នាំ…………របស់សាលាដំបូង…………………………។

**សូមគោរពជូន**

………………………………………………………………………

**កម្មវត្ថុ:**ប្តឹងឧទ្ធរណ៍លើសាលក្រមលេខ…… ចុះថ្ងៃទី……ខែ……ឆ្នាំ………របស់……………។

**យោង:** - មាត្រា៣៧៥ មាត្រា៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០/០៨/២០០៧

-លិខិតប្រគល់សិទ្ធិប្តឹងឧទ្ធរណ៍ចុះថ្ងៃទី……… ខែ………ឆ្នាំ…………

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន………………មេត្តាជ្រាបថាៈដោយហេតុថា កូនក្តីរបស់ខ្ញុំ ឈ្មោះ………………………………………មិនសុខចិត្តចំពោះការសម្រេចសេចក្តីតាម សាលក្រមលេខ…………ចុះថ្ងៃទី………ខែ…………ឆ្នាំ………… របស់………………………………។ ខ្ញុំជាមេធាវីសុំប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចត្រង់ចំណុច……………………………………។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម…………………មេត្តាទទួលតាមនីតិវិធីនៃ ច្បាប់។

សូមលោក………………………………មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ធ្វើនៅ…………………,ថ្ងៃទី………ខែ……… ឆ្នាំ…………

**ហត្ថលេខា និងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់…………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:………………………………ទូរសារ:……………………………អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ១៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតប្រគល់សិទ្ធិប្តឹងទាមទារសំណងរដ្ឋប្បវេណី**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ…………………………អាយុ………ឆ្នាំ ជនជាតិ………… សញ្ជាតិ………… មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ………….. ផ្លូវលេខ………… ក្រុម…………..ភូមិ…………………….. ឃុំ/សង្កាត់………………………..ស្រុក/ខណ្ឌ………………………….. ខេត្ត/រាជធានី……………………….. មុខរបរ……………….. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ…………ចុះថ្ងៃទី……ខែ……ឆ្នាំ……។

**សូមគោរពជូន**

………………………………………………………………………….

**កម្មវត្ថុ:** សុំប្រគល់សិទ្ធិជូនមេធាវី……………………..អត្តលេខ………ស្នាក់ការ ការិយាល័យ…………………………..ដែលមានអាសយដ្ឋានផ្ទះលេខ………… ផ្លូវលេខ………… ភូមិ……………………. ឃុំ/សង្កាត់…………………………..ស្រុក/ខណ្ឌ……………………..ខេត្ត/រាជធានី………………..ដើម្បីប្តឹងទាមទារសំណងរដ្ឋប្បវេណី។

**យោង:** - មាត្រា៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន………………………………. មេត្តាជ្រាបថា:ខ្ញុំបាទ/នាងខ្ញុំបានប្រគល់សិទ្ធិជូនមេធាវី…………………………..ចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតម្រាមដៃនេះតទៅគឺមេធាវីមានសិទ្ធិប្តឹង/តំណាង…………………………អោយខ្ញុំបាទ/នាងខ្ញុំដើម្បី ការពារផលប្រយោជន៏ស្របច្បាប់ទៅតាមនីតិវិធីច្បាប់។

អាស្រ័យហេតុនេះសូម……………………………………….មេត្តាទទួលតាមនីតិវិធីនៃច្បាប់។

សូម…………………………………………….. ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

……………………, ថ្ងៃទី……… ខែ……… ឆ្នាំ…………

**ស្នាមម្រាមដៃ**

បានឃើញ និងយល់ព្រម

………………,ថ្ងៃទី………ខែ…………ឆ្នាំ…………

**ហត្ថលេខា និងត្រា**

---

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………. ឃុំ/សង្កាត់…………………. ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:……………………………….ទូរសារ:…………………………….អ៊ីម៉ែល:……………

**ឧបសម្ព័ន្ធ១៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹងរបស់មេធាវីតំណាងជនរងគ្រោះ/ដើមបណ្តឹងរដ្ឋប្បវេណី**

ខ្ញុំមេធាវី………………… អត្តលេខ………..សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ……………………….  ត្រូវជា………………..ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ………….ចុះថ្ងៃទី……..ខែ……..ឆ្នាំ……….. របស់សាលាដំបូង……………………………….។

**សូមគោរពជូន**

**ឯកឧត្តម/លោក ព្រះរាជអាជ្ញាអមសាលាដំបូង**…………………………..

**កម្មវត្ថុ:**សុំប្តឹងឈ្មោះ……..ភេទ……..អាយុ………..ជនជាតិ……………សញ្ជាតិ……………………….

មុខរបរ……………………..អាសយដ្ឋាន………………………………………..ពីបទ……………..

ប្រព្រឹត្តនៅវេលាថ្ងៃទី……ខែ……ឆ្នាំ……..នៅភូមិ…………ឃុំ/សង្កាត់……..ស្រុក/ខណ្ឌ…

……………..ខេត្ត/រាជធានី…………………….។

**យោង:**សំណុំរឿងព្រហ្មទណ្ឌលេខ………..ចុះថ្ងៃទី……ខែ……ឆ្នាំ……..របស់សាលាដំបូង…………..

- មាត្រា………………….នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧
- លិខិតប្រគល់សិទ្ធិឲ្យមេធាវីជាតំណាងអាណត្តិ ចុះថ្ងៃទី៣០/១១/២០០៩

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំជាមេធាវីតំណាងដោយអាណត្តិឲ្យជនរងគ្រោះ/ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ…………………….សូមរៀបរាប់អំពីបណ្តឹងមានខ្លឹមសារដូចតទៅៈ

១.អត្តសញ្ញាណអ្នកប្តឹងជនរងគ្រោះ/ដើមបណ្តឹងរដ្ឋប្បវេណី

២.អង្គហេតុ

៣.ភស្តុតាងនៃបណ្តឹង

៤.ភស្តុតាងដាក់បន្ទុក

៥.ដំណើរការចំណាត់ការនីតិវិធី

៦.លទ្ធផលការងារស៊ើបអង្កេត

៧.ការខូចខាត/ព្យសនកម្ម

៨.សរុបចំណុចប្តឹងទាមទារ

៩.សំណូមពរ

ធ្វើនៅ……………………ថ្ងៃទី……… ខែ……… ឆ្នាំ…………

**ហត្ថលេខានិងត្រា**

អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់……………………… ស្រុក/ខណ្ឌ……………
ខេត្ត/រាជធានី…………ទូរស័ព្ទ:…………………………………ទូរសារ:…………………………………អ៊ីម៉ែល:……………

# ព្រះរាជក្រម

នស/រកម/០៨០៧/០២៤

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
34/24071

## គន្ថីទី ៣
## ការស៊ើបអង្កេត
## មាតិកាទី ១
## បទប្បញ្ញត្តិទូទៅ
## ជំពូកគោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៣.** – ការសម្ងាត់នៃការស៊ើបអង្កេត

ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេត ជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើសដែលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៨៤.** – ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត

អំណាចទាំងឡាយ ដែលផ្ដល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះបំពេញការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្ដែង ឬក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។

## មាតិកាទី ២
## ការស៊ើបអង្កេតករណីជាក់ស្ដែង
## ជំពូកទី ១
## បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង

**មាត្រា ៨៥.** – អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្ដែង

ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពតាម

បទប្បញ្ញត្តិនៃមាតិកានេះ ។

**មាត្រា ៨៦.-** និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រជាប់ចាប់ប្រភឹង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

**មាត្រា ៨៧.-** ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើសហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

**មាត្រា ៨៨.-** ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## វិធានការស្រាវជ្រាវ

**មាត្រា ៨៩.-** វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។

ប្រសិនបើយល់ឃើញថាមានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្យាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

**មាត្រា ៩០.–** កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។

**មាត្រា ៩១.–** ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយ លើកលែងតែ :

-ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីដែលចែងដោយមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ដឹកជញ្ជូន ចែកចាយ

ប្រើប្រាស់ គ្រឿងញៀន ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ :

-ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី ។

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។

**មាត្រា ៩២.** – ការបិទស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។

**មាត្រា ៩៣.** – កំណត់ហេតុលើការស្តាប់ចម្លើយ

មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ ។

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដែលស្បថថា និយាយការពិត ស្របតាមជំនឿ ឬសាសនារបស់ខ្លួន ។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។

ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ ។

មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.–** បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.–** ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## ជំពូកទី ៣
## ការឃាត់ខ្លួន

**មាត្រា ៩៦.–** ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ការពន្យារគឺជាវិធានការពិសេស ។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។

ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

**មាត្រា ៩៧.** – កំណត់ហេតុស្ដីពីការឃាត់ខ្លួន

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្ដីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្ដីសម្រេចឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួនជាបន្ទាន់ ដោយមានចុះសេចក្ដីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតស្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**មាត្រា ៩៨.–** ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ គាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

**មាត្រា ៩៩.–** ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ សុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា ។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះ សមស្របនឹងការឃាត់ខ្លួនដែរឬទេ ។

ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ មន្ត្រីនគរបាលយុត្តិធម៌ ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យ

សុខភាព ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន ។

**មាត្រា ១០០.** – អនីតិជនដែលត្រូវបានឃាត់ខ្លួន

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ។

**មាត្រា ១០១.** – បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួន ត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ ។

គ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្តីដូចតទៅនេះ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ជាយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ១០២.** – កំណត់ហេតុសរុបនៃការឃាត់ខ្លួន

គ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។

កំណត់ហេតុសរុបនេះត្រូវមានចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

-អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន

-ចិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងចិរវេលានៃការសម្រាកដែលនៅចន្លោះការស្តាប់ចម្លើយនីមួយៗ

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន

-លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ ។

កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង ។

## ជំពូកទី ៤

## ការបញ្ជូនខ្លួន

**មាត្រា ១០៣.** – ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ :

-បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ

-ដោះលែងឱ្យមានសេរីភាពឡើងវិញ ។

សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ។

**មាត្រា ១០៤.** – រយៈពេលនៃការបញ្ជូនខ្លួន

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ។

ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន ។

នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន ។

មូលហេតុនៃការយឺតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ៥
## វិធានទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង

**មាត្រា ១០៥.-** ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍

មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យស្តាប់ និងថតសំលេងការសន្ទនាតាមទូរស័ព្ទឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬសារតាមអិនធើណែត ។

**មាត្រា ១០៦.-** ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង

ថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តិបទល្មើស ។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា ។

**មាត្រា ១០៧.-** ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ។

កាលណាបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាង ត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ ។

**មាត្រា ១០៨.-** និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ

កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនោះ

-កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

ពាក្យឆ្លូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ ។

កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ ។

**មាត្រា ១០៩.** – មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

វិធាន និងទម្រង់ការដែលបានបញ្ញត្តនៅមាត្រា :

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩១ (ការឆែកឆេរ)

-មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)

-មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)

-មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)

-មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

-មាត្រា ៩៦ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)

-មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្លាប់ដោយឯកឯង ជាអាទិ៍)

-មាត្រា ១០៦ (ចិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង) និង

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ ។

មានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នេះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ។

**មាត្រា ១១០.** – អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម

តាមគោលការណ៍កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ។

# មាតិកាទី ៣
# ការស៊ើបអង្កេតបឋម
# ជំពូកទោល
# ការស៊ើបអង្កេតបឋម

**មាត្រា ១១១.** – ការបើកការស៊ើបអង្កេតបឋម

កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ។

**មាត្រា ១១២.** – វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម

បទប្បញ្ញត្តិនៃមាត្រា :

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ

ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋម ។

**មាត្រា ១១៣.** – ការឆែកឆេរ

កាលណាការស៊ើបអង្កេតជាបឋមនោះ ទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ។

មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ។

ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ ។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់

តាំងដោយព្រះរាជអាជ្ញា ។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ ។ ការឆែកឆេរមិនអាចផ្តើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយ ម៉ោង ១៨ (ដប់ប្រាំបី) ឡើយ ។

បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនេះ ត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាង ។

**មាត្រា ១១៤.** – ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ។

បុគ្គលដែលកោះហៅត្រូវតែចូលមកបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួន ។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រា ។

បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន ។

**មាត្រា ១១៥.** – កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ ។ អ្នកបកប្រែមិនអាចត្រូវ បានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ ។

**មាត្រា ១១៦.** – ការឃាត់ខ្លួនជនជាប់សង្ស័យ

កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ បទប្បញ្ញត្តិនៃជំពូកទី ៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្តីពីការបញ្ជូនខ្លួន នៃមាតិកាទី២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែងក្នុងគន្ថីនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ១១៧.** – មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម វិធាន និងទម្រង់ការដែលចែងនៅក្នុងមាត្រា :

-មាត្រា ៩៦ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្ដីពីការឃាត់ខ្លួន)

-មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្គាប់ដោយឯកឯង ជាអាទិ៍)

-មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)

-មាត្រា ១១៣ (ការឆែកឆេរ)

-មាត្រា ១១៤ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) នៃក្រមនេះ

មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នេះទេនាំឱ្យមានមោឃភាពនៃនីតិវិធី ។

**មាត្រា ១១៨.** – អំណាចថ្លឹងថ្លែងរបស់ចៅក្រម

តាមគោលការណ៍ កំណត់ហេតុមានតម្លៃត្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

ចៅក្រមថ្លឹងថ្លែងដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។

## មាតិកាទី ៤

## ការប្រគល់ឱ្យម្ចាស់ដើមវិញ នូវវត្ថុដែលចាប់យក ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត

## ជំពូកតែមួយ

## ការប្រគល់ឱ្យម្ចាស់ដើមវិញ នូវវត្ថុដែលចាប់យក ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត

**មាត្រា ១១៩.** – អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ

ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលស៊ើបអង្កេត ទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ គ្មានការជំទាស់អ្វីប្រាកដប្រជាទេ ។

ប៉ុន្តែ វត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ មិនអាចប្រគល់ឱ្យវិញបានទេ ។ វត្ថុទាំងនោះត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល ។

ក្នុងករណីមិនព្រមប្រគល់ឱ្យវិញទេ អ្នកប្ដឹងអាចប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន ។

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការ

ចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា នៅតែមានសមត្ថកិច្ច កាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ ។

**មាត្រា ១២០.** – ការប្រគល់វត្ថុដែលរឹបអូសជូនម្ចាស់ដើមវិញ

កាលបើតុលាការដែលទទួលពាក្យប្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯង លើពាក្យសុំឱ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះ ពុំមានការជំទាស់អ្វីជាប្រាកដប្រជាទេ ។

# គន្ថីទី ៤
# ការស៊ើបសួរ
## មាតិកាទី ១
## ចៅក្រមស៊ើបសួរ
### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១២១.** – ការសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់ ។

បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។

ម្យ៉ាងទៀតព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១២២.** – ការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន ។

**មាត្រា ១២៣.** – សមត្ថកិច្ចដែនដី

ចៅក្រមដែលមានសមត្ថកិច្ចគឺ :

-ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស

-ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស

-ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយ

ទទួលបណ្ដឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច ។

វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ។

ការសម្រេចនេះបិទផ្លូវតវ៉ា ។

**មាត្រា ១២៨.–** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ ។

ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន ដោយអនុលោមតាមវាក្យខណ្ឌទី ២ នៃមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ ។

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។

កាលបើចៅក្រមស៊ើបសួរទទួលពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធីដូចដែលមានចែងនៅមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

កាលណាទទួលពាក្យប្ដឹងសាមញ្ញ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យប្ដឹងនោះទៅព្រះរាជអាជ្ញា ។

**មាត្រា ១២៩.–** វិសាលភាពនៃការប្ដឹង

ចៅក្រមស៊ើបសួរទទួលបណ្ដឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ ។

ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ ។

ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង ។

**មាត្រា ១២៦.** – ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរ ត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ នូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។

ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ នូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ។

ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ ក្នុងឋានៈ ជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

**មាត្រា ១២៧.** – ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក

ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមាន ប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់ ។

ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ។

**មាត្រា ១២៨.** – ជំនួយរបស់ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច ។ ក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ ។

**មាត្រា ១២៩.** – មុខងាររបស់ក្រឡាបញ្ជី

សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី ។ ក្រឡាបញ្ជីចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន ។ លិខិតចម្លងនេះត្រូវតែបញ្ជាក់ថា ត្រឹមត្រូវតាមលិខិតដើមដោយក្រឡាបញ្ជី ។ សេចក្តីចម្លងត្រូវរៀបចំទុកនៅក្នុងសំណុំរឿងបង្ការទុក ។

គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ ។

សំណុំរឿង និងសំណុំលិខិតដែលបង្ការទុក ត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី នៅមន្ទីរចៅក្រមស៊ើបសួរ ឬនៅក្នុងបន្ទប់ណាមួយនៃតុលាការដែលមានលក្ខខណ្ឌសន្តិសុខគ្រប់គ្រាន់ ។

មេធាវី ឬលេខាធិការរបស់មេធាវី ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរឱ្យធ្វើការថតចម្លងដោយខ្លួនជាអ្នកចេញសោហ៊ុយ និងក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។

**មាត្រា ១៣០.** – ការចុះដល់ទីកន្លែងដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួន នៅលើវិសាលភាពនៃ

សមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរនេះ ។

ប្រសិនបើការចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពដែនដីជាតិទាំងមូល ។ ប៉ុន្តែ ចៅក្រមត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ។

ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្ដីពីប្រតិបត្តិការរបស់ខ្លួននេះ ។

**មាត្រា ១៣១.-** ដីកាចាត់ឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរអាចសុំឱ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

**មាត្រា ១៣២.-** ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៣.-** ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាង

ហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា ១ (មួយ) ខែទេ ជនត្រូវចោទអាចប្ដឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៤.** – ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរ ឱ្យស្ដាប់ចម្លើយខ្លួន ស្ដាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង ។ ពាក្យសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងថិរវេលា ១ (មួយ) ខែ ក្រោយពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា ១ (មួយ) ខែទេ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់ សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៥.** – ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលា ព្រះរាជអាជ្ញាអាចពិនិត្យមើលសំណុំរឿងស៊ើបសួរ ឬស្នើសុំឱ្យបញ្ជូនសំណុំរឿងមកពិនិត្យ ប៉ុន្តែ ត្រូវមានភារកិច្ចបង្វិលសំណុំរឿងនេះទៅវិញ នៅក្នុងថិរវេលា ២៤ (ម្ភៃបួន) ម៉ោង ។

**មាត្រា ១៣៦.** – វត្តមានរបស់ព្រះរាជអាជ្ញា ចំពោះកិច្ចស៊ើបសួរ

ព្រះរាជអាជ្ញាអាចមានវត្តមាននៅក្នុងគ្រប់កិច្ចស៊ើបសួរ ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទក្នុងការសួរតទល់ និងក្នុងការស្ដាប់ចម្លើយ ។

**មាត្រា ១៣៧.** – ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍

កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា ។

ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាមួយឡើយ ។

កាលណាការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងតាមលិខិត លិខិតនេះត្រូវ

ដាក់បញ្ចូលក្នុងសំណុំរឿង ។ កាលណាការតាំងខ្លួនត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

**មាត្រា ១៣៨.** – បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ពាក្យប្តឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវី ។

**មាត្រា ១៣៩.** – ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា

ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា ។ ចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា ។

ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ ។

ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ។

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។

**មាត្រា ១៤០.** – ការបង់ប្រាក់តម្កល់ទុក

ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេច នូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង ។

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះបាន ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើម

បណ្ដឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ។

ប្រសិនបើប្រាក់តម្កល់ទុក មិនត្រូវបានបង់នៅក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ ។ ចៅក្រមស៊ើបសួរនេះ សម្រេចតាមដីកាដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។

ប្រាក់តម្កល់ទុកត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធី លើកលែងតែត្រូវអនុវត្តបទប្បញ្ញត្តិនៃមាត្រា ១៤១ (បណ្ដឹងដោយបំពាន ឬបណ្ដឹងដោយអូសបន្លាយពេលវេលា) នៃក្រមនេះ ។

ប្រាក់តម្កល់ទុកត្រូវតម្កល់ទុកនៅក្នុងគណនីពិសេស ដែលបើកនៅក្នុងធនាគារ ឬរក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំ ។ ទីកន្លែងនេះត្រូវបានជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា ។

**មាត្រា ១៤១.** – បណ្ដឹងដោយបំពាន ឬបណ្ដឹងដោយអូសបន្លាយពេលវេលា

ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលានោះ ចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាសម្រេចឱ្យដើមបណ្ដឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី ។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះត្រូវឱ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់ ។

**មាត្រា ១៤២.** – បណ្ដឹងឱ្យជួសជុលការខូចខាត

កាលណាការស៊ើបសួរដែលបើកបន្ទាប់ពីមានពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរ បុគ្គលដែលមានឈ្មោះនៅក្នុងពាក្យប្ដឹង អាចប្ដឹងសុំការជួសជុលសំណងពីអ្នកដែលប្ដឹងពីខ្លួន ប្រសិនបើនីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា ។

ពាក្យប្ដឹងសុំការជួសជុលនេះ ត្រូវដាក់ជូនដល់តុលាការជាន់ដំបូងដែលរឿងត្រូវបានស៊ើបសួរ ។ តុលាការអាចសុំឱ្យគេបញ្ជូនសំណុំរឿងមកពិនិត្យ ។

# ជំពូកទី ២
# ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ
## ផ្នែកទី ១
## ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

**មាត្រា ១៤៣.** – ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី ។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម ។

ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច ។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី ។

ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន ។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា :

-ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាន

-គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់ ។

ការឱ្យដំណឹងព្រមទាំងការប្រកាសស្តីអំពីការផ្លាស់ប្តូរអាសយដ្ឋាននោះ ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។

**មាត្រា ១៤៤.** – ជំនួយរបស់អ្នកបកប្រែ

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សីទេ ។

## ផ្នែកទី ២
## ការសួរចម្លើយជនត្រូវចោទ

**មាត្រា ១៤៥.** – វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥(ប្រាំ) ថ្ងៃ មុនការសួរចម្លើយ ។ ក្នុងថិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី ។

ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវី ។ និទ្ទេសស្តីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន ។ ការបោះបង់ចោលនេះត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ ។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែដូចបានចែងនៅក្នុងមាត្រា ១៤៤ (ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ ។

**មាត្រា ១៤៦.** – សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ១៤៧.** – ការពិភាក្សាដេញដោល

បទប្បញ្ញត្តិនៃមាត្រា ១៤៥ (វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ) និងមាត្រា ១៤៦ (សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តក្នុងករណីសួរចម្លើយតទល់ជនត្រូវចោទ ។

**មាត្រា ១៤៨.** – រយៈពេលអប្បបរមាសម្រាប់ការសួរចម្លើយ

កាលណាថិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងថិរវេលា ១ (មួយ) ខែ បន្ទាប់ពីការសុំទេ នោះជនត្រូវចោទអាចប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង ។ បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ ។

**មាត្រា ១៤៩.** – សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្ដីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន ។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាចត្រូវគេស្ដាប់ ឬថតបានទេ ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្ដីខ្លួនស្ដាប់ ។ ផ្ទុយទៅវិញ មេធាវីមិនអាចឱ្យលិខិតថតចម្លងពីលិខិតនៃសំណុំរឿង ដល់កូនក្ដីរបស់ខ្លួនបានឡើយ ។

## ផ្នែកទី ៣
## ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

**មាត្រា ១៥០.** – ការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី ។

ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការស្ដាប់ចម្លើយ ។ នៅក្នុងថិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន ។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានគេស្ដាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ ប៉ុន្ដែ ប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដោយគ្មានវត្តមានរបស់មេធាវី ។ និទ្ទេសស្ដីពីអវត្តមាន ត្រូវចុះនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីបាន ដោយមិនបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន ។ ការបោះបង់ចោលនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្ដឹងរដ្ឋប្បវេណី ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដោយមិនចាំបាច់

កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់នេះត្រូវបណ្ដាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្ដាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្តុតាង ។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែបានដូចបានចែងនៅមាត្រា ១៤៤ (ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ ។

**មាត្រា ១៥១.** – សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ

នៅក្នុងពេលស្ដាប់ចម្លើយ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។ ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ១៥២.** – ការពិភាក្សាដេញដោល ឬការសួរតទល់

បទប្បញ្ញត្តិនៃមាត្រា ១៥០ (ការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី) និងមាត្រា ១៥១ (សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តនៅក្នុងករណីសួរតទល់ដើមបណ្ដឹងរដ្ឋប្បវេណី ។

## ផ្នែកទី ៤
## ការស្ដាប់ចម្លើយសាក្សី

**មាត្រា ១៥៣.** – ការស្ដាប់ចម្លើយសាក្សី

ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសំដែងឱ្យឃើញការពិត ។

ចៅក្រមស៊ើបសួរស្ដាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីផងបានដែរ ។

បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន ។

ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈ បង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន ។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន ។ បញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។

**មាត្រា ១៥៤.** – សម្បថរបស់សាក្សី

មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា

និយាយតែការពិត ។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនេះ ។

**មាត្រា ១៥៥.** – ជំនួយរបស់អ្នកបកប្រែ

ចៅក្រមស៊ើបសួរអាចហៅអ្នកបកប្រែ ដើម្បីស្ដាប់ចម្លើយសាក្សី ដូចបានចែងនៅមាត្រា ១៤៤ (ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ ។

**មាត្រា ១៥៦.** – សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ

ត្រូវបានស្ដាប់ចម្លើយដោយមិនចាំបាច់ធ្វើសម្បថ ចំពោះសាក្សីដូចតទៅនេះ :

១-ឪពុក ម្ដាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ ។

២-កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ ។

៣-បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ ។

៤-បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ ។

៥-ប្ដី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ ។

៦-កុមារអាយុតិចជាង ១៤ ឆ្នាំ ។

**មាត្រា ១៥៧.** – ភាពគ្មានលទ្ធភាពស្ដាប់ចម្លើយរបស់សាក្សីមួយចំនួន

ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្ដាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ ។ ក្នុងករណីនេះ ចៅក្រមត្រូវយកនីតិវិធីនៃមាត្រា ១៤៣ (ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនេះ មកអនុវត្ត ។

**មាត្រា ១៥៨.** – ការចុះទៅដល់លំនៅឋានរបស់សាក្សី

ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះនៅ ដើម្បីទទួលចម្លើយ ។

## ផ្នែកទី ៥
## ការឆែកឆេរ និងការចាប់យកវត្ថុតាង

**មាត្រា ១៥៩.** – វិធានអនុវត្តចំពោះការឆែកឆេរ

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ។

ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ